ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



◆ សូមផ្ញើជូន ក្រុមអ្នកស្ម័គ្រចិត្តកម្ពុជានៃមជ្ឈមណ្ឌលឯកសារកម្ពុជាទាំងអស់

◆ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមកពីឃុំព្រះរំកិល ស្រុកបុរីអូរស្វាយសែនជ័យ ទទួលបានការពិនិត្យសុខភាពបឋម

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៩២ ខែមេសា ឆ្នាំ២០២៤

# ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

### សំបុត្រ

◆ សូមផ្ញើជូន ក្រុមអ្នកស្ម័គ្រចិត្តកម្ពុជានៃមជ្ឈមណ្ឌលឯកសារកម្ពុជា ទាំងអស់៖ ........................ ១
◆ ការជម្លៀសប្រជាជនដោយបង្ខំក្នុងរបប ........ ៣

### ផ្នែកឯកសារ

◆ តូច ចែម ៖ លេខាតំបន់២០ ភូមិភាគបូព៌ា ....... ៥

### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ

◆ មជ្ឈមណ្ឌលឯកសារកម្ពុជាជួបជុំជាមួយអ្នកស្ម័គ្រចិត្តកម្ពុជាក្រុមទី៧ និងទី៨ ចំនួនជាង២០០នាក់ មកពីខេត្តត្បូងឃ្មុំ និងខេត្តតាកែវ..................... ៩
◆ ជាវ ង៉ុយ ៖ អតីតកងចល័ត ................... ១២
◆ ទាក់ ញឹប ៖ អតីតកងកុមារក្នុងរបបខ្មែរ ...... ១៣
◆ សុខ សារឿន ៖ បងប្អូនរបស់ខ្ញុំស្លាប់ .......... ១៤
◆ ស៊ិម រិន៖ អតីតកងចល័តខ្មែរក្រហម .......... ១៥
◆ ស៊ិម ហួន៖ ឪពុកខ្ញុំធ្វើម្ហូប មាន់ ទា ទទួល .... ១៧
◆ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងរៀបចំទស្សនកិច្ចសិក្សាស្តីអំពីការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហមដល់អ្នកស្ម័គ្រចិត្តកម្ពុជា...... ១៩

### ផ្នែកវេទិកាពិភាក្សាសាធារណៈ

◆ អ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តកំពង់ចាម ចូលរួមទស្សនកិច្ចសិក្សាស្តីអំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យ ....................... ២៥
◆ អ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តត្បូងឃ្មុំ ចូលរួមទស្សនកិច្ចសិក្សាស្តីពី អំពើប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យ ដោយផ្ដោតសំខាន់លើ.............. ៣១
◆ អ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តព្រៃវែង ចូលរួមទស្សនកិច្ចសិក្សាស្តីពី អំពើប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យ ....................... ៣៥
◆ មជ្ឈមណ្ឌលដង្ហែដង្រាវាលវែង បានរៀបចំដំណើរទស្សនកិច្ចសិក្សាតាមផ្លូវវេជក្លើងខ្មែរក្រហម... ៤០



នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងកម្លាំងកុម្មុយនីស្តខ្មែរក្រហម បានគ្រប់គ្រងប្រទេសកម្ពុជា និងបង្កើតរបបកម្ពុជាប្រជាធិបតេយ្យ ដែលនៅទីបំផុតរបបនេះបានបណ្ដាលឲ្យប្រជាជនក្នុងចន្លោះពី១លាន៨សែនទៅ២លាន២សែននាក់ស្លាប់បាត់បង់ជីវិត។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

◆ មជ្ឈមណ្ឌលឯកសារកោះថ្មចុះពិនិត្យ និងវាយតម្លៃវេទិកាថ្នាក់រៀនស្តីពី «ការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងការទប់ស្កាត់............. ៤៤
◆ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមកពីឃុំព្រះរំកិល ស្រុកបុរីអូរស្វាយសែនជ័យ ទទួលបានការពិនិត្យសុខភាពបឋម ..................... ៤៦
◆ ចំណាប់អារម្មណ៍របស់អ្នកស្ម័គ្រចិត្តកម្ពុជាខេត្តកំពង់ចាម ................................ ៤៩

### ផ្នែកស្រាវជ្រាវរកគ្រួសារ

◆ ជីវិតកូនប្រុសពុកក្នុងគុកខ្មែរក្រហម (ត) ... ៥៧

**រក្សាសិទ្ធិ**
មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥ព.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្នេរលេខនេះ ៖** ឆាំង យុ, ផេង ពង្សរ៉ាស៊ី, ស៊ុយ សុខមាន, វេង សម្កស្ស, ម៉ាប់ ស៊ីណា, ស្លួត វិចិត្រ, ស៊ាង ចិន្តា, ឡុង ដានី, ឈុំ ក៉ា និង ហង្ស ឆាំឆាន
**អ្នកនិពន្ធ និងស្រាវជ្រាវ៖** មីន សាណាស់ **អ្នកបកប្រែ៖** លឹម អ៊ុកីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន
**ជំនួយការនិពន្ធនាយក៖** ដារ៉ារដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វេង
Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiasri.org

# សូមផ្ញើជូន ក្រុមអ្នកស្ម័គ្រចិត្តកម្ពុជានៃ មជ្ឈមណ្ឌលឯកសារកម្ពុជាទាំងអស់

**ឆាំង យុ**

ខ្ញុំបាទ សូមថ្លែងអំណរគុណដល់ ក្រុមអ្នកស្ម័គ្រចិត្តកម្ពុជា ទាំងអស់ ចំពោះការលះបង់ ការបំពេញការងារ និងការប្តេជ្ញាចិត្តចំពោះភាពជាអ្នកដឹកនាំសម្រាប់ប្រទេសរបស់ខ្លួន។ ការធ្វើដំណើរទស្សនកិច្ចទៅកាន់ទីតាំងដែលជាប់ពាក់ព័ន្ធនឹងរបបប្រល័យពូជសាសន៍ខ្មែរក្រហម គឺមិនមែនជារឿងងាយស្រួលនោះទេ។ ចំណែកឯការរៀនសូត្រអំពីប្រវត្តិសាស្ត្រ ក៏មិនងាយស្រួលដែរ។ ប្រវត្តិសាស្ត្រគឺមិនមែនជាមុខវិជ្ជាដែលងាយស្រួលរៀន ដោយសារធម្មជាតិរបស់មនុស្សមានលក្ខណៈស្មុគស្មាញ បន្កប់នូវមនោ-សញ្ចេតនា និងពោរពេញទៅដោយឥរិយាបថដែលមិនអាចរៀបរាប់បានអស់សេចក្តី។ ខណៈពេលដែលមនុស្សអាចបញ្ចេញនូវភាពសាហាវឃោរឃៅ ខ្លាំងយ៉ាងណាក៏ដោយ មនុស្សក៏អាចបង្ហាញនូវភាពស្រស់ផូរផង់ មានសណ្តានចិត្តល្អ និងភាពជាវីរបុរសថែមទៀតផង។ ដោយសារតែប្រវត្តិសាស្ត្រមិនមែនជារឿងងាយស្រួលបែបនេះហើយ ទើបអនាគតរបស់អ្នកទាំងអស់គ្នាក៏មិនងាយស្រួលដូចគ្នាដែរ។



លោក ឆាំង យុ នៅស្រុកកំណើត នៅខេត្តតាកែវ ឆ្នាំ១៩៩៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

សោកនាដកម្មនៅក្នុងប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា ត្រូវបានចារឹកទុកក្នុងក្រអៅបេះដូងនៃអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមប្រមាណ៥លាននាក់។ ខណៈពេលដែលអ្នករស់រានមានជីវិតនៃប្រវត្តិសាស្ត្រនេះបានបន្តបាត់បង់ទៅ វាគឺជាកាតព្វកិច្ចរបស់អ្នកទាំងអស់គ្នាក្នុងការថែរក្សាប្រវត្តិសាស្ត្រនេះ។ ទស្សនវិទូបារាំងឈ្មោះ ហ្វ្រង់ស្វ័រ ម៉ារី អារ៉ូអិត ឬត្រូវបានស្គាល់ថាជា អឹមដឺ វ៉ុលទែរ បាននិយាយ ថា៖« យើងត្រូវផ្តល់ការគោរព ចំពោះអ្នកដែលនៅរស់រានមានជីវិត ហើយយើងត្រូវផ្តល់ការពិត ចំពោះអ្នកដែលបាត់បង់ជីវិត។»

បើទោះជាអ្នកទាំងអស់គ្នាកំពុងរស់នៅទីណាក៏ដោយ អ្នកទាំងអស់គ្នាមិនត្រូវបណ្តោយឲ្យការពិតអំពីអតីតកាលរបស់ប្រទេសកម្ពុជា ត្រូវបានបំភ្លៃ លុបបំបាត់ ឬសាបរលាបនោះឡើយ។ ការប្តេជ្ញាចិត្តរបស់អ្នកទាំងអស់គ្នាចំពោះសច្ចភាពប្រវត្តិសាស្ត្រ គឺជា

ផ្នែកមួយនៃការតាំងចិត្តដ៏ធំធេងនៅក្នុងជីវិតរបស់អ្នកទាំងអស់គ្នាដែរគឺ៖ ចូរផ្តល់ភាពស្មោះត្រង់ចំពោះខ្លួនឯងផ្ទាល់ អ្នកដទៃ និងពិភពលោកទាំងមូល។

ខណៈពេលដែលអ្នកទាំងអស់គ្នាកំពុងបោះជំហានឆ្ពោះទៅរកអាជីពថ្មីៗ ការអប់រំជាន់ខ្ពស់ ឬវិថីជីវិតណាមួយក៏ដោយ ដែលអ្នកទាំងអស់គ្នាបានសម្រេចចិត្តជ្រើសរើស បន្ទាប់ពីចាកចេញពីកម្មវិធីយុវជនស្ម័គ្រចិត្តកម្ពុជា៖ ចូរចងចាំថាអ្នកទាំងអស់គ្នាពិតជាធ្លាប់មានឱកាស និងពេលវេលា ក្នុងការប្រែក្លាយពិភពលោកមួយនោះឲ្យមានភាពប្រសើរឡើងវិញដែរ។ គោលបំណងនៃកម្មវិធីយុវជនស្ម័គ្រចិត្តកម្ពុជាគឺបង្ហាញជូនអ្នកទាំងអស់គ្នានូវភាពស្មុគស្មាញនៃប្រវត្តិសាស្ត្រនេះផង និងផ្សារភ្ជាប់អ្នកទាំងអស់គ្នាទៅនឹងអារម្មណ៍ថ្មី ដែលទាក់ទងនឹងអតីតកាលនេះផង ហើយថាតើអតីតកាលនេះអាចតម្រែតម្រង់អនាគតរបស់អ្នកទាំងអស់គ្នាដោយរបៀបណា។ អ្នកទាំងអស់គ្នាគួរចាប់យកឱកាសនៃការភ្ជាប់ទំនាក់ទំនងជាមួយប្រវត្តិសាស្ត្រនេះដើម្បីធ្វើជាផ្នែកមួយនៃដំណើរជីវិតរបស់ខ្លួនដែរ ដោយសារតែប្រវត្តិសាស្ត្រមិនត្រឹមតែសំខាន់សម្រាប់ខ្លួនអ្នកផ្ទាល់ និងក្រុមគ្រួសារប៉ុណ្ណោះទេ ប៉ុន្តែក៏កាន់តែសំខាន់ចំពោះការសម្រេចបាននូវអនាគតដ៏ល្អប្រសើរជាងមុនសម្រាប់ប្រទេសជាតិ និងពិភពលោកថែមទៀតផង។ រៀងរាល់ដែលមានថ្ងៃថ្មី ការសម្រេចចិត្តថ្មី និងការបោះជំហានទៅមុខ គឺសុទ្ធសឹងតែជាឱកាសថ្មីក្នុងការគោរពដល់អតីតកាលតាមរយៈការទទួលយកនូវការពិតក្នុងជីវិត។

សូមបួងសួងដល់ទេវតាឆ្នាំថ្មីប្រទានសព្ទសាធុការពរដល់អ្នកទាំងអស់គ្នា សួស្តីឆ្នាំថ្មីប្រពៃណីជាតិខ្មែរ។

ពីខ្ញុំបាទ **ឆាំង យុ**
នាយកប្រតិបត្តិមជ្ឈមណ្ឌលឯកសារកម្ពុជា



អ្នកស្ម័គ្រចិត្តកម្ពុជា ជំនាន់ទី៤ ចូលរួមដំណើរទស្សនកិច្ចសិក្សាអំពី «ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យ» ផ្តោតសំខាន់ទៅលើការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩) តាមផ្លូវរថភ្លើងឆ្ពោះទៅខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម

ឆាំង យុ



នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងកម្លាំងកុម្មុយនីស្តខ្មែរក្រហម បានគ្រប់គ្រងប្រទេសកម្ពុជា ទាំងស្រុង និងបានជម្លៀសប្រជាជនចេញពីផ្ទះសម្បែងឲ្យទៅរស់នៅតាមសហករណ៍ស្ថិតនៅទីជនបទដាច់ស្រយាល។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មានបីករណីដែលប្រជាជនកម្ពុជាបាននិរាសព្រាត់ប្រាសក្រុមគ្រួសារ។ សង្គ្រាមនៅប្រទេសកម្ពុជាចន្លោះពីឆ្នាំ១៩៧០ ដល់ ១៩៧៥ ដែលបានបែងចែកប្រទេសកម្ពុជាឲ្យដាច់ស្រឡះពីគ្នារវាង «តំបន់រំដោះ» ដែលគ្រប់គ្រងដោយខ្មែរក្រហម និងតំបន់ដែលគ្រប់គ្រងដោយរបបសាធារណរដ្ឋខ្មែរដឹកនាំដោយឧត្តមសេនីយ៍ លន់ នល់។ គ្រួសារនិងសាច់ញាតិត្រូវបានបំបែក។ ក្នុងករណីខ្លះ បងប្អូនបានវាយប្រយុទ្ធគ្នានៅផ្នែកម្ខាងៗនៃសង្គ្រាម។ អ្នកទាំងនោះមិនអាចផ្សះផ្សាគ្នាបានឡើយ ទោះបីសង្គ្រាមបានបញ្ចប់នៅឆ្នាំ១៩៧៥ ទៅហើយយ៉ាងណាក៏ដោយ។ ទីពីរ) គ្រួសារបានបែកខ្ញែកគ្នានៅពេលដែលខ្មែរក្រហមចូលកាន់កាប់ប្រទេសកម្ពុជា នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ លើកនេះ គោលនយោបាយដោយចេតនាត្រូវបានបង្កើតឡើងដើម្បីធ្វើឲ្យប្រាកដថាស្ថាប័នគ្រួសារត្រូវតែបានបំផ្លាញ។ ការងារតាមកងចល័តផ្សេងៗបានបង្កើតឡើងដើម្បីជំនួសការងារពីសង្គមមុន។ អាពាហ៍ពិពាហ៍ត្រូវបានរៀបចំឡើងជាលក្ខណៈទ្រង់ទ្រាយធំដោយអង្គការ (ការដឹកនាំបែបស្រមើស្រមៃរបស់ខ្មែរក្រហម)។ កុមារដាក់ឲ្យនៅ

ក្នុងអន្តរភាពកុមារ ហើយបង្រៀនថា ឪពុកម្តាយរបស់ក្មេងៗទាំងនោះគឺជាអន្តការៗ ប្រជាជនបានខិតខំប្រឹងប្រែងទាំងក្នុងរបបខ្មែរក្រហម និងបន្ទាប់ពីរបបខ្មែរក្រហមដើម្បីតាមស្វែងរកសាច់ញាតិរបស់ខ្លួនដែលបានបាត់ដំណឹង ប៉ុន្តែការខិតខំប្រឹងប្រែងរបស់ប្រជាជនយើងគឺមិនបានទទួលផលឡើយៗ ទីបី) នៅពេលដែលខ្មែរក្រហមត្រូវបានផ្តួលរំលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ មួយភាគធំនៃប្រជាជនបានធ្វើដំណើរទៅនៅជាមួយខ្មែរក្រហមដែលបានដកថយទៅនៅភាគខាងលិច និងនៅព្រំដែនថៃជំនួសឲ្យការវិលត្រឡប់មកស្រុកកំណើតវិញៗ ប្រជាជនខ្លះអាចផ្លាស់ទៅរស់នៅប្រទេសទីបីៗ ប្រជាជនខ្លះទៀតបានធ្វើមាតុភូមិនិវត្តន៍មកស្រុកកំណើតវិញនៅដើមទសវត្សរ៍ឆ្នាំ១៩៩០ៗ ជាលទ្ធផលនៃរឿងរ៉ាវប្រវត្តិសាស្ត្រទាំងនេះ សព្វថ្ងៃមានប្រជាជនកម្ពុជាប្រមាណបីសែននាក់កំពុងរស់នៅក្នុងសហរដ្ឋអាមេរិក ហើយអាចកើនរហូតដល់មួយលាននាក់ រស់នៅរាយប៉ាយជុំវិញពិភពលោកៗ

ប្រជាជនកម្ពុជា នៅតែស្វែងរកសាច់ញាតិដែលបាត់ខ្លួនរបស់ខ្លួន ហើយការដឹងអំពីដោគវាសនានៃមនុស្សជាទីស្រឡាញ់របស់ខ្លួនដែលបាត់បង់នោះ គឺជាកត្តាសំខាន់ណាស់ក្នុងការផ្សះផ្សាជាមួយនឹងអតីតកាលៗ វាក៏អាចជួយឲ្យប្រជាជនយើងទប់ទល់នឹងឥទ្ធិពលនៃជំងឺបាក់ទឹកចិត្តក្រោយការប៉ះទង្គិចផ្លូវចិត្ត ដែលត្រូវបានគេគិតថាមានការរីករាលដាលក្នុងចំណោមប្រជាជនកម្ពុជាដែលទទួលរងនូវផលប៉ះពាល់ពីសង្គ្រាម និងអំពើប្រល័យពូជសាសន៍ៗ ការស្រាវជ្រាវនេះមានគោលបំណងបំពេញតម្រូវការខាងលើ ដោយការបោះពុម្ពផ្សាយកំណត់ត្រាជីវប្រវត្តិជនរងគ្រោះដោយអំពើប្រល័យពូជសាសន៍ (ដោយរាប់បញ្ចូលទាំងអ្នកដែលមានតួនាទី និងឋានៈនៅក្នុងរបបខ្មែរក្រហម) ដែលស្រង់ចេញពីប្រព័ន្ធទិន្នន័យជីវប្រវត្តិ ប្រវត្តិរូប រូបថត និងភូមិសាស្ត្ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាៗ កំណត់ត្រានីមួយៗរបស់ជនរងគ្រោះរួមមាន ព័ត៌មានជីវប្រវត្តិ និងព័ត៌មានដែលមានការទាក់ទងជាមួយនឹងជនរងគ្រោះៗ ការស្រាវជ្រាវនេះមានគោលបំណងបោះពុម្ពសៀវភៅចំនួនបីពាន់ក្បាល បន្ទាប់មកចែកចាយដោយឥតគិតថ្លៃដល់សាលាឃុំទាំងអស់នៅទូទាំងប្រទេសកម្ពុជា និងសហគមន៍ខ្មែរធំៗនៅក្រៅប្រទេស ព្រមទាំងបង្កើតឲ្យមានវេទិកាសហគមន៍ និងប្រមែប្រមូលព័ត៌មានពីអ្នកភូមិដើម្បីដោះស្រាយការខុះខាត និងទទួលមតិកែលម្អៗ



នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងកម្លាំងកុម្មុយនីស្តខ្មែរក្រហមបានគ្រប់គ្រងប្រទេសកម្ពុជាទាំងស្រុង និងបានជម្លៀសប្រជាជនចេញពីផ្ទះសម្បែងឲ្យទៅរស់នៅតាមសហករណ៍ស្ថិតនៅទីជនបទដាច់ស្រយាលៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# តូច ចែម ៖ លេខាតំបន់២០ ភូមិភាគបូព៌ា

**ដារ៉ាវដ្ឋ មេត្តា**



ប្រធានកងអនុសេនាតូច ប៉ែន សាម៉េន (រូបទីពីរ រាប់ពីខាងស្តាំ) នៅភូមិភាគបូព៌ានៃកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ១៩៧៨។ ប៉ែន សាម៉េន ធ្លាប់បានរៀបចំការបះបោរប្រឆាំងនឹងរបបកម្ពុជាប្រជាធិបតេយ្យ និងដឹកនាំកងចារកិច្ចដែលបានតស៊ូមុនពេល សាម៉េន ត្រូវបានខ្មែរក្រហមចាប់ខ្លួន និងសម្លាប់ចោល។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា/ភ្នាក់ងារសារព័ត៌មានវៀតណាម)

ខ្ញុំឈ្មោះ តូច ចែម ហៅ សុត្រ អាយុ៣៨ឆ្នាំ នៅក្នុងឆ្នាំ១៩៧៨។ ខ្ញុំកើតនៅក្នុងភូមិអន្លង់ក្រេះ ឃុំដូនតីខាងកើត ស្រុកពញាក្រែក តំបន់២០ ភូមិភាគបូព៌ា។ ឪពុកម្តាយខ្ញុំស្លាប់អស់ហើយ ហើយខ្ញុំនៅមានប្អូនស្រីតែម្នាក់ឈ្មោះ ជន់។ នៅក្នុងឆ្នាំ ១៩៥៩ ខ្ញុំរស់នៅជាមួយជីតារបស់ខ្ញុំឈ្មោះ ញ៉ែម នៅក្នុងភូមិអន្លង់ក្រេះ ឃុំដូនតីខាងកើត។ ក្រោយមកខ្ញុំបានខូចសីលធម៌ជាមួយនារីឈ្មោះ យ៉ែន នៅភូមិថ្លុកក្រោមហើយឪពុកម្តាយនាងរករឿងខ្ញុំ ដូច្នេះខ្ញុំក៏មករស់នៅជាមួយឪពុកធំឈ្មោះ យ៉ាំ នៅភូមិអន្លង់ក្រេះខាងជើង។ មកនៅទីនេះ ខ្ញុំបានស្គាល់មនុស្សពីរនាក់ឈ្មោះ ស៊ិក និង ញឹម រួចរាប់អានធ្វើជាមិត្តភក្តិនឹងគ្នា។ ឈ្មោះ ឆន គឺជាមារបស់ ស៊ិក ឃើញខ្ញុំមិនមានធ្វើការងារ ក៏បបួលខ្ញុំធ្វើការជាមួយគាត់។

នៅខែមីនា ឆ្នាំ១៩៦០ ឆនបានហៅ ស៊ិក, ញឹម និង ខ្ញុំ ទៅព្រៃខ្នាចចក ជួបជាមួយឈ្មោះ ភឹម និងភួង ដើម្បីឧទ្ទេសនាមឲ្យឈ្មោះ ភឹម និង ភួង បានទទួលស្គាល់ជា សេ-អ៊ី-អា ដោយមានរៀបចំពិធីផងដែរ។ ពេលចប់កម្មវិធី ភឹម បានណែនាំខ្ញុំ, ញឹម, ស៊ិក ឲ្យចូលវង់ភ្លេងឃុំដូនតី ជាមួយ ឡាក់ គឺជាលេខាស្រុកទឹកជ្រៅ ដោយមាន ឆន គឺជាអ្នកជូនមក។ ឆន បានឲ្យខ្ញុំស្គាល់ឈ្មោះ ឯក ឯម និង សួន គឺជាគណៈភូមិក្នុង

រដ្ឋអំណាចខ្លាំងៗ អ្នកនៅក្នុងវង់ភ្លេងឃុំដូនតី មាន ឈ្មោះ ឡាក់, ស៊ុក សមាជិកតំបន់២០, ញឹក រោងចក្រ អារឈើរបស់ភូមិភាគ, អ៊ិន ទទួលបច្ចេកទេសកាត់ដេរ របស់ភូមិភាគ, ចន, ផុន, អ៊ិន ក្រោយមកក៏ស្លាប់, អ៊ី នៅក្នុងឆ្នាំ១៩៧១ គឺជាលេខាអនុកងធំមកនៅ ទ័ពភាគ, ផាន នៅសហករណ៍អន្លង់ក្រេះ, ផុន នៅ សហករណ៍ក្របៅ, ប៊ិន សមាជិកគណៈកសិកម្ម-សិប្បកម្មភូមិភាគ, គឹម នីសារ និង ខ្ញុំ។ សកម្មភាពភ្លេង នេះគឺដើរលេងបំផុសឲ្យយុវជន យុវនារី ភ្ញើតភ្ញើន តាមការអូសទាញ សេ-អ៊ី-អា។ វង់ភ្លេងឃុំដូនតីបាន ដើរលេងនៅឃុំដូនតី និងឃុំត្រស់។

នៅឆ្នាំ១៩៦២ ឆន ដកខ្ញុំ, ស៊ុក និង ញឹម ឲ្យមក ក្តាប់ភូមិអន្លង់ក្រេះ។ នៅក្នុងឆ្នាំ១៩៦៨ ខ្ញុំយក សំបុត្រឲ្យ គឹម ជាបន្តបន្ទាប់ និងពេលខ្លះជូនឈ្មោះ ឆន មកជួប គឹម។ ឆន និង គឹម បានឲ្យខ្ញុំស្គាល់ឈ្មោះ ពាម, ម៉ុន, ភួង, ចាន់ សាម៉ន, ស៊ុន, ណាំ សាន, ម៉ៃ ដូ, គាត, គាល់, កែ, រិន និង អោម ជា សេ-អ៊ី-អា គឹម កសាងជាយូរហើយ។

នៅឆ្នាំ១៩៧១ គឹម ដកខ្ញុំមកធ្វើជាសមាជិក ស្រុកពញាក្រែក។ ក្នុងនោះមាន ទេព កង គឺជាលេខា ស្រុកពញាក្រែក ស៊ឹម ហៅ ធ្មេញស អនុលេខាស្រុក ពញាក្រែក, សារឿង, ញូង ហៅ សុខ និង បេ សាលី គឺជាសមាជិក។ ក្រោយចាត់តាំងហើយ គឹម ណែនាំ ឲ្យក្តាប់ខ្សែជាមួយគ្នាហើយឡើងទៅ គឹម ផ្ទាល់។ កាលនោះ គឹម ទទួលជាលេខាតំបន់២១។ ក្រោយមក កង ហៅយើងទៅប្រជុំ និងចាត់តាំងតាមភារកិច្ចគឺ ១) ស៊ឹម ហៅ ធ្មេញស ចុះកសាងកម្លាំង សេ-អ៊ី-អា នៅឃុំដូនតីខាងកើត និងឃុំកណ្តោលជ្រុំ។ ២) ញូង ហៅ សុខ ចុះកសាងកម្លាំង សេ-អ៊ី-អា នៅឃុំ ត្រពាំងផ្លុង និងឃុំជីមាន់។ ៣) សាលី ចុះកសាង កម្លាំង សេ-អ៊ី-អា នៅឃុំក្រែក និងឃុំកោងកាង។ ៤) ខ្ញុំ ចុះកសាងកម្លាំង សេ-អ៊ី-អា នៅឃុំមានជ័យ និងឃុំកក់។

នៅឆ្នាំ១៩៧២ គឹម ឈប់ធ្វើជាលេខាតំបន់២០ ហើយចាត់តាំង ទឹម គឺជាលេខា, គង់ សាគុន ហៅ ទុយ អនុលេខា។ គឹម បានខេទ្វសនាមខ្សែ សេ-អ៊ី-អា ឲ្យជាប់ជាមួយ ទឹម និង ទុយ ផ្ទាល់។ ខ្ញុំបានធ្វើការទាក់ ទងជាមួយឈ្មោះ ខាង លេខាស្រុកកំចាយមារ, វ៉ាន់ ហៅ សុង លេខាស្រុកកញ្ជ្រៀច, ហាន លេខា ស្រុក មេសាង តាមការខេទ្វសនាមរបស់ ទឹម។ នៅក្នុង ឆ្នាំ១៩៧២ដដែល ឈ្មោះ សាឡាត់ ហៅ ស៊ឹម ក៏មក ធ្វើជាលេខាស្រុកពញាក្រែក ដោយតំបន់បានដក ឈ្មោះ ទេព កង និង បេ។ ទឹម ក៏បានខេទ្វសនាមខ្ញុំឲ្យ ជាប់ខ្សែ សេ-អ៊ី-អា ជាមួយ ស៊ឹម។

នៅក្នុងឆ្នាំ១៩៧៣ ខ្ញុំធ្វើសកម្មភាពប្រឆាំងមាគ៌ា ចាត់តាំងសហករណ៍របស់បក្ស ព្រោះលំបាកណាស់ មិនដូចយើងរស់នៅឯកជនទេ។ ខ្ញុំក៏បានបំផុសបំផុល ចលនាប្រជាជនជាបន្តបន្ទាប់។ គឹម បានហៅខ្ញុំ, ស៊ឹម និងតា ធ្មេញស ទៅជួបនៅភូមិពន្លឺ ឃុំដូនតី ណែនាំឲ្យ សហការជាមួយ សេ-អ៊ី-អា យួនដើម្បីរួមកម្ទេចបក្ស កុម្មុយនីស្តកម្ពុជា។ ទឹម បាននាំខ្ញុំ តាធ្មេញស ទាក់ទង សេ-អ៊ី-អា យួននៅត្រពាំងផ្លុង ស្រុកពញាក្រែក។ យួនបានសុំបោះទីតាំងទ័ពនៅតំបន់២០ ហើយឈ្មោះ ទឹម ក៏យល់ព្រម។

នៅខែមេសា ឆ្នាំ១៩៧៤ គឹម ដកខ្ញុំមកធ្វើជា លេខាស្រុកត្រមូង ដែលទើបតែបង្កើតថ្មី ដើម្បីកសាង កម្លាំង សេ-អ៊ី-អា ឲ្យទាន់ពេលវេលាដោយស្រុក នេះមិនទាន់ក្តាប់បានទាំងស្រុងដូចនៅពញាក្រែក ឡើយ។ គឹម បានឲ្យខ្ញុំទាក់ទងមិត្ត របស់បងចាន់ លេខាតំបន់២១ ដែលជាខ្សែសំខាន់ហើយខ្ញុំក៏អាច ទាក់ទង គឹម ផ្ទាល់ដែរ។ ក្រោយមកខ្ញុំ, ឈុំ សាម៉ៃ, ព្រឿង និង ម៉ៅ បានធ្វើសកម្មភាពកសាងកម្លាំងបាន មួយចំនួនរួមមាន ហាប គឺជាលេខាឃុំត្រមូង, អឿន អនុលេខាឃុំត្រមូង, មឹក, ហ៊ាង គឺជាសមាជិក ឃុំ ត្រមូង, ស៊ូ គឺជាលេខាឃុំមេមង, វន គឺជាអនុលេខា ឃុំមេមង,ជុន, ទឹម និង ហ៊ី គឺជាសមាជិក ឃុំមេមង។ កុម គឺជាលេខាឃុំជាំតាម៉ៅ, ឡាច អនុលេខាឃុំ ជាំតាម៉ៅ,ជា, ឆ្លូញ, សឿន គឺជាសមាជិកឃុំជាំ តាម៉ៅ។ ថែម លេខាឃុំទន្លូង, រិត អនុលេខាឃុំទន្លូង, កុប, យន់, លាប គឺជាសមាជិកឃុំទន្លូង។ ឈុំ គឺជា

លេខាឃុំជាំក្រវៀន, បរ៉ុង គឺជាអនុលេខាឃុំជាំក្រវៀន, យ៉ន សមាជិកឃុំជាំក្រវៀន, សេង គឺជាលេខាឃុំជាំ, សី គឺជាអនុលេខាឃុំជាំ, ស្មោង សឿន គឺជាសមាជិកឃុំជាំ, ម៉ន គឺជាលេខាឃុំចាន់មូល, ផល គឺជាអនុលេខាឃុំចាន់មូល, រស់ ខ្វាក គឺជាសមាជិកឃុំចាន់មូល។ ពិន គឺជាលេខាឃុំរូង, ឡេង គឺជាអនុលេខាឃុំរូង, ម៉ុង គឺជាសមាជិកឃុំរូង, នុត គឺជាសមាជិកឃុំរូង, សាវ៉ាន់ គឺជាសមាជិកឃុំរូង, សាំង គឺជាប្រធានមន្ទីរស្រុក, ឃឹម គឺជាអនុលេខាមន្ទីរស្រុក, ផល គឺជាសមាជិកមន្ទីរស្រុក, ខេង គឺជាប្រធានអង្គការយុវជនរបស់ស្រុក, នួន គឺជាអនុប្រធានអង្គការយុវជនរបស់ស្រុក។ សំខាន់ គឺជាប្រធានកសិកម្មស្រុកត្រមូង, សឿន គឺជាអនុប្រធានកសិកម្មស្រុកត្រមូង, ណុល គឺជាប្រធានមន្ទីរសេដ្ឋកិច្ច, ហឿន គឺជាអនុប្រធានមន្ទីរសេដ្ឋកិច្ច, យ៉ាន ប្រធានសំណង់របស់ស្រុក, យឿន ប្រធានពាណិជ្ជកម្មស្រុក, សាវ៉ាត អនុប្រធានពាណិជ្ជកម្ម, សារឿន ប្រធានគមនាគមន៍ស្រុក, ចុល អនុប្រធានគមនាគមន៍ស្រុក, សាម៉ុន គឺជាប្រធានយោធាស្រុក។

នៅខែមេសា ឆ្នាំ១៩៧៥ បងចាន់, ភួង បានហៅខ្ញុំទៅមន្ទីរតំបន់២១ នៅភូមិគោកចារ ពេលខ្ញុំមកដល់ឃើញបងចាន់, ភួង, ម៉ែដូ, គង្គា, សុក សៅ, ឈឿន, ឆោម សាវ៉ាត, ផា, សាប៊ុន, ឡាក់, ហ៊ិ នៅទីនោះ។ ពេលនោះ ភួង, បងចាន់ បានណែនាំទាំងអស់គ្នាឲ្យបំផុសបំផុលប្រជាជនក្រោកឡើងបះបោរប្រឆាំងនឹងបក្ស ធ្វើបាតុកម្ម កុប្បកម្ម ទាមទាររបបរស់នៅជាឯកជន ធ្វើការងារឯកជន ទាមទារសាសនា ប្រឆាំងនឹងរបបសហករណ៍របស់បក្សឲ្យធ្វើដូចពីដើម។ ខ្ញុំក៏ទាក់ទងឈ្មោះ ម៉ាន់ ប្រធានទទួលខុសត្រូវខ្មែរអ៊ិស្លាមរួមគ្នា ខ្មែរអ៊ិស្លាមមានចំនួន៣សែននាក់ ឈ្មោះ ម៉ាន់ គឺជាអ្នកទទួលខុសត្រូវខ្មែរអ៊ិស្លាមរបស់ភូមិភាគ។ ពេលនោះ យើងរួមគ្នាបំផុសបំផុលប្រជាជនបះបោរជាបន្តបន្ទាប់ ដូចជា នៅស្រុកក្រូចឆ្មារ ស្រុកត្បូងឃ្មុំ ក្រៅពីនេះគ្រាន់តែរំដើបរំដួលជាពិសេសខ្មែរអ៊ិស្លាម ខ្លាំងជាងគេ។

នៅខែវិច្ឆិកា ឆ្នាំ១៩៧៦ ខ្ញុំណែនាំឈ្មោះ ឡាក់, ហ៊ិ, សាប៊ុន, បូ, ផា, ឆោម សាវ៉ាត, គង្គា និង ស្រេង ណែនាំនៅតំបន់គឺឲ្យបំផ្លាញផលដំណាំស្រូវនៅរដូវប្រូត, ពង្រីងនិងពង្រីកកម្លាំង សេ-អ៊ី-អា នៅតាមស្រុកនីមួយៗ។ កសាងកងទ័ពនៅតាមស្រុកពីកងអនុសេនាធំនៅស្រុកនីមួយៗត្រៀមលក្ខណៈសម្បត្តិដើម្បីទទួលផែនការពីថ្នាក់លើវាយបក្សកុម្មុយនីស្តកម្ពុជា។ នៅខែធ្នូ ភឹម ហៅខ្ញុំទៅមន្ទីរសិប្បកម្មភាគបោះទីតាំងនៅភូមិចិញ្ចើម ឃុំចិញ្ចើម ស្រុកត្បូងឃ្មុំ តំបន់២១។ ពេលខ្ញុំទៅដល់មានបងចាន់, ភួង, ពាម, ភឹម បានណែនាំខ្ញុំឲ្យដឹករូងសម្ងាត់២ខ្សែគឺ មួយដឹកចេញពីភូមិរកាខ្នុរ ឃុំរកាខ្នុរ ស្រុកក្រូចឆ្មារ ទៅភូមិអំពិល ឃុំរកាខ្នុរបុងខាងកើត ទៅភូមិក្របីគ្រៀល ឃុំឈូក ស្រុកក្រូចឆ្មារ ទៅព្រៃអាង្គួន ទៅកាត់ភូមិស្វាយកាំបិត ឃុំស្រែប្រាំង ស្រុកដំបែរ ទៅភូមិទួលសំបូរ ស្រុកដំបែរ ទៅថ្មដាប់ ឃុំរំចេក ស្រុកមេមត់ ទៅព្រៃបាក់ស្អង ទៅភូមិកន្ទោង ស្រុកមេមត់ ទៅភ្នំបាខែង ទៅភូមិឈើខ្លឹម ក្នុងឃុំគគីរ ស្រុកមេមត់ ទៅភូមិក្របាស ឃុំមេមង ស្រុកត្រមូង ទៅភូមិអង្គាំ ទៅភូមិជ្រៃ ទៅភូមិដោង ទៅភូមិកន្ទ្រើយ ទៅភូមិរូង ភូមិស្រោមដាវ ក្នុងស្រុកត្រមូងតំបន់២១ ចេញពីនេះទៅធ្លាក់ដល់ស្រុកតឹងបៀង ប្រទេសវៀតណាម។ ចំណែកមួយខ្សែទៀតដឹកចេញពីភូមិខ្សាច់ប្រឆេះ ឃុំខ្សាច់ប្រឆេះ ចេញមកជួបគ្នានៅភូមិក្របីគ្រៀល ឃុំឈូក ស្រុកក្រូចឆ្មារ។ យើងត្រៀមពេលធ្វើសកម្មភាពបែកការណ៍ យើងយករូងនេះធ្វើជាមូលដ្ឋានសម្រាប់គេចខ្លួនទៅប្រទេសវៀតណាម បញ្ហាមួយទៀតយករូងនេះធ្វើជាមូលដ្ឋានសម្រាប់នាំកងទ័ពយួនមកវាយបក្សកុម្មុយនីស្តកម្ពុជាក្នុងសភាពការណ៍តឹងតែង។

នៅខែមករា ឆ្នាំ១៩៧៧ ខ្ញុំបានចុះទៅជួប សាប៊ុន, គង្គា, ហ៊ិ, ស្រេង និង ឡាក់។ ខ្ញុំណែនាំឲ្យធ្វើពីភូមិជប់ រហូតដល់ប្រទេសវៀតណាម ដើម្បីធ្វើសកម្មភាព និងអនុវត្តផែនការគឺដឹកកងទ័ពយួនពីក្រៅមកធ្វើសកម្មភាពវាយបក្សកុម្មុយនីស្តកម្ពុជា

ដោយយកផ្លូវនេះជាយុទ្ធសាស្ត្រយោធា។ នៅចុងខែកុម្ភៈ ចាប់អនុវត្តធ្វើផ្លូវមានកម្លាំងខាង ភួង និងកម្លាំងខាងខ្ញុំទាំង៥ស្រុក។ នៅខែសីហា ភឹម ឲ្យខ្ញុំទៅ ទាក់ទងយួនជាមួយ ប៉ៃផាត គឺជាលេខាខេត្តតៃនិញ។ ក្រោយមក ភឹម បានហៅខ្ញុំទៅប្រជុំនៅក្រុងស្វាយរៀង កន្លែងឈ្មោះ ហាយ សូ ទទួលភ្ញៀវពេលនោះ។ អ្នកចូលរួមខាងយួនមាន ហាយ សូ គឺជាសមាជិកគណៈមជ្ឈិមបក្សកុម្មុយនីស្តយួន, ប៉ៃម៉ាប់ រួមទាំងកងការពារចំនួន១៥នាក់ ហើយចំណែកខាងខ្មែរមានភឹម, ចាន់, ម៉ុន, ពាម, សូ, ខ្ញុំ, ស៊ុន និង យាន។ ពេលនោះ ភឹម បានរាយការណ៍អំពីការអនុវត្តផែនការជាបន្តបន្ទាប់វាយបក្សកុម្មុយនីស្តកម្ពុជា ក៏ត្រូវបរាជ័យជាបន្តបន្ទាប់ ហើយបក្សកុម្មុយនីស្តកម្ពុជាចាប់កម្លាំងយើងអស់ជាច្រើនទៀត។ ហាយ សូ មានយោបល់ថា បក្សកុម្មុយនីស្តវៀតណាមកំណត់វាយបក្សកុម្មុយនីស្តកម្ពុជាដោយមានការបែងចែកមុខព្រួញវាយតាមផ្លូវជាតិលេខ១ លេខ២២ និង ផ្លូវជាតិលេខ២៧ ចាស់។ យើងបានកំណត់វាយនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៧។

នៅខែកុម្ភៈ ឆ្នាំ១៩៧៨ ភឹម បានហៅខ្ញុំទៅប្រជុំនៅស្នួល មន្ទីរភាគហើយអ្នកចូលរួមប្រជុំខាងយួនមានឈ្មោះ ហាយ សូ, ប៉ៃម៉ាប់, បា ហាយ, ទឹកាម, បា យៀក, បា ថាយ, បា ដុង និងខាងខ្មែរមានភឹម, បង ចាន់, ឈាន, ម៉ុន, ពាម, ស៊ុន, រិន និង ខ្ញុំ។ អង្គប្រជុំបានលើកឡើងអំពីបញ្ហាបរាជ័យ ក្នុងឆ្នាំ១៩៧៧ និងការអនុវត្តផែនការនៅឆ្នាំ១៩៧៨នេះ។ នៅខែឧសភា ឆ្នាំ១៩៧៨ ខ្ញុំចុះទៅមើលគេជីករូង ពីភូមិរកាខ្នុរដែលទើបជីកហើយ ឃុំរកាខ្នុរ ស្រុកក្រូចឆ្មារ មកភូមិក្របីគ្រៀល ឃុំឈូក ស្រុកក្រូចឆ្មារដដែល។ ចំណែកស្រុកស្នួលជីកហើយ ពីភូមិខ្សាច់ប្រឆេះ ទៅជួបនឹងភូមិក្របីគ្រៀល សម្រេចផែនការបាន៥ភាគរយ។ ភឹម ដកស្រុកក្រូចឆ្មារទៅកាន់ផ្ទាល់ដោយចាត់តាំងឈ្មោះ ហឿង គឺជានីរសារ ធ្វើជាលេខាស្រុក អៀម និង យោក គឺជាសមាជិក។ ភឹម ក៏បានឲ្យឈ្មោះ ហឿង, សុង ទទួលខុសត្រូវជីករូងវិញ។ ចំណែកខ្ញុំចុះជាប់មកធ្វើផ្លូវ។ ផ្លូវធ្វើហើយពីភូមិជប់ ឃុំជប់ រហូតដល់ភ្នំបាក់ស្អួង ហើយនៅតែពីស្រុកទេគឺស្រុកមេមត់ និងស្រុកត្រាមូង តំបន់២១។ រហូតដល់ថ្ងៃទី២៣ ខែឧសភា អង្គការចាប់ខ្លួនខ្ញុំតែម្តង។

***កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីចម្លើយសារភាពឯកសារ D១៣៤១៩។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំនិងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថាចម្លើយសារភាពរបស់ តូច ចែម ហៅ សុត្រ ពិតប៉ុន្មានយ៉ាងណានោះទេ?***



កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ឆ្នាំ១៩៧៨។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា/ ភ្នាក់ងារសារព័ត៌មានវៀតណាម)

# មជ្ឈមណ្ឌលឯកសារកម្ពុជា ជួបជុំជាមួយ អ្នកស្ម័គ្រចិត្តកម្ពុជាក្រុមទី៧ និងទី៨ ចំនួនជាង២០០នាក់ មកពីខេត្តត្បូងឃ្មុំ និងខេត្តតាកែវ

*ផេង ពង្សរ៉ាស៊ី*



អ្នកស្ម័គ្រចិត្តកម្ពុជាក្រុមទី៧ និងទី៨ ចំនួនជាង២០០នាក់ មកពីខេត្តត្បូងឃ្មុំ និងខេត្តតាកែវ ប្រជុំជាមួយលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា នៅសណ្ឋាគារ ហាយយ៉ាត់ ក្នុងក្រុងភ្នំពេញ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ព្រឹកថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារកម្ពុជា បានរៀបចំការជួបជុំមួយជាមួយអ្នកស្ម័គ្រចិត្តកម្ពុជាក្រុមទី៧ និងទី៨ ចំនួនជាង២០០នាក់ មកពីខេត្តត្បូងឃ្មុំ និងខេត្តតាកែវ នៅបន្ទប់ប្រជុំនាសណ្ឋាគារ ហាយយ៉ាត់ ដើម្បី៖ (១) ផ្តល់ឱកាសដល់យុវជនបង្ហាញពីលទ្ធផលកិច្ចការស្រាវជ្រាវរយៈពេលខ្លីរបស់ខ្លួននិង (២) ទទួលយកអនុសាសន៍ល្អពីនាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ទាក់ទងនឹងប្រធានបទស្រាវជ្រាវ។

ដំបូងលោក ផេង ពង្សរ៉ាស៊ី គឺជាអ្នកសម្របសម្រួល បានប្រាប់ពីវត្ថុបំណងនៃកិច្ចប្រជុំ និងការរៀបចំក្រុមយុវជនដើម្បីឡើងធ្វើបទបង្ហាញ។ ជាមួយគ្នានេះដែរលោក ផេង ពង្សរ៉ាស៊ី ក៏បានលើកឡើងពីផែនការរៀបចំ «ដំណើរទស្សនកិច្ចអប់រំ» នៅខែឧសភា និងមិថុនា ឆ្នាំ២០២៤ បន្ថែមទៀត ដើម្បីផ្តល់ឱកាសដល់យុវជនដទៃទៀត បានចូលរួម និងឈ្វេងយល់អំពី «ការជម្លៀសប្រជាជនដោយបង្ខំ» នៅដំណាក់កាលទី៣ របស់ខ្មែរក្រហម។ ដើម្បីឲ្យការធ្វើបទបង្ហាញរបស់យុវជនកាន់តែប្រសើរឡើង លោក ផេង ពង្សរ៉ាស៊ី ក៏បានពន្យល់បន្ថែមអំពីជំពូកនៃការជម្លៀសប្រជាជនដោយបង្ខំ ព្រមទាំងបានពន្យល់ពីមូលហេតុនៃការជម្លៀសយ៉ាងលម្អិតទៀតផង។





លោក ផេង ពង្សរ៉ាស៊ី គឺជាអ្នកសម្របសម្រួល បានថ្លែងទៅកាន់អ្នកស្ម័គ្រចិត្តកម្ពុជាក្រុមទី៧ និងទី៨ ចំនួនជាង ២០០នាក់ មកពីខេត្តត្បូងឃ្មុំ និងខេត្តតាកែវ ដែលមកចូលរួមប្រជុំជាមួយលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា នៅសណ្ឋាគារ ហាយយ៉ាត់ ក្នុងក្រុងភ្នំពេញ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

សម្រាប់កិច្ចប្រជុំមួយព្រឹកនេះ មានក្រុមយុវជនមកពីខេត្តទាំងពីរចំនួន៥ក្រុម ក្នុងចំណោម១៥ក្រុម បានឡើងបកស្រាយអំពីប្រធានបទស្រាវជ្រាវរបស់ខ្លួន។ ក្រុមនីមួយៗដែលបានឡើងធ្វើបទបង្ហាញ បានលើកឡើងពី៖ ក) ព័ត៌មានលម្អិតពីប្រធានបទ, ខ) ចំណេះដឹងថ្មីចេញពីប្រធានបទ និងដំណើរទស្សនកិច្ចអប់រំ, គ) បញ្ហាប្រឈមក្នុងដំណើរទស្សនកិច្ច និងកិច្ចការស្រាវជ្រាវ, ឃ) សំណូមពរសម្រាប់អភិវឌ្ឍន៍ដំណើរទស្សនកិច្ចលើកក្រោយៗទៀត, ង) សេចក្ដីថ្លែងអំណរគុណរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាពិសេសលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាផ្ទាល់ ដែលបានផ្ដួចផ្ដើមឲ្យយុវជនទាំងអស់មានឱកាសរៀនសូត្របានច្រើនពីប្រវត្តិសាស្ត្រខ្មែរក្រហម។

លោក ឆាំង យុ បានផ្ដល់អនុសាសន៍ល្អ និងបានបណ្ដុះគំនិតយុវជនឲ្យចេះយកឱកាសនៃដំណើរទស្សនកិច្ចអប់រំ ដើម្បីបន្តបង្កើនជំនាញរបស់ខ្លួនបន្ថែមទៀត ទាក់ទងនឹងមុខវិជ្ជាដែលយុវជនម្នាក់ៗបាននិងកំពុងសិក្សានៅសាកលវិទ្យាល័យ។ ឧទាហរណ៍ លោកបានផ្ដល់អនុសាសន៍ដល់យុវតីម្នាក់ដែលកំពុងសិក្សាមុខវិជ្ជា «សិល្បៈម្ហូបអាហារ» ឲ្យមានគំនិតច្នៃប្រឌិតខ្ពស់ ក្នុងការអភិវឌ្ឍន៍វិជ្ជាមុខម្ហូបអាហារខ្មែរឲ្យក្លាយជាម្ហូបអាហារដែលមានលក្ខណៈជាម្ហូបខ្មែរពិតៗ និងមានការទទួលស្គាល់ពីអន្តរជាតិ។ ឧទាហរណ៍មួយទៀត៖ លោក ឆាំង យុ បានផ្ដល់អនុសាសន៍ដល់យុវជនឈ្មោះ ស៊ីន ម៉ៃយាង គឺជានិស្សិតឆ្នាំទី២ មុខជំនាញ «ភាសាវិទ្យា» និង «ដឹកនាំរបាំ» ឲ្យត្រិះរិះពិចារណាពីការរៀបចំសាច់រឿងដែលខ្លួនបានស្រាវជ្រាវ ឲ្យទៅជា «ការសម្ដែង» ឬ «ល្ខោន» ឬទម្រង់នៃសិល្បៈផ្សេងៗ ដើម្បីប្រើប្រាស់ជាមេរៀនសម្រាប់បង្កើនការចងចាំពីប្រវត្តិសាស្ត្រខ្មែរក្រហម។

ភ្ជាប់ជាមួយនឹងអនុសាសន៍នេះ លោក ឆាំង យុ បានឲ្យក្រុមបច្ចេកទេសចាក់បញ្ចាំងល្ខោននិយាយមានចំណងជើងថា «ទម្លាយភាពស្ងៀមស្ងាត់» រយៈពេល៩នាទី ដល់ម៉ែយាង និងយុវជនទាំងអស់បានទស្សនា ដើម្បីបង្ហាញពីទម្រង់នៃការប្រើប្រាស់សាច់រឿងរបស់អ្នករស់រានមានជីវិតតាមបែបសិល្បៈ។

បន្ទាប់ពីការធ្វើបទបង្ហាញតាមក្រុមរួចមក អង្គពិធីទាំងមូលបានផ្តល់ពេលវេលាខ្លះសម្រាប់យុវជនក្នុងការបញ្ចេញមតិ និងសួរសំណួរ។ អ្នកស្ម័គ្រចិត្តម្នាក់មកពីខេត្តត្បូងឃ្មុំបានងើបឈរឡើងហើយនិយាយថា ខ្លួនបានទទួលសារ (ការផ្តាំផ្ញើ) មួយពីអ្នករស់រានមានជីវិតម្នាក់រស់នៅក្បែរទីតាំងសម្លាប់ទួលពោធិ៍ជ្រៃថា ឲ្យយុវជនទាំងអស់ត្រូវតែរៀនសូត្រ និងចងចាំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងលើកទឹកចិត្តឲ្យយុវជនកុំឆាប់ជឿលើការញុះញង់ ឬការអូសទាញពីអ្នកដទៃ ព្រោះវាជាហេតុដែលនាំឲ្យកើតមានអំពើប្រល័យពូជសាសន៍នាពេលអនាគត។ យុវតីរូបនោះក៏បានធ្វើការប្រៀបធៀបពីការសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ និងនៅការដ្ឋានលើកទំនប់អាងត្រពាំងថ្ម ថាមានភាពខុសប្លែកពីគ្នា ប៉ុន្តែវាបង្ហាញពីភាពឃោរឃៅរបស់ខ្មែរក្រហមដូចគ្នា។

ចុងបញ្ចប់នៃកម្មវិធី យុវតីម្នាក់ទៀតបានឡើងច្រៀងចម្រៀង «នាវាលាផែ» យ៉ាងពិរោះដល់អង្គពិធីទាំងមូលស្តាប់ និងថតរូបជុំគ្នា មុននឹងយុវជនទាំងអស់ចាកចេញពីបន្ទប់ប្រជុំ ដើម្បីហូបអាហារថ្ងៃត្រង់ និងឆ្ពោះទៅកាន់គោលដៅរៀងខ្លួន។





អ្នកស្ម័គ្រចិត្តកម្ពុជាក្រុមទី៧ និងទី៨ ចំនួនជាង២០០នាក់ មកពីខេត្តត្បូងឃ្មុំ និងខេត្តតាកែវ ប្រជុំជាមួយលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា នៅសណ្ឋាគារ ហាយយ៉ាត់ ក្នុងក្រុងភ្នំពេញ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ជាវ ង៉ុយ ៖ អតីតកងចល័ត

ស៊ុយ សុខមាន



ជាវ ង៉ុយ អាយុ៦៧ឆ្នាំ គឺជាកសិករ បច្ចុប្បន្នរស់នៅក្នុងភូមិព្រែក១ ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ជាវ ង៉ុយ ភេទប្រុស អាយុ៦៧ឆ្នាំ គឺជាកសិករ កើតនៅក្នុងភូមិទួលគ្រួស ឃុំស្រែតាំងយ៉ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ បច្ចុប្បន្នខ្ញុំរស់នៅក្នុងភូមិព្រែក១ ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ ខ្ញុំមានឪពុកឈ្មោះ គ្រួច ជាវ និងម្តាយឈ្មោះ ធូ សែន។ ឪពុកម្តាយខ្ញុំបានស្លាប់នៅក្នុងសម័យសង្គមរាស្ត្រនិយមដោយសារជំងឺ។ ខ្ញុំមានបងប្អូនចំនួន៤នាក់ គឺប្រុស២នាក់ និងស្រី២នាក់។ បងប្អូនរបស់ខ្ញុំបានស្លាប់អស់ហើយនៅរស់តែខ្ញុំម្នាក់ប៉ុណ្ណោះ។ ខ្ញុំបានរៀបការប្រពន្ធឈ្មោះ លី ខូយ នៅក្នុងឆ្នាំ១៩៨៦។ ក្រោយរៀបការយើងមានកូនចំនួន៦នាក់ ក្នុងនោះមានកូនប្រុស៣នាក់ និងស្រី៣នាក់។

កាលពីសម័យសង្គមរាស្ត្រនិយម ខ្ញុំនៅកុមារ និងបានចូលរៀនអក្សរនៅសាលាក្នុងភូមិ ប៉ុន្តែខ្ញុំមិនបានចាំឈ្មោះសាលានោះទេ។ កាលនោះខ្ញុំរៀនបានត្រឹមថ្នាក់ទី១២ (សង្គមចាស់) ក៏ឈប់រៀន។ ខ្ញុំបានរស់នៅជាមួយបងស្រី ក្រោយពេលដែលឪពុកម្តាយខ្ញុំស្លាប់។ នៅឆ្នាំ១៩៧០ ខ្ញុំរស់នៅភូមិទួលគ្រួសដដែល ហើយក៏ឃើញទាហាន លន់ នល់ ចូលមកបោះទីតាំងនៅក្នុងភូមិរបស់ខ្ញុំដែរ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមទទួលជ័យជម្នះលើរបប លន់ នល់ និងបានគ្រប់គ្រងប្រទេសទាំងស្រុង។ ដំបូងខ្មែរក្រហមមិនបានធ្វើបាបប្រជាជនភ្លាមៗទេ គឺក្រោយមកទើបខ្មែរក្រហមចាប់ផ្តើមតឹងរ៉ឹងបន្តិចម្តងៗ។ ខ្មែរក្រហមក៏មិនទាន់បំបែកខ្ញុំចេញពីគ្រួសារដែរ ចំណែករបបអាហារខ្ញុំហូបគ្រប់គ្រាន់។

លុះដល់ឆ្នាំ១៩៧៦ ខ្មែរក្រហមបានចាត់តាំងខ្ញុំចូលក្នុងកងចល័ត និងបញ្ជូនទៅលើកទំនប់ប្រឡាយស្ថិតនៅដំណាក់ឈើក្រំ។ ខ្មែរក្រហមបង្ខំខ្ញុំឲ្យងើបតាំងពីម៉ោង៣ព្រឹក ហើយចាប់ផ្តើមធ្វើការនៅម៉ោង៤ព្រឹក ដោយកំណត់ឲ្យជីកដីឲ្យបាន៣ម៉ែត្រគុបម្នាក់ ទើបឲ្យសម្រាកហូបបបរលាយដំឡូងមី។

នៅឆ្នាំ១៩៧៧ ខ្មែរក្រហមបានជម្លៀសខ្ញុំឲ្យទៅរស់នៅភូមិតាំងលួច ឃុំតាំងលួច ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ ចំណែកការងារដែលអង្គការចាត់តាំងឲ្យធ្វើគឺលើកទំនប់ ជីកប្រឡាយដដែល។ ការហូបចុក គឺខ្ញុំទទួលបានតែបបរម្នាក់មួយវែកតែប៉ុណ្ណោះ។ នៅឆ្នាំ១៩៧៨ ខ្ញុំបានរត់ចូលក្នុងព្រៃស្ថិតនៅភូមិរវៀង ព្រោះខ្លាចយោធាខ្មែរក្រហមនាំរត់ឡើងភ្នំ។ ពេលខ្ញុំរស់នៅក្នុងព្រៃ ខ្ញុំត្រូវដើរជីកដំឡូងជ្រៅដើម្បីហូបចម្អែតក្រពះ។ ខ្ញុំរស់នៅក្នុងព្រៃរយៈពេល២ខែ ទើបត្រឡប់មករស់នៅក្នុងភូមិវិញនៅក្នុងឆ្នាំ១៩៧៩។

# ផាក់ ញឹប ៖ អតីតកងកុមារក្នុងរបបខ្មែរក្រហម

## វេង សម្ភស្ស



ផាក់ ញឹប អាយុ៥៥ឆ្នាំ បច្ចុប្បន្នរស់នៅភូមិស្រែពពាយ ឃុំសន្ទ្រែ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ផាក់ ញឹប ភេទស្រី អាយុ៥៥ឆ្នាំ គឺជាកសិករ និងមានស្រុកកំណើតនៅភូមិជីរៀងចាស់ ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ។ បច្ចុប្បន្នខ្ញុំរស់នៅភូមិស្រែពពាយ ឃុំសន្ទ្រែ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ ខ្ញុំមានឪពុកឈ្មោះ សៀង សុទ្ធ និងម្តាយឈ្មោះ មេត ពៅ (ឪពុកម្តាយរបស់ខ្ញុំបានបាត់បង់ជីវិតក្នុងរបបខ្មែរក្រហម)។ ខ្ញុំមានបងប្អូនចំនួន៤នាក់ ក្នុងនោះមានស្រីចំនួនម្នាក់ និង ប្រុសចំនួន៣នាក់។ ខ្ញុំមានប្តីឈ្មោះ ដាន់ ម៉ៅ សព្វថ្ងៃអាយុ៦៣ឆ្នាំ ប្រកបរបរជាកសិករ។ ខ្ញុំមានកូនស្រីចំនួន២នាក់។

កាលពីកុមារភាពខ្ញុំមិនបានរៀនសូត្រទេ ពីព្រោះគ្រួសាររបស់ខ្ញុំមានជីវភាពខ្វះខាត នឹង ត្រូវមើលថែជីដូនចាស់ស្ថិតនៅភូមិជីរៀងចាស់ ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ។ ចំណែកអាហារហូបចុកវិញមិនសូវជាគ្រប់គ្រាន់ប៉ុន្មានទេ។ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ លន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ខ្ញុំរស់នៅខេត្តកំពង់ស្ពឺជាមួយយាយដដែល មិនបានផ្លាស់ប្តូរទីលំនៅទេ ទោះជាមានយន្តហោះទម្លាក់គ្រាប់បែកពីសំណាក់កងទ័ព លន់ នល់ ក៏ដោយ។

រហូតមកដល់ឆ្នាំ១៩៧៥ ក្រោយខ្មែរក្រហមបានទទួលជ័យជម្នះលើរបបសាធារណរដ្ឋខ្មែរ លន់ នល់ ខ្មែរក្រហមក៏ចាប់ផ្តើមបង្កើតសហករណ៍ ប្រមូលទ្រព្យសម្បត្តិរបស់របរប្រជាជនដាក់រួមគ្នាទាំងអស់។ ខ្មែរក្រហមកំណត់ឲ្យប្រជាជនទាំងអស់ស្លៀកពាក់ខ្មៅ។ ហេតុនេះក្រណាត់សដែលអង្គការចែកឲ្យអ្នកភូមិ គឺត្រូវយកទៅជ្រលក់ផ្លែមក្លឿឲ្យទៅជាខ្មៅ។ ចាប់ពីឆ្នាំ១៩៧៦ ដល់ ឆ្នាំ១៩៧៨ ខ្មែរក្រហមបានរឹតបន្តឹងកាន់តែខ្លាំងចំពោះការរស់នៅក្នុងភូមិរបស់ខ្ញុំ។ ខ្មែរក្រហមចាត់តាំងខ្ញុំចូលក្នុងកងកុមារ និងត្រូវធ្វើការដូចជា រែកដី និងកាប់ទន្ទ្រានខែត្រធ្វើជាជីសម្រាប់ដាក់ស្រែ។ ខ្ញុំខំធ្វើការជូនអង្គការណាស់ តែអង្គការផ្តល់របបអាហារមកខ្ញុំវិញត្រឹម ក្តិបចេក ក្តិបល្ហុង និង កន្ទក់លីង។ ខ្ញុំធ្វើការបែបនេះរហូតមកដល់ឆ្នាំ១៩៧៩ ពេលកងទ័ពវៀតណាមចូលមករំដោះប្រទេសកម្ពុជា យាយរបស់ខ្ញុំក៏មកទទួលខ្ញុំពីកងកុមារត្រឡប់ទៅភូមិកំណើតវិញ។ ប៉ុន្តែខ្ញុំមិនបានជួបជាមួយបងប្អូនរបស់ខ្ញុំទេ រហូតដល់ឆ្នាំ១៩៩០ ទើបខ្ញុំបានជួបជុំគ្នា។

# សុខ សារឿន ៖ បងប្អូនរបស់ខ្ញុំស្លាប់ដោយសារអត់អាហារ

**ស៊ុយ សុខមាន**



សុខ សារឿន អាយុ៦២ឆ្នាំ គឺជាកសិករ កើតនៅភូមិទួលគ្រួស ឃុំតាំងយ៉ៃ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ បច្ចុប្បន្នគាត់រស់នៅភូមិព្រែក១ ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ សុខ សារឿន ភេទស្រី អាយុ៦២ឆ្នាំ គឺជាកសិករ កើតនៅភូមិទួលគ្រួស ឃុំតាំងយ៉ៃ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ បច្ចុប្បន្នខ្ញុំរស់នៅភូមិព្រែក១ ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ ខ្ញុំមានឪពុកឈ្មោះ សុខ (ស្លាប់) និងម្ដាយឈ្មោះ រ៉ែន (ស្លាប់)។ ខ្ញុំមានបងប្អូនចំនួន៥នាក់ ក្នុងនោះមានស្រីចំនួន២នាក់ និងប្រុសចំនួន៣នាក់។ ខ្ញុំបានរៀបការប្ដីឈ្មោះ សៅ អូ។ ក្រោយរៀបការយើងមានកូនចំនួន៤នាក់ គឺកូនប្រុសម្នាក់ និងកូនស្រីចំនួន៣នាក់។

កាលនៅវ័យកុមារ ខ្ញុំមិនបានរៀនសូត្រទេ ព្រោះនៅក្នុងភូមិរបស់ខ្ញុំមិនមានសាលារៀន ។ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ លន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ។ ក្រោយមក ក៏មានការទម្លាក់គ្រាប់បែកយ៉ាងខ្លាំងមកលើភូមិរបស់ខ្ញុំ ហើយពេលទម្លាក់មកម្ដងៗគ្រួសាររបស់ខ្ញុំតែងតែនាំគ្នារត់គេចទៅសម្ងំលាក់ខ្លួននៅក្នុងត្រង់សេដែលជីកនៅក្បែរៗផ្ទះ។ ចំពោះអាហារហូបចុកពេលនោះមិនទាន់មានការខ្វះខាតទេ គឺអ្នកភូមិអាចដាំបាយ និងធ្វើម្ហូបហូបនៅតាមផ្ទះរៀងៗខ្លួន។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានគ្រប់គ្រងប្រទេសទាំងស្រុង។ បន្ទាប់មក ខ្មែរក្រហមបានបិទសិទ្ធិសេរីភាពប្រជាជនទាំងអស់ ហើយចាត់ប្រជាជនឲ្យធ្វើការងាររួម ហូបរួម និងមិនអនុញ្ញាតឲ្យមានទ្រព្យសម្បត្តិឯកជនឡើយ។ ចំណែកអាហារហូបចុក គឺមិនមានគ្រប់គ្រាន់ឡើយ។ ខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យចូលក្នុងកងចល័ត និងត្រូវរែកដី លើកភ្លឺស្រែ ធ្វើជីដាក់ស្រែ ហើយបន្ទាប់មកបានបញ្ជូនខ្ញុំឲ្យទៅលើកទំនប់នៅសាច់ពូក និងដំណាក់ឈើក្រំ។ ខ្ញុំធ្លាប់ទៅលើកថ្មនៅឈើតោកដើម្បីយកទៅចាក់លុបស្ទឹងទាំងមូល ក្រោមការបញ្ជាពីមេកងខ្មែរក្រហម។ ប្រជាជនណាដែលខ្ជិល និងធ្វើខុសវិន័យ មេកងបានដាក់ទោស និងធ្វើទារុណកម្ម។ ទារុណកម្មសម័យនេះមានពីរប្រភេទ គឺស្រាល និងធ្ងន់។

នៅដើមឆ្នាំ១៩៧៩ ពេលកងទ័ពវៀតណាមវាយចូលមក ខ្ញុំបានរត់គេចខ្លួនទៅរស់នៅក្នុងព្រៃអស់រយៈពេលមួយឆ្នាំ ព្រោះខ្លាចកងទ័ពវៀតណាមសម្លាប់។ ពេលរស់នៅក្នុងព្រៃ ខ្ញុំគ្មានអង្ករ និងអាហារហូបចុកគ្រប់គ្រាន់ឡើយ ដូច្នេះខ្ញុំដើរជីកដំឡូងព្រៃយកមកហូបជំនួសបាយ។ បងប្អូនរបស់ខ្ញុំចំនួន៣នាក់បានស្លាប់ដោយសារអត់អាហារនៅពេលនោះ។ បន្ទាប់មកទើបខ្ញុំត្រឡប់មករស់នៅក្នុងភូមិវិញ។ រហូតមកដល់ឆ្នាំ១៩៩៣ ខ្ញុំបានរៀបការ ហើយរស់នៅជុំប្ដី និងកូនដោយប្រកបរបរធ្វើស្រែចម្ការរហូតមកដល់សព្វថ្ងៃ។

# ស៊ុម រិនៈ អតីតកងចល័តខ្មែរក្រហម

**វេង សម្ភស្ស**



ស៊ុម រិន អាយុ៦៨ឆ្នាំ បច្ចុប្បន្នរស់នៅក្នុងភូមិគល់ទទឹង ឃុំសន្រ្ទែ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ស៊ុម រិន អាយុ៦៨ឆ្នាំ កើតនៅខេត្តកំពង់ឆ្នាំង។ បច្ចុប្បន្នខ្ញុំរស់នៅក្នុងភូមិគល់ទទឹង ឃុំសន្រ្ទែ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ ខ្ញុំមានឪពុកឈ្មោះ ម៉ោល (ស្លាប់) និង ម្តាយឈ្មោះ អ៊ឹម សូត (ស្លាប់)។ ខ្ញុំមានបងប្អូនចំនួន៣នាក់ ក្នុងនោះមានស្រី២នាក់ ប៉ុន្តែបងប្អូនខ្ញុំបាត់បង់ជីវិតអស់ហើយ។ ខ្ញុំមានប្តីឈ្មោះ ឈិន (ស្លាប់ដោយសារជាន់មីន) ហើយក្រោយរៀបការយើងមានកូនចំនួន៩ នាក់ គឺស្រី៦នាក់ និង ប្រុសចំនួន៣នាក់។ កូនៗរបស់ខ្ញុំរៀបការមានប្តីមានប្រពន្ធអស់ហើយ។

កាលនៅវ័យកុមារ ខ្ញុំមិនបានចូលរៀនទេ ព្រោះខ្ញុំត្រូវនៅជួយឪពុកម្តាយ ឃ្វាលគោក្របី មើលថែប្អូនៗ និងធ្វើកិច្ចការផ្ទះ។ ក្រោយពេលរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ក្រុមគ្រួសាររបស់ខ្ញុំ និងអ្នកនៅក្នុងភូមិទាំងអស់បាននាំគ្នារត់ចូលព្រៃគេចពីទាហានលន់ នល់ និងគេចពីគ្រាប់ផ្លោង។ ក្រុមគ្រួសាររបស់ខ្ញុំត្រូវរស់នៅព្រៃភ្នំ និងផ្លាស់ទីលំនៅពីកន្លែងមួយទៅកន្លែងមួយទៀត។ ការហូបចុកក៏មិនបានគ្រប់គ្រាន់ដែរ គឺអង្ករមួយកំប៉ុងសម្រាប់មនុស្ស១០នាក់ ហេតុនេះយើងត្រូវដាំលាយជាមួយទំពាំង។

ចន្លោះពីឆ្នាំ១៩៧១ ដល់ឆ្នាំ ១៩៧២ មានយន្តហោះទម្លាក់គ្រាប់បែកណាប៉ាល់ មកលើព្រៃដែលក្រុមគ្រួសារខ្ញុំលាក់ខ្លួន។ នៅឆ្នាំ១៩៧៣ ខ្ញុំផ្លាស់មករស់នៅត្រពាំងព្រីងវិញ ហើយក៏ជាពេលដែលគ្រួសារខ្ញុំអស់អង្ករ ហើយប្តូរទម្លាប់មកហូបក្តួចប្រចាំថ្ងៃ។ ខ្ញុំចាប់ផ្តើមស្គាល់ក្រុមខ្មែរក្រហម ហើយខ្មែរក្រហមបានប្រើខ្ញុំឲ្យកាប់ឆ្ការព្រៃ និងគាស់គល់ឈើធំៗ។ នៅឆ្នាំ១៩៧៤ ខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យទៅរស់នៅភូមិផ្សេងទៀត។

មកដល់ឆ្នាំ១៩៧៥ ខ្មែរក្រហមទទួលបានជ័យជម្នះទាំងស្រុងលើរបប លន់ នល់ ហើយខ្មែរក្រហមក៏ចាប់ផ្តើមជម្លៀសខ្ញុំចេញពីភូមិ។ ដំបូង ខ្មែរក្រហមបែកក្រណាត់ពណ៌សឲ្យខ្ញុំ ហើយខ្ញុំក៏យកទៅជាន់នឹងភក់ឲ្យប្រែមកពណ៌ខ្មៅវិញ។ បន្ទាប់មកខ្មែរក្រហមបានប្រើខ្ញុំឲ្យទៅស្ទូង និងកាប់ដើមឈើធំៗ។ ខ្ញុំត្រូវធ្វើការទាំងថ្ងៃទាំងយប់។

នៅឆ្នាំ១៩៧៦ខ្មែរក្រហមបានប្រើខ្ញុំឲ្យទៅសែងសពកងទ័ពខ្មែរក្រហមដែលវាយប្រយុទ្ធគ្នានៅបំណាក់។ បន្ទាប់មក ខ្មែរក្រហមបានឲ្យខ្ញុំយកបាយទៅឲ្យកងទ័ពនៅតាមលេណដ្ឋាន។ ក្រៅពីនោះ

ខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យធ្វើការងារផ្សេងៗទៀត ដូចជា ដេរខោអាវ ត្បាញក្រមាឲ្យកងទ័ព និងដាំថ្នាំជក់ និងដាំខ្ទឹមៗ

នៅចន្លោះពីឆ្នាំ១៩៧៧ ដល់ ឆ្នាំ១៩៧៨ ខ្ញុំភៀសខ្លួនទៅរស់នៅក្នុងព្រៃភ្នំ ហើយការហូបចុកគឺលំបាកខ្លាំងណាស់ៗ រហូតដល់ឆ្នាំ១៩៧៩ ពេលកងទ័ពវៀតណាមវាយចូលមក ទើបខ្ញុំនាំគ្នាវិលត្រឡប់មកភូមិស្រុកវិញ ប៉ុន្តែយើងមិនទាន់មានអង្ករហូបគ្រប់គ្រាន់នៅឡើយៗ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំភ្លាម ការរស់នៅមិនងាយស្រួលនោះទេ ព្រោះប្តីរបស់ខ្ញុំត្រូវឡើងដើមត្នោតដើម្បីយកទឹកត្នោតទៅដូរយកអង្ករពីកងទ័ពវៀតណាមៗ ក្រោយមកទើបប្រជាជនធ្វើស្រែរួមគ្នា ឬហៅថាប្រវាស់ដៃៗ នៅទសវត្សរ៍ឆ្នាំ១៩៩០ រដ្ឋអំណាចបានចែកដីឲ្យខ្ញុំធ្វើស្រែដើម្បីចិញ្ចឹមជីវិតរហូតមកដល់សព្វថ្ងៃៗ



ផ្លូវភ្នំនៅស្រុកវាលវែង ជាប់នឹងស្រុកក្រវាញ ខេត្តពោធិ៍សាត់ៗ
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ផ្លូវលំនៅក្នុងស្រុកវាលវែង ជាប់នឹងស្រុកក្រវាញ ខេត្តពោធិ៍សាត់ៗ
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# ស៊ុម ហួន ៖ ឪពុកខ្ញុំធ្វើម្ហូប មាន់ ទា ទទួលខ្មែរក្រហមទើបរួចផុតពីការចាប់ខ្លួន

**ម៉ាប់ ស៊ីណា**



ស៊ុម ហួន អាយុ៥៩ឆ្នាំ បច្ចុប្បន្នរស់នៅភូមិជ្រៃ ឃុំត្រមូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ស៊ុម ហួន អាយុ៥៩ឆ្នាំ កើតនៅភូមិជ្រៃ ឃុំត្រមូង ស្រុកមេមត់ ខេត្តកំពង់ចាម។ បច្ចុប្បន្នខ្ញុំរស់នៅភូមិឃុំដដែល។ ខ្ញុំមានប្តីឈ្មោះ នឹម ឆាន អាយុ៥៨ឆ្នាំ និងមានកូនចំនួន៦នាក់។ កាលពីក្មេងខ្ញុំបានរៀនតិចតួចតែប៉ុណ្ណោះ។ ខ្ញុំចូលរៀនពេលព្រឹក ហើយពេលថ្ងៃខ្ញុំទៅឃ្វាលគោក្របី។ គ្រូបង្រៀនរបស់ខ្ញុំឈ្មោះ ដើង ហើយគាត់កាចណាស់ ប៉ុន្តែឥឡូវគាត់បានស្លាប់ហើយ។ ពេលខ្ញុំរៀនគឺមានសិស្សតែ១០នាក់តែប៉ុណ្ណោះ ហើយសិស្សជាច្រើនរៀនបេះចាំ ដោយឡែកតែខ្ញុំរៀនខ្សោយ។ ខ្ញុំរៀនបណ្តើរធ្វើការងារបណ្តើរ ដូច្នេះមិនសូវបានរៀនសូត្រជាប់លាប់ទេ។ គ្រូបង្រៀនមិនមកពីណាឆ្ងាយទេ គឺរស់នៅក្នុងភូមិតែម្តង។ កាលនោះប្រជាជនធ្វើការងារប្រវាស់ដៃ ប៉ុន្តែនៅ ហូបបាយរៀងៗខ្លួននៅឡើយ។

ខ្ញុំនៅចាំបានថា នៅក្នុងភូមិមានការទម្លាក់គ្រាប់បែក ប៉ុន្តែខ្ញុំមិនចាំច្បាស់លាស់ថានៅឆ្នាំណាទេ ព្រោះខ្ញុំមានអាយុទើបតែ៧ឆ្នាំប៉ុណ្ណោះ។ ខ្ញុំដឹងត្រឹមថា អំឡុងពេលទម្លាក់គ្រាប់បែក គឺមានប្រជាជនស្លាប់ច្រើនណាស់។ ការទម្លាក់គ្រាប់បែកនោះគឺនៅវេលាប្រហែលម៉ោង២រសៀល ព្រោះខ្ញុំបានហូបបាយថ្ងៃត្រង់រួចហើយ ហើយខ្ញុំក៏ដើរទៅលេងផ្ទះបងប្អូនជីដូនមួយដែលស្ថិតនៅជិតផ្ទះរបស់ខ្ញុំ។ ខ្ញុំនិងបងប្អូនជីដូនមួយរបស់ខ្ញុំជារឿយៗលេងជាមួយគ្នា ប៉ុន្តែតែងតែដណ្តើមរបស់របរគ្នាលេង ហើយមិនសូវត្រូវគ្នាទេ។ ខ្ញុំបាននិយាយទៅកាន់បងប្អូនជីដូនមួយរបស់ខ្ញុំថា បើលេងដណ្តើមរបស់របរខ្ញុំដូច្នេះ គឺខ្ញុំទៅផ្ទះខ្ញុំវិញហើយ ហើយបន្ទាប់ពីខ្ញុំនិយាយរួចក៏ដើរត្រឡប់មកផ្ទះរបស់ខ្ញុំវិញ ស្រាប់តែមានយន្តហោះមកទម្លាក់គ្រាប់គ្រាំងៗតែម្តង។ ខ្ញុំមិនបានរត់ចូលរណ្តៅត្រង់សេ ឬលេណដ្ឋានទេ គឺខ្ញុំស្ថិតនៅលើផ្ទះតែម្នាក់ឯង ចំណែកឪពុកម្តាយ បងប្អូនខ្ញុំ នាំគ្នារត់ចូលរណ្តៅត្រង់សេអស់ហើយ។

កាលជំនាន់នោះ ឪពុកខ្ញុំឈ្មោះ ស៊ុម ធ្លាប់ធ្វើជាគ្រូបង្រៀន ប៉ុន្តែពេលខ្មែរក្រហមចូលមកឪពុកខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឲ្យធ្វើជាប្រធានកងតូចៗ ឪពុកខ្ញុំធ្វើជាប្រធានកងតូចពិតមែន ប៉ុន្តែឪពុកខ្ញុំមិនកោងកាចទេ គឺគាត់ស្លូតណាស់។ ទោះបីទាហានខ្មែរក្រហមមកពីខាងណាក៏ឪពុកខ្ញុំឲ្យហូបចុកដែរ។ ឪពុកខ្ញុំតែងតែនិយាយថា «ឲ្យគាត់ធ្វើបាបមនុស្សយ៉ាងដូចម្តេច បើយើងហូបតែបបរដូចគ្នា ណាមួយប្រជាជនក្នុងភូមិសុទ្ធតែកូនក្មួយឯងទៀត ប្រសិនបើយើងស្លាប់គឺស្លាប់ទាំងអស់គ្នា»។ ឪពុករបស់ខ្ញុំទៅនៅភូមិស្រុកផ្សេង

ក៏ប្រជាជននៅទីនោះធ្វើតែអំពើល្អជាមួយគាត់ និងស្រឡាញ់ចូលចិត្តគាត់ គឺគ្មាននរណាធ្វើបាបគាត់ទេ ដោយសារតែគាត់មិនបានធ្វើបាបអ្នកដទៃ។

ពេលមានការទម្លាក់គ្រាប់កាន់តែខ្លាំងនៅក្នុងភូមិ ខ្ញុំរត់គេចខ្លួនទៅដល់ភូមិសំពោច និងភូមិស្រែរនាម ឃុំយ្ងឹម ស្រុកស្អួល ខេត្តក្រចេះ។ ខ្ញុំរស់នៅទីនោះរយៈពេលមួយឆ្នាំ ដោយធ្វើការងារដកស្ទូង និងបោចស្មៅនៅវាលស្រែ ប៉ុន្តែខ្ញុំគ្មានអាហារហូបគ្រប់គ្រាន់ឡើយ។

មួយរយៈក្រោយមក ខ្មែរក្រហមជម្លៀសខ្ញុំឲ្យទៅរស់នៅភូមិផ្សេងទៀត ហើយប្រជាជននៅទីនោះចិត្តល្អណាស់។ ខ្ញុំនៅធ្វើស្រែ ដកស្ទូង បោចស្មៅតាមគុម្ពស្រូវដដែល។ ខ្ញុំធ្វើការច្រើនម៉ោងណាស់ក្នុងមួយថ្ងៃចំណែកការហូបចុកវិញគឺខ្វះខាតដដែល។ ខ្ញុំហូបតែបបរ ហើយយូរៗម្តងទើបបានហូបបាយ។ ខ្ញុំត្រូវខ្មែរក្រហមឲ្យទៅនៅកងកុមារ ត្រូវធ្វើការងាររែកដីលើកទំនប់ និងធ្វើការងារធ្ងន់ផ្សេងៗទៀត ដែលខ្ញុំមិនធ្លាប់ធ្វើពីមុនមក។ ខ្ញុំនៅតូចមែន ប៉ុន្តែខ្ញុំហ៊ានណាស់គឺពេលនោះដោយសារខ្ញុំអាណិតយាយរបស់ខ្ញុំខ្លាំងពេក ខ្ញុំក៏បានលួចយករបបអាហាររបស់ខ្ញុំទៅឲ្យយាយរបស់ខ្ញុំដែលរស់នៅស្រែរនាម ព្រោះយាយរបស់ខ្ញុំហូបបបរមិនបាន។ ថ្ងៃមួយ ខ្ញុំបានសម្រេចចិត្តទៅសុំពោតចំនួន៣ផ្លែពីយោធាខ្មែរក្រហម ដោយមុនទៅសុំខ្ញុំបានលើកដៃសំពះសុំទេវតាឲ្យជួយតាមថែរក្សាខ្ញុំ និងសុំពោតឲ្យបាន។ ពេលខ្ញុំទៅដល់យោធាខ្មែរក្រហមបានប្រាប់ខ្ញុំថា ចាំស្វាត់មនុស្សចាំមកយកពោត។ ខ្ញុំសុំយោធាខ្មែរក្រហមតែ៣ផ្លែប៉ុណ្ណោះ ប៉ុន្តែយោធាខ្មែរក្រហមឲ្យពោតខ្ញុំរហូតដល់៦ផ្លែ។ ខ្ញុំគិតថាមានទេវតានៅចាំជួយខ្ញុំ។ បន្ទាប់មក ខ្ញុំក៏យកពោតនោះមកឲ្យយាយរបស់ខ្ញុំ ប៉ុន្តែទោះបីជាយ៉ាងណាក៏មិនអាចជួយយាយរបស់ខ្ញុំដែលស្រេកឃ្លានបានដែរ គឺគាត់បានស្លាប់ក្រោយមក។

ខ្ញុំមានបងជីដូនមួយឈ្មោះ ញ៉ែរ ត្រូវបានខ្មែរក្រហមជ្រើសរើសឲ្យចូលធ្វើជាពេទ្យទាហាន។ ឪពុករបស់ខ្ញុំបានឃើញបងញ៉ែរ នៅតាមអគ្គភាពខ្មែរក្រហម ហើយដោយសារអាណិតក្មួយ ឪពុកខ្ញុំក៏សុំខ្មែរក្រហមយកក្មួយមកផ្ទះវិញ ប៉ុន្តែខ្មែរក្រហមមិនឲ្យបងញ៉ែរមកវិញទេ ថែមទាំងបានហៅឪពុកខ្ញុំឲ្យចូលធ្វើពេទ្យជាមួយបង ញ៉ែរ ថែមទៀត។ ទោះបីឪពុកខ្ញុំមិនចេះជំនាញពេទ្យក៏ដោយ ក៏ពេលនោះខ្មែរក្រហមបញ្ជូនឪពុកខ្ញុំទៅរៀនពេទ្យដែរ។ ថ្ងៃមួយ ខ្មែរក្រហមបម្រុងយកឪពុកខ្ញុំទៅវាយសម្លាប់ចោល ព្រោះស៊ើបដឹងថាឪពុកខ្ញុំធ្លាប់ជាគ្រូបង្រៀន និងធ្វើជាមេភូមិ។ អ្នកដែលមកយកឪពុកខ្ញុំទៅសម្លាប់មានគ្នាបីនាក់ ប៉ុន្តែខ្ញុំមិនចាំឈ្មោះអ្នកទាំងនោះទេ។ ឪពុកខ្ញុំនិយាយថា គាត់មិនបានរត់គេចទៅទីណាឡើយ គឺនៅត្រៀមទទួលខ្មែរក្រហមទាំង៣នាក់នោះ យ៉ាងរាក់ទាក់ទៀតផង។ ឪពុកខ្ញុំបានធ្វើម្ហូបមាន់ទាទទួល និងរៀបចំកន្ទេលឲ្យខ្មែរក្រហមទាំង៣នាក់នោះស្នាក់នៅបានយ៉ាងសមរម្យ។ លុះព្រឹកឡើង ខ្មែរក្រហមទាំង៣នាក់នោះមិនបានយកឪពុកខ្ញុំទៅសម្លាប់ទេ ថែមទាំងនិយាយល្អដាក់ឪពុកខ្ញុំទៀតថា ប្រសិនបើមានការចោទប្រកាន់លើឪពុកខ្ញុំលើកក្រោយ សូមឲ្យឪពុកខ្ញុំរត់គេចខ្លួនខ្លះទៅ ព្រោះក្រែងលោយោធាខ្មែរក្រហមខ្លះមិនមានការអធ្យាស្រ័យដូចខ្លួន ហើយបានសរសើរឪពុកខ្ញុំថា ចិត្តល្អ ដូច្នេះមិនដាច់ចិត្តយកឪពុកខ្ញុំទៅសម្លាប់ចោលឡើយ។

ក្រោយមកខ្មែរក្រហមជម្លៀសខ្ញុំចេញពីភូមិឲ្យទៅនៅថ្មគ្រែមួយរយៈ ទើបជម្លៀសបន្តទៅនៅស្រុកស៊ីងត្រង់។ នៅដើមឆ្នាំ១៩៧៩ ពេលរបបខ្មែរក្រហមដួលរលំ ខ្ញុំបានធ្វើដំណើរមកដល់ក្រុងកំពង់ចាម ហើយក៏បានជួបជាមួយកងទ័ពវៀតណាម និងកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាដែលចូលមករំដោះប្រទេស ធ្វើឲ្យខ្ញុំសប្បាយរីករាយយ៉ាងខ្លាំង។ ខ្ញុំដើររយៈពេលប្រាំថ្ងៃទើបមកដល់ស្រុកកំណើត។ ពេលខ្ញុំមកដល់ភូមិដំបូង ខ្ញុំឃើញព្រៃដុះព័ទ្ធជុំជិត ចំណែកផ្ទះសម្បែងគឺខូចខាតគ្មានសល់ឡើយ។ ខ្ញុំនិងបងប្អូននាំគ្នាជីកដំឡូង ជីកមើមក្តួចយកមកហូប ព្រោះមិនទាន់មានស្រូវអង្ករឡើយ។ អ្នកភូមិខ្លះនាំគ្នាទៅរកស្រូវនៅស្រែរនាមដែលនៅសេសសល់ពីភ្លើងឆេះ យកមកបុកដាំបាយហូប។ ចំណែកម្តាយខ្ញុំបានយកមាសដែលនៅសេសសល់ទៅដូរស្រូវពីប្រជាជនក្នុងភូមិសាទុំ ដើម្បីយកមកទុកធ្វើពូជដាំដុះដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ។

# មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងរៀបចំ
## ទស្សនកិច្ចសិក្សាស្តីអំពីការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហមដល់អ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តឧត្តរមានជ័យ និងខេត្តសៀមរាប

សួត វិចិត្រ



អ្នកស្ម័គ្រចិត្តកម្ពុជាមកពីស្រុកអន្លង់វែង ស្រុកត្រពាំងប្រាសាទ និងក្រុងសំរោង ខេត្តឧត្តរមានជ័យ ចូលរួមដំណើរទស្សនកិច្ចសិក្សាស្តីអំពីការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម ពីថ្ងៃទី៤ ដល់ថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងនៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានរៀបចំដំណើរទស្សនកិច្ចសិក្សាស្តីពី «ការជម្លៀសប្រជាជនដោយបង្ខំតាមរថភ្លើង» សម្រាប់អ្នកស្ម័គ្រចិត្តកម្ពុជាចំនួន៩៩នាក់ ក្នុងនោះស្រីចំនួន៥៥នាក់ និងប្រុសចំនួន៤៤នាក់។ អ្នកចូលរួមមកពីស្រុកវ៉ារិន និងស្រុកអង្គរធំ ខេត្តសៀមរាប ព្រមទាំងមកពីក្រុងសំរោង, ស្រុកអន្លង់វែង និងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ នៅចន្លោះពីថ្ងៃទី៤ ដល់ទី៨ ខែមេសា ឆ្នាំ២០២៤។ ដំណើរទស្សនកិច្ចនេះ មានគោលបំណងលើកកម្ពស់ការអប់រំដល់យុវជនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩), រឿងរ៉ាវជីវិតរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងរំឭកដល់ជនរងគ្រោះ ដែលធ្លាប់ទទួលរងការឈឺចាប់ និងការជម្លៀសដោយបង្ខំតាមខ្សែរថភ្លើងទៅកាន់ការដ្ឋានការងារនៅក្នុងរបបខ្មែរក្រហម។ ដំណើរទស្សនកិច្ចសិក្សានេះត្រូវបានរៀបចំឡើងដោយមានការគាំទ្រពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) និងការចូលរួមពីអ្នកស្ម័គ្រចិត្តកម្ពុជា ទាំង៨ជំនាន់ដែលបានបំពេញការងាររបស់ខ្លួនចាប់ពីជំនាន់ទី១រហូតដល់ជំនាន់ទី៨ នៅតាមមូលដ្ឋាន

រៀងៗខ្លួនដើម្បីចងក្រងឯកសារ ទាក់ទងរឿងរ៉ាវជីវិតរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងប្រមែប្រមូលព័ត៌មានសុខភាពនៅក្នុងពេលបច្ចុប្បន្ន។ សៀវភៅ ស្តីពី «ការជម្លៀសប្រជាជនដោយបង្ខំនៅក្នុងរបបខ្មែរក្រហម»បានបញ្ជាក់ថា ខ្មែរក្រហមបានជម្លៀសប្រជាជនជា ៣ដំណាក់កាល ដោយរាប់ចាប់តាំងពីជ័យជម្នះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ចុងឆ្នាំ១៩៧៨។ ដំណាក់កាលចុងក្រោយនៃការជម្លៀសនេះ ខ្មែរក្រហមបានប្រើប្រាស់រថភ្លើងដើម្បីជម្លៀសខ្លួនឯងទៅកាន់ភូមិភាគពាយ័ព្យប្រទេសជាប់នឹងប្រទេសថៃក្នុងគោលបំណងរៀបចំកម្លាំងតស៊ូដណ្តើមអំណាចត្រឡប់មកវិញ។ នៅក្នុងនោះ អ្នកស្ម័គ្រចិត្តកម្ពុជាបានយកឱកាសនេះ ដើម្បីឈ្វេងយល់ពីអតីតកាលនៃភាពភ័យព្រួយ ភាពអស់សង្ឃឹម និងរឿងរ៉ាវនៅពីក្រោយភាពសុខសាន្តត្រាណក្នុងពេលបច្ចុប្បន្ននេះ។ ជាពិសេសគឺពិនិត្យមើលទៅលើទីតាំងដែលពាក់ព័ន្ធទៅនឹងបទចោទប្រកាន់ទៅលើ មេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតរបស់ខ្មែរក្រហមតាមផ្លូវតុលាការ ដូចជា ការសម្លាប់មន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ (របប លន់ នល់) នៅទួលពោធិ៍ជ្រៃ នៅក្នុងខេត្តពោធិ៍សាត់ជាដើម។ មេដឹកនាំចំនួន២រូប គឺ នួន ជា និង ខៀវ សំផន ដែលជាអ្នកទទួលខុសត្រូវនៅក្នុងការជម្លៀសប្រជាជននៅដំណាក់កាលទី១ និងទី២ ត្រូវបានតុលាការកាត់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិតពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលជាប់ទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំពីទីក្រុងភ្នំពេញ និងតំបន់ផ្សេងៗទៀតក៏ដូចជាការសម្លាប់រង្គាលទៅលើទាហាន លន់ នល់ នៅទួលពោធិ៍ជ្រៃ ដែលស្ថិតនៅក្នុងសំណុំរឿង០០២/០១។ ថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៤ គឺជាថ្ងៃដំបូងនៃដំណើរទស្សនកិច្ចសិក្សាអំពី«ការជម្លៀសប្រជាជនដោយបង្ខំតាមរថភ្លើងក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩)»។ ខាងក្រោម គឺជាការយល់ឃើញរបស់អ្នកស្ម័គ្រចិត្តកម្ពុជា៖

ខ្ញុំឈ្មោះ **សែ សាថ៉ន** អាយុ១៨ឆ្នាំ រស់នៅភូមិត្រពាំងស្វាយ ឃុំបេង ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ និងជាយុវជនស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ នៅពេលខ្ញុំធ្វើដំណើរតាមរថភ្លើង ខ្ញុំមានអារម្មណ៍រំភើបប្លែកភ្នែក ព្រោះបានឃើញទេសភាពវាលស្រែ និងរុក្ខជាតិផ្សេងៗ ព្រមទាំងបាន





អ្នកស្ម័គ្រចិត្តកម្ពុជាចំនួន៩៩នាក់ក្នុងនោះស្រីចំនួន៥៥នាក់ និងប្រុសចំនួន៤៤នាក់ មកពីស្រុកវ៉ារិន និងស្រុកអង្គរធំ ខេត្តសៀមរាប និងស្រុកអន្លង់វែង, ស្រុកត្រពាំងប្រាសាទ និងក្រុងសំរោង ខេត្តឧត្តរមានជ័យ ចូលរួមដំណើរទស្សនកិច្ចសិក្សា ស្តីអំពីការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ឃើញពីការរស់នៅរបស់ប្រជាជននៅតាមដងផ្លូវ។ ប៉ុន្តែបើក្រឡេកទៅមើលក្នុងចន្លោះពីឆ្នាំ១៩៧០ រហូតដល់ឆ្នាំ១៩៧៥ ប្រជាជនបានរត់មកជ្រកកោននៅទីក្រុងភ្នំពេញដើម្បីចៀសផុតពីសង្គ្រាមរវាងកងទ័ព លន់ នល់ និងយោធាខ្មែរក្រហម។ ក្នុងឆ្នាំ១៩៧៥ យោធាខ្មែរក្រហមបានជម្លៀសប្រជាជនដោយបង្ខំនៅទីក្រុងភ្នំពេញឲ្យទៅនៅតាមបណ្តាខេត្តនីមួយៗ។ នៅពេលនោះហើយដែលទីក្រុងភ្នំពេញបានប្រែក្លាយទៅជាទីក្រុងដែលស្ងាត់ជ្រងំគ្មានមនុស្សរស់នៅ។ បុរស ស្ត្រី គ្រប់ស្រទាប់វណ្ណៈ មនុស្សចាស់ក្មេង អ្នកជំងឺព្យាបាលនៅមន្ទីរពេទ្យ ស្ត្រីមានផ្ទៃពោះឬស្ត្រីដែលទើបសម្រាលកូនរួចត្រូវបង្ខំឲ្យចាកចេញពីទីក្រុង។ ប្រជាជនត្រូវដេកសម្រាកនៅតាមដងផ្លូវនិងក្រោមដើមឈើហើយ ហូបតែបាយបន្តិចបន្តួចៗ ដោយសារការធ្វើដំណើរផ្លូវឆ្ងាយ ប្រជាជនដែលត្រូវបានជម្លៀសបានជួបប្រទះការខ្វះខាតយ៉ាងច្រើន បណ្តាលឲ្យមានការហេវហត់ កើតជំងឺហើមដៃជើងនិងជំងឺផ្សេងៗទៀត។

ខ្ញុំឈ្មោះ **យ៉េម ស្រីមុំ** អាយុ២៣ឆ្នាំ មានទីកន្លែងកំណើតរស់នៅភូមិលាងដៃ ឃុំលាងដៃ ស្រុកអង្គរធំ ខេត្តសៀមរាប។ ការជិះរថភ្លើងថ្មីប្លែកសម្រាប់ខ្ញុំនិងជាលើកទី១ ខ្ញុំគិតថាយាយតា អ៊ំ ពូ មីង ដែលធ្លាប់ខ្មែរក្រហមជម្លៀសតាមរថភ្លើង ត្រូវបែកបាក់ពីបងប្អូនក្រុមគ្រួសារ ហើយខ្លះក៏បានវិលមកជុំគ្រួសារខ្លះក៏បាត់ខ្លួនតាំងពីសម័យខ្មែរក្រហមមកដល់បច្ចុប្បន្ន។ ត្រូវរស់នៅខ្លួនទីពឹងខ្លួន ការហូបចុកមិនគ្រប់គ្រាន់ទេ ពេលខ្លះមិនមានអាហារពីរបីថ្ងៃក៏មានដោយផឹកតែទឹកជំនួសបាយ។ ប្រជាជនត្រូវធ្វើការដោយកម្លាំង និងគ្មានសិទ្ធិតវ៉ា ចំពោះការងារដែលអង្គការរៀបចំតាមផែនការ ពេលខ្លះត្រូវធ្វើទាំងយប់និងថ្ងៃក្រោមរដូវភ្លៀងធ្លាក់។ ប្រជាជនខ្លះក៏ត្រូវស្លាប់ដោយសារជំងឺគ្រុនចាញ់ ព្រោះមិនមានថ្នាំគ្រប់គ្រាន់និងការព្យាបាលជិតដល់ជាដើម។ ខ្ញុំសូមអរគុណដល់អង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រុមការងារទាំងអស់គ្នាដែលបានរៀបចំដំណើរទស្សនកិច្ច ទាំងការធ្វើដំណើរ ការស្នាក់នៅ និងអាហារ និងបានឈ្វេងយល់បន្ថែមពីប្រវត្តិសាស្ត្រ។

ខ្ញុំឈ្មោះ **លី ថារីន** មានអាយុ១៧ឆ្នាំ មកពីវិទ្យាល័យ ហ៊ុនសែនឧត្តរមានជ័យ។ បច្ចុប្បន្ន ខ្ញុំរស់នៅភូមិអូរទង ឃុំគោកខ្ពស់ ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ។ ការធ្វើដំណើរតាមរថភ្លើងនេះ គឺជាលើកទី១សម្រាប់ខ្ញុំ ហើយក៏បានផ្តល់ជាបទពិសោធន៍ និងប្រយោជន៍ដល់ខ្ញុំក៏ដូចអ្នកសិក្សា។ ខ្ញុំស្គាល់ពីភាពលំបាក ភាពឈឺចាប់ ភាពអត់ឃ្លាន របស់លោកតាលោកយាយ និងប្រជាជនទាំងអស់ពេលខ្មែរក្រហមឡើងកាន់អំណាច។ បច្ចុប្បន្ន យើងមានអាហារហូបគ្រប់គ្រាន់ ប៉ុន្តែបើយើងក្រឡេកទៅមើលសម័យខ្មែរក្រហមឡើងកាន់កាប់ប្រទេសនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ជាថ្ងៃដែលពោរពេញទៅដោយភាពអាប់អួ ដែលប្រជាជនកម្ពុជារស់យ៉ាងលំបាកវេទនា ខ្វះស្បៀងអាហារ ខ្វះកន្លែងរស់នៅ ធ្វើការទាំងយប់ទាំងថ្ងៃ១២ម៉ោង ព្រាត់ប្រាសគ្រួសារ ឃ្លាតឆ្ងាយពីមនុស្សជាទីស្រឡាញ់។ ខ្ញុំពិតជាស្ងើចសរសើរដល់ប្រជាជនកម្ពុជា ទាំងអស់ដែលក្លាហាន តស៊ូដើម្បីជាតិមាតុភូមិ។ ការជម្លៀសប្រជាជនតាមរថភ្លើង បានផ្តល់ផលលំបាកជាច្រើនដូចជា ការខ្វះអាហារហូបចុក ទីកន្លែងស្នាក់នៅ ប្រជាជនសម្រាកបានតិច ការធ្វើដំណើរពិបាក ប្រជាជនដែលជម្លៀសបានជួបប្រទះភាពខ្វះខាត ហេវហត់អស់កម្លាំង បណ្តាលឲ្យមានជំងឺ។ ប្រជាជនរាប់ម៉ឺននាក់ត្រូវបានជម្លៀសដោយបង្ខំឲ្យចាកចេញពីទីក្រុង ប្រជាជនប្រហែល៣០០០នាក់បានស្លាប់នៅពេលជម្លៀស។ របបខ្មែរក្រហមបន្សល់ទុកនៅការចងចាំដ៏ឈឺចាប់ និងវិនាសយ៉ាងធំធេងសម្រាប់ប្រជាជនគ្រប់ស្រទាប់វណ្ណៈ។ របបខ្មែរក្រហម បន្សល់ទុកស្ត្រីមេម៉ាយ ជនពិការ និងក្មេងកំព្រា។

ខ្ញុំឈ្មោះ **សំអូន បូរ៉ានី** អាយុ១៧ឆ្នាំ បច្ចុប្បន្នរស់នៅភូមិអូរកន្សែង ឃុំសំរោង ស្រុកសំរោង ខេត្តឧត្តរមានជ័យ។ ខ្ញុំគឺជាអ្នកស្ម័គ្រចិត្តកម្ពុជា។ ពេលធ្វើដំណើរតាមរថភ្លើង ខ្ញុំមានអារម្មណ៍សប្បាយរីករាយរំភើបជាខ្លាំង និងប្លែកភ្នែក។ មិនតែប៉ុណ្ណោះ

ការជិះរថភ្លើងបានធ្វើឲ្យខ្ញុំបានបន្ធូរអារម្មណ៍នឹងស្រស់ថ្លាពីព្រោះបានស្រូបយកខ្យល់អាកាសធម្មជាតិនិងបរិសុទ្ធ ហើយបានស្គាល់ អ៊ុំ ពូ មីង បងប្អូននិងមិត្តភក្តិជាច្រើនដែលធ្វើដំណើររួមជាមួយគ្នាផងដែរ។ ពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ ប្រជាជនបានភៀសខ្លួនមកជ្រកកោននៅទីក្រុងភ្នំពេញដើម្បីជៀសផុតពីសង្គ្រាមរវាងកងទ័ព លន់ នល់ និងខ្មែរក្រហម។ ក្នុងឆ្នាំ១៩៧៥ យោធាខ្មែរក្រហមបានជម្លៀសប្រជាជនដោយបង្ខំពីទីក្រុងភ្នំពេញឲ្យទៅរស់នៅតាមបណ្តាខេត្តនីមួយៗ។ ពេលនោះទីក្រុងភ្នំពេញបានប្រែក្លាយទៅជាទីក្រុងដែលស្ងាត់ជ្រងំគ្មានមនុស្សរស់នៅ។ នៅពេលដែលខ្ញុំធ្វើដំណើរតាមរថភ្លើងខ្ញុំបានស្រមៃឃើញភាពសោកសង្រេង នៅក្នុងរបបខ្មែរក្រហម។ ខ្ញុំអាណិតប្រជាជនជាខ្លាំង ព្រោះពេលនោះប្រជាជនមិនមែនធ្វើដំណើរងាយស្រួលដូចឥឡូវនេះទេគឺត្រូវខ្មែរក្រហមជម្លៀសដោយបង្ខំហើយមិនឲ្យអាហារហូបចុកគ្រប់គ្រាន់ទៀតផង។

ខ្ញុំឈ្មោះ **គុត ហ៊ា** អាយុ២៨ឆ្នាំ មកពីភូមិត្រពាំងស្វាយ ឃុំលាងដៃ ស្រុកអង្គរធំ ខេត្តសៀមរាប។ នៅពេលជិះរថភ្លើងខ្ញុំមានអារម្មណ៍ សប្បាយរីករាយ និងបានគយគន់សម្រស់ធម្មជាតិ និងសោភ័ណ្ឌភាព។ ខ្ញុំទទួលបានចំណេះដឹងផ្ទាល់ខ្លួន និងបទពិសោធន៍ផ្សេងៗ។ ខ្ញុំរីករាយព្រោះបានស្គាល់មិត្តភក្តិតាមបណ្តាខេត្ត។ ខ្ញុំសប្បាយចិត្តនៅពេលបានចូលទស្សនាព្រះរាជបណ្ណាល័យ ហ្លួងម៉ែ ដែលមានឯកសារខ្មែរក្រហមជាច្រើនពីឆ្នាំ១៩៧៥-១៩៧៩ និងឯកសារផ្សេងៗទៀត។ ចំពោះយាយតាដែលធ្លាប់ខ្មែរក្រហមជម្លៀសតាមរថភ្លើងគឺជួបការលំបាកជាច្រើនដូចជា៖ ការបែកបាក់និងព្រាត់ប្រាសក្រុមគ្រួសារ, គ្មានផ្ទះសម្បែងរស់នៅសមរម្យ, បាត់បង់មិត្តភាព ,មានជំងឺឈឺថ្កាត់គ្មានមន្ទីរពេទ្យព្យាបាល ,ការបរិភោគអាហារមានការខ្វះខាត, ការរស់នៅជួបទុក្ខលំបាកនិងវេទនា និងជួបគ្រោះទុរ្ភិក្ស។

ខ្ញុំឈ្មោះ **គុន សុនីសា** អាយុ១៧ឆ្នាំ មកពីវិទ្យាល័យតេជោសែនសំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ។ នៅក្នុងដំណើរតាមរថភ្លើងពីរាជធានីភ្នំពេញទៅកាន់ក្រុងសិរីសោភ័ណ ខ្ញុំមានអារម្មណ៍ប្លែកនិងទទួលបានចំណេះដឹងថ្មីៗជាច្រើន។ ថ្វីត្បិតតែមានសំឡេងស៊ីផ្លេរថភ្លើងថ្លង់ពិតមែនតែខ្ញុំសប្បាយចិត្ត ព្រោះបានឃើញព្រៃព្រឹក្សា បានរាប់អានមិត្ត និងសិស្សច្បង និងទទួលបានបទពិសោធន៍ថ្មីៗដើម្បីឲ្យការធ្វើដំណើរនាពេលក្រោយៗទៀតបានដោយរលូន។ ខ្ញុំមានភាពស្រស់ស្រាយក្នុងចិត្តបំបាត់នូវទុក្ខកង្វល់ទាំងឡាយ កាត់បន្ថយភាពស្ត្រេស និងដឹងពីរឿងរ៉ាវផ្សេងៗពីដំណើរតាមរថភ្លើងនេះ។ លោកយាយ លោកតា អ៊ុំ ពូ មីង នៅតាមភូមិស្រុកស្រែចម្ការ និងប្អូនៗសិស្សានុសិស្សបានស្វាគមន៍ដំណើរទស្សនកិច្ចសិក្សានេះ។

ខ្ញុំឈ្មោះ **រ័ន្ធ ប៊ុនយិន** អាយុ១៧ឆ្នាំ រស់នៅស្រុកសំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ។ ខ្ញុំមកពីវិទ្យាល័យតេជោសែនសំរោង។ នៅវេលាម៉ោង៧កន្លះ ខ្ញុំចេញពីទីក្រុងភ្នំពេញឆ្ពោះទៅក្រុងសិរី-សោភ័ណ ខេត្តបន្ទាយមានជ័យ ដោយធ្វើដំណើរតាមរថភ្លើង ដែលមានលេខសម្គាល់១០៣៨។ ការធ្វើដំណើរតាមរថភ្លើងនេះ ខ្ញុំទទួលបាននូវអារម្មណ៍ប្លែកព្រមទាំងបទពិសោធថ្មីៗ។ តែទោះបីជាយ៉ាងនេះក្តី ការធ្វើដំណើរតាមរថភ្លើងនាពេលបច្ចុប្បន្ននេះខុសគ្នាយ៉ាងខ្លាំងពីការធ្វើដំណើរតាមរថភ្លើងកាលពី៤៤ឆ្នាំមុន។ ពិតណាស់បើយើងក្រឡេកទៅកាលពី៤៤ឆ្នាំមុន ការធ្វើដំណើរតាមរថភ្លើង ហាក់បីដូចជាផ្ទុយស្រឡះពីពេលបច្ចុប្បន្ន។ នាពេលនោះ (៤៤ឆ្នាំមុន) មិនមែនជាការជិះរថភ្លើងទៅតាមស្រុកភូមិ ឬគោលដៅរបស់ខ្លួននោះឡើយ គឺមានតែការជម្លៀសដោយបង្ខំចេញពីទីក្រុងភ្នំពេញតាមរថភ្លើង ទូកកាណូត ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម។ ស្របគ្នានេះដែរ ខ្មែរក្រហមបានបង្អត់អាហារ និងបានបំបែកបំបាក់ប្រជាជនឲ្យរស់នៅដាច់ពីគ្នា។ ការធ្វើដំណើរតាមរថភ្លើងនៅពេលនោះ មានអ្នក



*អ្នកស្ម័គ្រចិត្តកម្ពុជាចំនួន៩៩នាក់ក្នុងនោះស្រីចំនួន៥៥នាក់ និងប្រុសចំនួន៤៤នាក់ មកពីស្រុកវ៉ារិន និងស្រុកអង្គរធំ ខេត្តសៀមរាប និងស្រុកអន្លង់វែង, ស្រុកត្រពាំងប្រាសាទ និងក្រុងសំរោង ខេត្តឧត្តរមានជ័យ ចូលរួមដំណើរទស្សនកិច្ចសិក្សាស្តីអំពីការជម្លៀសដោយបង្ខំក្នុងរបបខ្មែរក្រហម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

អង្គុយ មានអ្នកឈររាប់រយអ្នក ហាក់បីដូចជាគុកសម្រាប់ឃាំងមនុស្ស។ ក្រោយពីខ្ញុំសរសេរចំណាប់អារម្មណ៍ពីការធ្វើដំណើរដ៏លំបាករបស់ប្រជាជននា៤៤ឆ្នាំមុន ខ្ញុំក៏ចូលរួមសោកស្តាយពីការបាត់បង់ការបែកបាក់ក្រុមគ្រួសារ សាច់ញាតិបងប្អូន ក្រោមស្នាដៃខ្មែរក្រហមដែលបានធ្វើបាបប្រជាជនស្លូតត្រង់។ ប្រជាជនបាត់បង់សាច់ញាតិ ប្រទេសជាតិបាត់បង់វប្បធម៌ សេដ្ឋកិច្ច និងមានភាពចលាចលដោយសារខ្មែរក្រហម។

ខ្ញុំឈ្មោះ **រេហង ច័ន្ទធីរៈយុទ្ធ** អាយុ១៧ឆ្នាំ រស់នៅភូមិបុរីរដ្ឋបាល ក្រុងសំរោង ខេត្តឧត្តរមានជ័យ។ ការជិះរថភ្លើងនៅពេលនេះគឺជាលើកទី១របស់ខ្ញុំ ហើយខ្ញុំមានអារម្មណ៍ប្លែក ព្រោះបានឃើញទេសភាពវាលស្រែរួម ទាំងមានខ្យល់បរិសុទ្ធអំឡុងពេលធ្វើដំណើរ។ អាកាសធាតុនាពេលរដូវប្រាំងក្តៅបន្តិច ប៉ុន្តែមិនជាក្តៅខ្លាំងនោះទេ។ ខ្ញុំថែមទាំងឃើញតថភាពរស់នៅរបស់ប្រជាជននៅតាមដងផ្លូវរថភ្លើង និងបានឈ្ងុយល់បន្ថែមពីជីវភាពរស់នៅរបស់ប្រជាជន។ ខ្ញុំគិតថា យាយតា ដែលជម្លៀសតាមរថភ្លើងក្នុងរបបខ្មែរក្រហមមានភាពលំបាកវេទនាខ្លាំង ដោយសារមានមនុស្សច្រើនពេកក្នុងទូរថភ្លើង។

ខ្ញុំឈ្មោះ **លី បាល់** ភេទ ប្រុស អាយុ១៨ឆ្នាំ។ ខ្ញុំរស់នៅស្រុកសំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ។ ខ្ញុំមានអារម្មណ៍សប្បាយចិត្តជាខ្លាំងក្នុងពេលធ្វើដំណើរតាមរថភ្លើងព្រោះជាលើកទីមួយសម្រាប់ខ្ញុំ មិនតែប៉ុណ្ណោះ ការធ្វើដំណើរតាមរថភ្លើងនេះ ខ្ញុំបានមើលទេសភាពស្រែចម្ការដ៏ស្រស់ស្អាត។ សម្រាប់ខ្ញុំការធ្វើដំណើរតាមរថភ្លើងនេះ ទោះក្តៅបន្តិចមែនតែសប្បាយស្រស់ស្រាយប្លែកភ្នែក។ សម្រាប់ខ្ញុំការជម្លៀសយាយតាក្នុងរបបខ្មែរក្រហមតាមរថភ្លើងនេះ

ពិតជាពិបាកណាស់សម្រាប់មនុស្សចាស់ជរា និងអ្នកមានផ្ទៃពោះ ព្រោះគាត់ពិបាកអង្គុយចុកចង្កេះ ស្ពឹកដៃជើង ហើយអាកាសធាតុពេលថ្ងៃត្រង់ក្ដៅខ្លាំងៗ ការជម្លៀសនេះ គឺបានបង្ខំឲ្យប្រជាជនប្រញាប់ប្រញាល់ចាកចេញពីលំនៅដ្ឋានកាន់តែលឿនកាន់តែល្អ។ ខ្ញុំពិតជាអាណិតអាសូរដល់គាត់ខ្លាំងណាស់ដោយបានដឹងពីការជម្លៀសនេះ។ ខ្ញុំពិតជាសោកស្ដាយខ្លាំងណាស់ ព្រោះរឿងនេះកើតលើប្រជាជនខ្មែរ។ ខ្ញុំសង្ឃឹមថារបបមួយនេះនឹងមិនកើតឡើងលើប្រជាជនខ្មែរយើងម្ដងទៀតទេ ដោយយើងបានរៀនមេរៀននេះ។ យើងដឹងថា ការជម្លៀសនេះវាពិតជាឈឺចាប់ណាស់សម្រាប់ប្រជាជនខ្មែរក្នុងរបបខ្មែរក្រហមនេះ។ ខ្ញុំនឹងចែករំលែកនៅអ្វីដែលខ្ញុំចេះនឹងរៀនពីទីនេះទៅកាន់មនុស្សដទៃទៀតឲ្យបានដឹងពីបទពិសោធន៍នេះ។

ខ្ញុំឈ្មោះ **គឿន គើប** អាយុ៤០ឆ្នាំ រស់នៅភូមិសំរោង ឃុំលាងដៃ ស្រុកអង្គរធំ ខេត្តសៀមរាប។ នេះជាលើកដំបូងហើយសម្រាប់ខ្ញុំដែលបានមកចូលរួមកម្មវិធីដំណើរទស្សនកិច្ចសិក្សាដោយជិះរថភ្លើង ហើយក៏មិនដែលដឹងថាខុសគ្នាពីជិះរថយន្តដែរ។ ពេលបានជិះរថភ្លើងហើយទើបខ្ញុំដឹងថារលាក់យោគបន្តិចទៅតាមស្ថានភាពផ្លូវរថភ្លើង និងមានសំឡេងរំខានបន្តិចៗ ចំពោះអាកាសធាតុវិញគឺក្ដៅបន្តិច ព្រោះរថភ្លើងមិនមានម៉ាស៊ីនត្រជាក់ដូចរថយន្ត ប៉ុន្តែវាមិនមែនជាឧបសគ្គទេសម្រាប់ខ្ញុំ។ ចំណែកទេសភាពតាមដងផ្លូវនៅរដូវប្រាំងគឺមានភាពក្រៀមក្រោះ មិនស្រស់បំព្រងដូចរដូវវស្សាឡើយ។ បើគិតដល់របបខ្មែរក្រហមវិញ ខ្ញុំអាណិតស្រណោះដល់លោកយាយ លោកតាខ្លាំងណាស់ ដែលត្រូវបានខ្មែរក្រហមជម្លៀសតាមរថភ្លើងដោយបង្ខំ ត្រូវឃ្លាតឆ្ងាយពីស្រុកភូមិកំណើត ព្រាត់ប្រាសក្រុមគ្រួសារជាទីស្រលាញ់ ហើយត្រូវមកធ្វើការដោយបង្ខំចិត្តបង្ខំកាយ ធ្វើការលើសកម្លាំង រងការធ្វើទារុណកម្មផ្សេងៗគ្រប់បែបយ៉ាង និងមិនមានបាយហូបឆ្អែត។ អ្នកទ្រាំមិនបានក៏ស្លាប់ចោលក្រុមគ្រួសារបាត់ទៅ អ្នកខ្លះក៏មានវាសនាបានមកជួបក្រុមគ្រួសារវិញ។



អ្នកស្ម័គ្រចិត្តកម្ពុជាចំនួន៩៩នាក់ក្នុងនោះស្រីចំនួន៥៥នាក់ និងប្រុសចំនួន៤៤នាក់ មកពីស្រុកវ៉ារិន និងស្រុកអង្គរធំ ខេត្តសៀមរាប និងស្រុកអន្លង់វែង, ស្រុកត្រពាំងប្រាសាទ និងក្រុងសំរោង ខេត្តឧត្ដរមានជ័យ ចូលរួមដំណើរទស្សនកិច្ចសិក្សាស្ដីអំពីការជម្លៀសដោយបង្ខំក្នុងរបបខ្មែរក្រហម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# អ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តកំពង់ចាមចូលរួមទស្សនកិច្ចសិក្សាស្តីអំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យ ៖ ផ្តោតសំខាន់ទៅលើការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩)

**សាំង ចិន្តា**



អ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តកំពង់ចាមចូលរួមទស្សនកិច្ចសិក្សាស្តីអំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យ ដោយផ្តោតសំខាន់ទៅលើការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំទស្សនកិច្ចសិក្សាអំពី «ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យ» សម្រាប់យុវជនដែលផ្តោតទៅលើការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩) ដែលប្រព្រឹត្តទៅចាប់ពីថ្ងៃទី៣ ដល់ថ្ងៃទី៧ ខែមេសា ឆ្នាំ២០២៤។ ទស្សនកិច្ចសិក្សាអំពី «ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យ» នេះគឺជាកម្មវិធីស្រាវជ្រាវ ដែលធ្វើឡើងដើម្បីជំរុញការយល់ដឹងអំពីការជម្លៀសប្រជាជនដោយបង្ខំក្នុងដំណាក់កាលទី២គឺតាមរថភ្លើង និងកសាងនិងបណ្តុះបណ្តាលផ្នែកស្រាវជ្រាវដល់អ្នកស្ម័គ្រចិត្តកម្ពុជា ជំនាន់ទី៨ ដែលជាយុវជន-យុវនារីជំនាន់ក្រោយ។ អ្នកស្ម័គ្រចិត្តកម្ពុជា ជំនាន់ទី៨ ប្រចាំខេត្តកំពង់ចាម សរុបចំនួន១៥០នាក់ ដែលមកពីស្រុកកំពង់សៀម ស្រុកជើងព្រៃ ស្រុកកោះសូទិន ស្រុកបំការលើ និងស្រុកស្រីសន្ធរ ចូលរួមទស្សនកិច្ចសិក្សាអំពី «ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និង

លទ្ធិប្រជាធិបតេយ្យ»នេះ ក្នុងទិសដៅទៅកាន់ភាគពាយ័ព្យនៃប្រទេសកម្ពុជា គឺខេត្តពោធិ៍សាត់ និងខេត្តបន្ទាយមានជ័យ និងការប្រជុំបូកសរុបកិច្ចការងារស្រាវជ្រាវរបស់ខ្លួន។ ទស្សនកិច្ចសិក្សាអំពី «ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យ» ធ្វើឡើងក្នុងគោលបំណងដូចខាងក្រោម៖

ទី១) ឈ្វេងយល់ពីបទពិសោធន៍របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលត្រូវបានជម្លៀសដោយបង្ខំតាមរថភ្លើង

ទី២) បង្កើនការយល់ដឹងអំពីសាច់រឿងរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមិនទាន់ត្រូវបានចងក្រង និងចុះផ្សាយ ចេញពីប្រវត្តិសាស្ត្រផ្ទាល់មាត់របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

ទី៣) ផ្តល់ឱកាសដល់យុវជន-យុវនារី កើតក្រោយរបបខ្មែរក្រហម ឈ្វេងយល់ពីផ្លូវរថភ្លើង និងទទួលបានបទពិសោធន៍ផ្ទាល់ខ្លួនក្នុងការធ្វើដំណើរតាមរថភ្លើងដើម្បីលើកកម្ពស់អំពីការចូលរួមដោយប្រជាធិបតេយ្យ។

**ទស្សនកិច្ចសិក្សាអំពី«ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យ»នេះ ដាក់ចេញនូវរបៀបវារៈ និងទិសដៅរួមមាន៖**

នៅរសៀលថ្ងៃទី៣ ខែមេសា យុវជន-យុវនារីដែលជាអ្នកស្ម័គ្រចិត្តកម្ពុជា មកពីខេត្តកំពង់ចាម ចុះទស្សនកិច្ចសិក្សាមកកាន់ព្រះរាជបណ្ណាល័យ ហ្លួងម៉ែ និងស្នាក់ការកណ្តាលមជ្ឈមណ្ឌលឯកសារកម្ពុជា។ សុភ័ក្ត្រ ភាណា នាយកផ្នែកទំនាក់ទំនងនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ទទួលស្វាគមន៍ និងដឹកនាំប្រតិភូយុវជន-យុវនារីស្ម័គ្រចិត្តកម្ពុជាមកពីខេត្តកំពង់ចាម ទាំងអស់ចូលទស្សនាព្រះរាជបណ្ណាល័យ ហ្លួងម៉ែ និងបង្ហាញអំពីពិព័រណ៍ និងឯកសារដែលមានតម្កល់នៅព្រះរាជបណ្ណាល័យ។ ប្រតិភូយុវជន-យុវនារីស្ម័គ្រចិត្តកម្ពុជាមកពីខេត្តកំពង់ចាម បន្តទៅទស្សនាស្នាក់ការកណ្តាលមជ្ឈ-មណ្ឌលឯកសារកម្ពុជា និងបានជួបសំណេះសំណាលជាមួយក្រុមការងារ និងលោកនាយក ឆាំង យុ ដែលបានរៀបចំកិច្ចការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ បន្ទាប់ពីទស្សនកិច្ចសិក្សានៅព្រះរាជបណ្ណា-ល័យ ហ្លួងម៉ែ និងស្នាក់ការកណ្តាលមជ្ឈមណ្ឌលឯកសារកម្ពុជាបានបញ្ចប់, ប្រតិភូយុវជន-យុវនារីស្ម័គ្រចិត្តកម្ពុជាមកពីខេត្តកំពង់ចាម ធ្វើដំណើរទៅទស្សនកិច្ចសិក្សានៅហោអដ្ឋិធាតុ នៅវត្តលង្កាព្រះកុសុមារាម ដើម្បីឈ្វេងយល់ប្រវត្តិសាវតារនៃហោអដ្ឋិធាតុ (បណ្ណាល័យធាតុ) ដែលផ្សារភ្ជាប់ទំនាក់ទំនងជាមួយនឹងប្រវត្តិសាស្ត្រទំនើបរបស់ប្រទេសកម្ពុជា និងការតស៊ូរបស់ប្រជាជនកម្ពុជាក្នុងការជាសះស្បើយពីអតីតកាលរបស់ខ្លួន។

នៅព្រឹកថ្ងៃទី៤ ខែមេសា ប្រតិភូយុវជន-យុវនារីស្ម័គ្រចិត្តកម្ពុជាមកពីខេត្តកំពង់ចាម ធ្វើដំណើរតាមរថភ្លើងចេញពីទីក្រុងភ្នំពេញទៅកាន់ខេត្តពោធិ៍សាត់ និងបន្តដំណើរតាមរថយន្តក្រុងពីខេត្តពោធិ៍សាត់ទៅកាន់ខេត្តបន្ទាយមានជ័យ។ នេះគឺជាលើកទី១ ដែលយុវជន-យុវនារីស្ម័គ្រចិត្តកម្ពុជា ប្រចាំខេត្តកំពង់ចាម ដំណើរតាមរថភ្លើង និងទទួលបទពិសោធន៍ជាច្រើន។ ក្នុងកំឡុងពេលធ្វើដំណើរតាមរថភ្លើងនេះ យុវជន-យុវនារីស្ម័គ្រចិត្តកម្ពុជា ប្រចាំខេត្តកំពង់ចាម អានបទសម្ភាសន៍របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅស្រុកស្រីសន្ធរ និងស្រុកកោះសូទិន ដែលត្រូវបានជម្លៀសដោយបង្ខំ ក្នុងដំណាក់កាលទី៣ និងរឿងព្រេងនិទានខ្មែរ៖ រឿង អាប៉ាង នាងគី និងរឿង ផ្កាយក្រពើ ដែលត្រូវបាននិយាយក្នុងពេលដែលប្រជាជនត្រូវបានជម្លៀសដោយបង្ខំ។ បើទោះបីជាយ៉ាងណាក៏ដោយ ការធ្វើដំណើរតាមរថភ្លើងមិនមានភាពងាយស្រួលសម្រាប់អ្នកស្ម័គ្រចិត្តកម្ពុជាយើងទេ។ អាកាសធាតុក្តៅ និងផ្លូវដែករលាក់ពេលរថភ្លើងកំពុងរត់ ធ្វើឲ្យអ្នកស្ម័គ្រចិត្តទាំងអស់ពិបាកធ្វើការផ្តោតទៅលើសាច់រឿងរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងយល់អំពីន័យបង្កប់ក្នុងរឿងព្រេង

ខ្មែរ ទាំង២៧ បន្ទាប់ពីបានមកដល់ក្រុងសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ អ្នកស្ម័គ្រចិត្តទាំងអស់មកជួបជុំគ្នាដើម្បីបែងចែកក្រុមស្រាវជ្រាវ, ទទួលយកប្រធានបទសម្រាប់ចុះស្រាវជ្រាវ និងឯកសារផ្សេងៗ។

ថ្ងៃទី៥ ខែមេសា ឆ្នាំ២០២៤ ៖ ការចុះជួបអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រស់នៅភូមិស្រះកើត និងភូមិស្រះលិច ឃុំ/ស្រុកព្រះនេត្រព្រះ និងទស្សនកិច្ចសិក្សាទៅកាន់ទំនប់ត្រពាំងថ្ម ស្ថិតនៅភូមិត្រពាំងថ្ម ឃុំប៉ោយចារ ស្រុកភ្នំស្រុក ក្រុមអ្នកស្រាវជ្រាវវ័យក្មេង ដែលជាអ្នកស្ម័គ្រចិត្តកម្ពុជាចាកចេញពីក្រុងសិរីសោភ័ណ្ឌទៅកាន់ភូមស្រះកើត និងស្រះលិច ស្រុកព្រះនេត្រព្រះ ដើម្បីចុះជួបនិងស្តាប់សាច់រឿងរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ ក្រុមអ្នកស្រាវជ្រាវវ័យក្មេងនីមួយៗចំណាយរយៈពេលជាង៣ម៉ោងក្នុងការអង្គុយស្តាប់ និងសួរនាំសាច់រឿងរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ ជាការកត់សម្គាល់ ពាក់កណ្តាលនៃក្រុមអ្នកស្រាវជ្រាវវ័យក្មេងទាំងអស់ មិនបានជួបជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលដឹងអំពីព័ត៌មានទាក់ទងនឹងប្រធានបទរបស់ខ្លួន។ បើទោះបីជាយ៉ាងនេះក្តី ក្រុមអ្នកស្រាវជ្រាវវ័យក្មេងមានភាពបត់បែនយ៉ាងឆាប់រហ័ស និងផ្លាស់ប្តូរប្រធានបទស្រាវជ្រាវរបស់ខ្លួន ដោយស្របទៅតាមប្រភពព័ត៌មានដែលខ្លួនទទួលបានពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ កិច្ចសន្ទនាអន្តរជំនាន់រវាងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងក្រុមអ្នកស្រាវជ្រាវវ័យក្មេងទាំង១៨ក្រុម បញ្ចប់ទៅដោយរលូន និងតាមការគ្រោងទុក។ នៅពេលរសៀល ក្រុមអ្នកស្រាវជ្រាវវ័យក្មេងបន្តចុះទៅកាន់ទីតាំងទំនប់អាងត្រពាំងថ្ម ស្ថិតនៅស្រុកភ្នំស្រុក ដែលមានចំងាយប្រហែល៤៣គីឡូម៉ែត្រ ពីស្រុកព្រះនេត្រព្រះ។ នៅពេលទៅដល់ទំនប់ត្រពាំងថ្ម ក្រុមអ្នកស្រាវជ្រាវវ័យក្មេង ចុះសង្កេតមើលទំនប់ទឹកដ៏ធំ និងសញ្ជឹងគិតអំពីទុក្ខវេទនាប្រជាជនរាប់ម៉ឺននាក់ដែលត្រូវបានបង្ខំឲ្យធ្វើការលើកទំនប់ និងស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម។

បន្ទាប់ពីការចុះជួបជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងទស្សនកិច្ចទៅកាន់ទំនប់ត្រពាំងថ្ម លោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ធ្វើបទបង្ហាញស្តីពី ឯកសារដើម និងការផ្លាស់ប្តូរប្រធានបទស្រាវជ្រាវទៅតាមប្រភពព័ត៌មានទទួលបាន។

ថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៤ ៖ ការចុះទស្សនកិច្ចសិក្សាទៅកាន់ប្រាសាទបន្ទាយឆ្មារ ជាផ្នែកមួយនៃទស្សនកិច្ចសិក្សានេះ អ្នកស្ម័គ្រចិត្តកម្ពុជា ប្រចាំខេត្តកំពង់ចាម ចុះទៅទស្សនកិច្ចសិក្សាទៅកាន់ប្រាសាទបន្ទាយឆ្មារ កសាងចុងសតវត្សរ៍ទី១២និងដើមសតវត្សរ៍ទី១៣ ស្ថិតនៅឃុំបន្ទាយឆ្មារ ស្រុកថ្មពួក។ ការចុះទៅកាន់ប្រាសាទបន្ទាយឆ្មារនេះ ធ្វើឡើងដើម្បីឲ្យក្រុមអ្នក





អ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តកំពង់ចាមចូលរួមទស្សនកិច្ចសិក្សាស្តីអំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យដោយផ្តោតសំខាន់ទៅលើការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ស្រាវជ្រាវវ័យក្មេងឃើញពីសភាពទ្រុឌទ្រោមខ្លាំង ថ្មធ្លាក់រប៉េះដួលរលំរប៉ាត់រប៉ាយ និងយល់ដឹងអំពីផលប៉ះពាល់ដោយសារតែសង្គ្រាម និងរបបខ្មែរក្រហម។

ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២៤៖ ការចូលរួមប្រជុំជាមួយលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា នៅសាលប្រជុំសណ្ឋាគារ ហាយយ៉ាត់ រីជិនស៊ីភ្នំពេញ។

ក្រុមអ្នកស្រាវជ្រាវវ័យក្មេងទាំង១៤ក្រុម រួមទាំងអ្នកស្ម័គ្រចិត្តកម្ពុជា មកពីបណ្ដាខេត្តផ្សេងទៀត ចូលរួមប្រជុំជាមួយលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីធ្វើបទបង្ហាញ និងឆ្លុះបញ្ចាំងអំពីចំណេះដឹង និងបទពិសោធន៍ដែលខ្លួនទទួលបានពីទស្សនកិច្ចសិក្សាអំពី «ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យ» សម្រាប់យុវជន ដែលផ្ដោតទៅលើការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩)។ ក្រុមអ្នកស្រាវជ្រាវវ័យក្មេងចំនួន២ក្រុម មកពីស្រុកកំពង់សៀម និងស្រុកស្រីសន្ធរ ត្រូវបានអនុញ្ញាតធ្វើបទបង្ហាញរបស់ខ្លួន។ បន្ទាប់ពីក្រុមអ្នកស្រាវជ្រាវវ័យក្មេងទាំង២ក្រុមបញ្ចប់បទបង្ហាញរបស់ខ្លួន លោកនាយក ឆាំង យុ ផ្ដល់ចំណាប់អារម្មណ៍ទៅកាន់ប្រធានបទដែលខ្លួនបានបង្ហាញទាក់ទងទៅនឹងការលើកទំនប់ត្រពាំងថ្ម និងរបបអាហារក្នុងរបបខ្មែរក្រហម។

ជាចុងបញ្ចប់នៃទស្សនកិច្ចសិក្សាអំពី«ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យ» រយៈពេល៤យប់៥ថ្ងៃនេះ អ្នកស្រាវជ្រាវវ័យក្មេង ដែលជាអ្នកស្ម័គ្រចិត្តកម្ពុជា ទទួលបានចំណេះដឹងថ្មីអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងបទពិសោធន៍ក្នុងការត្រៀមលក្ខណៈចុះទៅស្រាវជ្រាវ។

ខាងក្រោមគឺជាចំណាប់អារម្មណ៍របស់អ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តកំពង់ចាមដែលបានចូលរួមដំណើរទស្សនកិច្ចសិក្សាស្ដីអំពី៖ ការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម តាមផ្លូវរថភ្លើង៖

១) ជាដំបូង នាងខ្ញុំសូមគោរពលោកពូ ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពងចាម លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្សទាំងអស់។ នាងខ្ញុំឈ្មោះ **ហុង**



អ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តកំពង់ចាមចូលរួមទស្សនកិច្ចសិក្សាស្ដីអំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងលទ្ធិប្រជា-ធិបតេយ្យដោយផ្ដោតសំខាន់ទៅលើការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

**ចាន់រ៉ា** គឺជាសិស្សថ្នាក់ទី១២ នៃវិទ្យាល័យ ហ៊ុន សែន ស្គន់ និងជាអ្នកស្ម័គ្រចិត្តនៃអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា។ នាងខ្ញុំពិតជាមានអារម្មណ៍ថាអស្ចារ្យខ្លាំងណាស់ដែលបានចូលរួមដំណើរទស្សនកិច្ចសិក្សាស្រាវជ្រាវអំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហម និងទៅសម្ភាសន៍តាយាយអ៊ំពូមីងដោយផ្ទាល់នៅខេត្តបន្ទាយមានជ័យ។

ដំបូងខ្ញុំឃើញទំនប់អាងត្រពាំងថ្ម ហាក់ដូចជាទន្លេ ដែលមានទំហំធំធេង និងមានទឹកជ្រៅនៅពេលទៅដល់ភ្លាម ប៉ុន្តែនៅពេលដែលស្តាប់ការលើកឡើងរបស់លោកគ្រូ ស៊ាង ចិន្តា ធ្វើឲ្យនាងខ្ញុំ និងសិស្សានុសិស្សជាច្រើននាក់ទៀតមានការភ្ញាក់ផ្អើលជាខ្លាំងព្រោះ ទំនប់ត្រពាំងថ្មនេះកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ខ្មែរក្រហមបានប្រើតាយាយ អ៊ំពូមីង ធ្វើការដោយកម្លាំងផ្ទាល់ដោយគ្មានពេលសម្រាក។ នាងខ្ញុំពិតជាមានសេចក្តីសង្វេគចំពោះយាយតា ជាពន់ពេកនៅពេលបានដឹងរឿងរ៉ាវពិតដែលបង្កប់នៅខាងក្រោយភាពស្រស់ស្អាតរបស់ទំនប់ត្រពាំងថ្មនេះ។ បន្ថែមលើនេះ ខ្ញុំបានធ្វើដំណើរដោយជិះរថភ្លើង។ ការធ្វើដំណើរតាមផ្លូវមានការលំបាក និងក្តៅបន្តិចមែន ប៉ុន្តែសម្រាប់នាងខ្ញុំគឺជាអ្នកស្ម័គ្រចិត្តអាចពុះពារបាន។

នៅពេលខ្មែរក្រហមឡើងគ្រប់គ្រងអំណាច ខ្មែរក្រហមបានជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញដែលបង្កឲ្យមានការលំបាកជាខ្លាំង ហើយនេះគឺជាលើកទីមួយហើយដែលនាងខ្ញុំបានធ្វើដំណើរដោយជិះរថភ្លើង។ នាងខ្ញុំបានដឹងអំពីប្រវត្តិសាស្ត្រដែលខ្មែរក្រហមបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍លើជាតិនិងប្រជាជនរបស់ខ្លួន និងបានយល់ដឹងអំពីទុក្ខលំបាករបស់យាយតា នាសម័យនោះ។ ទស្សនកិច្ចសិក្សានេះធ្វើឲ្យនាងខ្ញុំទទួលបាននូវបទពិសោធន៍ថ្មី និងជំរុញនាងខ្ញុំឲ្យមានភាពក្លាហានជាងមុន។

ជាកិច្ចបញ្ចប់ នាងខ្ញុំសូមអរគុណដល់អង្គការមជ្ឈមណ្ឌលឯកសារកម្ពុជាដែលផ្តល់ឱកាសដល់នាងខ្ញុំក៏ដូចជាសិស្សានុសិស្សជាច្រើនទៀតបានចូលរួមទស្សនកិច្ចសិក្សានេះ។ ខ្ញុំក៏សូមគោរពជូនពរដល់អង្គការមជ្ឈមណ្ឌលឯកសារកម្ពុជាឲ្យកាន់តែមានភាពរីកចម្រើនតទៅមុខជានិរន្តរ៍ ដើម្បីជាទីស្នាក់ការតម្កល់ឯកសារសម័យខ្មែរក្រហមសម្រាប់កូនចៅ និងអ្នកស្រាវជ្រាវជំនាន់ក្រោយ។

២) នាងខ្ញុំឈ្មោះ **ម៉ន ជាយីន** សូមគោរព និងអរគុណដល់លោកតា ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ក្រុមការងារ ព្រមទាំងលោកគ្រូ អ្នកគ្រូ និងយុវជនស្ម័គ្រចិត្តទាំងអស់ ដែលបានចូលរួមក្នុងដំណើរទស្សនកិច្ចសិក្សានេះ។ កម្មវិធីនេះគឺប្លែកព្រោះខ្ញុំមិនដែលបានជួបពីមុនមក ដូចជា ការផ្តល់ឱកាសឲ្យក្រុមអ្នកស្ម័គ្រចិត្តចុះទៅស្រាវជ្រាវពីប្រវត្តិសាស្ត្ររបស់ប្រជាជនដែលបានរួចផុតពីរបបខ្មែរក្រហម។

ទស្សនកិច្ចនេះបានធ្វើឲ្យខ្ញុំយល់ដឹងកាន់តែច្បាស់ថា ប្រជាជនក្នុងសម័យនោះជួបការលំបាកខ្លាំងណាស់ ទាំងការរស់នៅ ទាំងការហូបចុក និងមិនមានសុវត្ថិភាពឡើយ។ ទីតាំងក្នុងដំណើរទស្សនកិច្ចសិក្សាខ្លះ នាងខ្ញុំមិនដែលស្គាល់ មិនដែលឮពីមុនមកទេ ដូចជា ទំនប់ត្រពាំងថ្ម និងកន្លែងផ្សេងៗទៀត។ ទស្សនកិច្ចនេះ បានផ្តល់បទពិសោធន៍ថ្មីសម្រាប់ជីវិតរបស់នាងខ្ញុំ នៅពេលដែលខ្ញុំបានចុះទៅកាន់ទីនោះផ្ទាល់។ នាងខ្ញុំនឹងចែករំលែកចំណេះដឹង និងបទពិសោធន៍ដែលនាងខ្ញុំទទួលបានពីដំណើរទស្សកិច្ចនេះទៅដល់ប្អូនៗ និងក្មេងៗជំនាន់ក្រោយឲ្យបានយល់ដឹងទាំងអស់គ្នា។

ជាចុងក្រោយ នាងខ្ញុំចង់ឲ្យមានដំណើរទស្សន-កិច្ចបែបនេះទៀត ដើម្បីផ្តល់ឱកាសឲ្យក្មេងៗយល់ដឹងព្រោះវាគឺជាចំណែកមួយនៃប្រវត្តិសាស្ត្ររបស់ប្រទេសជាតិយើង។ ដំណើរទស្សនកិច្ចសិក្សារយៈពេល៤យប់៥ថ្ងៃ គឺមានន័យខ្លាំងណាស់សម្រាប់ខ្ញុំ។

៣) ខ្ញុំឈ្មោះ **ឡម ចន្ទរចនា** សូមជម្រាបសួរលោកគ្រូអ្នកគ្រូ និងបងៗទាំងអស់គ្នា!

សម្រាប់ដំណើរទស្សនកិច្ចរយៈពេល៤យប់ ៥ថ្ងៃនេះ ខ្ញុំគិតថាលើសពីការរំពឹងទុករបស់ខ្ញុំហើយ

ខ្ញុំសប្បាយចិត្តខ្លាំងណាស់ដែលបានស្គាល់មនុស្សថ្មី កន្លែងថ្មីៗ ព្រមទាំងទទួលបានបទពិសោធន៍ថ្មីៗ និងចំណេះដឹងថ្មីបន្ថែមទៀតទាក់ទងនឹងរបបខ្មែរក្រហម។ ខ្ញុំត្រូវឡើងទៅភ្នំពេញតែម្នាក់ឯង គឺជាកន្លែងដែលខ្ញុំមិនដែលស្គាល់ច្បាស់ពីមុនមក។ ខ្ញុំក៏បានស្គាល់បរិបទនៃការរស់នៅទីក្រុង ដែលខ្ញុំមិនដែលដឹង និងឆ្លងកាត់ទេ។ ខ្ញុំបានជិះរថភ្លើងដែលជាលើកទីមួយរបស់ខ្ញុំ ហើយខ្ញុំក៏បានស្គាល់ និងយល់ដឹងអំពីជីវភាពរបស់ប្រជាជននៅតាមទីកន្លែងដែលខ្ញុំបានទៅដល់ និងបានស្តាប់រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលខ្ញុំមិនធ្លាប់បានស្តាប់ពីមុនមក ដូចជា ហូបសាច់មនុស្ស។ ខ្ញុំសប្បាយចិត្តយ៉ាងខ្លាំងដែលបានទៅទស្សនាប្រាសាទបន្ទាយឆ្មារលើកទីមួយ និងបានយល់ដឹងអំពីប្រវត្តិប្រាសាទ និងស្ញប់ស្ញែងយ៉ាងខ្លាំងដល់ដូនតាខ្មែរដ៏អស្ចារ្យដែលបានកសាងប្រាសាទនេះ ដោយប្រើរយៈពេលប្រាំឆ្នាំដើម្បីប្រមូលថ្មភក់ និងថ្មបាយក្រៀមជាច្រើនសម្រាប់សាងសង់។

ខ្ញុំក៏មានអារម្មណ៍សោកស្តាយដែលប្រាសាទបន្ទាយឆ្មារត្រូវរងការបំផ្លិចបំផ្លាញពីមនុស្ស និងធម្មជាតិដែលដូនតាខិតខំកសាងយ៉ាងលំបាក។ នៅពេលដែលខ្ញុំបានមកដល់វត្តរំលិច ខ្ញុំបានឃើញអដ្ឋិធាតុជនរងគ្រោះដែលស្លាប់នៅក្នុងរបបខ្មែរក្រហម ខ្ញុំសោកស្តាយ និងតក់ស្លុតព្រោះមិនដឹងថាជនរងគ្រោះទាំងនោះវេទនាយ៉ាងណានោះទេ។ បន្ថែមពីនេះ នៅពេលដែលខ្ញុំបានស្តាប់រឿងរ៉ាវរបស់អ៊ឹំ ស្រី ស៊ីនួន ខ្ញុំពិតជាអាណិតគាត់ខ្លាំងណាស់ ព្រោះគាត់បាត់បង់មនុស្សជាទីស្រឡាញ់ជាច្រើននាក់។ ជីវិតរបស់គាត់នៅពេលនោះលំបាកយ៉ាងខ្លាំង ហើយពេលមួយនោះគាត់ស្ទើរតែមិនមានជីវិតរស់។ រឿងរ៉ាវទាំងអស់នោះនៅតែដក់ជាប់ក្នុងអារម្មណ៍គាត់ជានិច្ច។ គាត់បានផ្តល់ដំបូន្មានដល់អ្នកជំនាន់ក្រោយឲ្យចេះស្រឡាញ់រួបរួម និងជួយដល់ប្រទេសជាតិ។ បន្ថែមលើនេះ ខ្ញុំទទួលបានបទពិសោធន៍ក្នុងការធ្វើការងារជាក្រុម និងបានជួបជាមួយនាយកមជ្ឈមណ្ឌលឯកសារកម្ពុជា។ ដំណើរទស្សនកិច្ចរយៈពេល៤យប់៥ថ្ងៃនេះ ខ្ញុំជួបបញ្ហាប្រឈមខ្លះ ព្រោះខ្ញុំពុលឡានពិបាកសម្របខ្លួនជាមួយអាកាសធាតុក្តៅខ្លាំង និងមានបញ្ហាសុខភាព។

ទោះបីយ៉ាងណា ខ្ញុំចង់ឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជានៅតែបន្តផ្តល់ឱកាសដល់យុវជនស្ម័គ្រចិត្តក្នុងការចូលរួមបំពេញការងារស្ម័គ្រចិត្ត ក៏ដូចជាផ្តល់ឱកាសក្នុងដំណើរទស្សនកិច្ចដែលធ្វើឲ្យយុវជនឈ្វេងយល់រឿងរ៉ាវជាច្រើនដែលគាត់មិនធ្លាប់ដឹង និងជួយជំរុញយុវជនស្ម័គ្រចិត្តឲ្យមានភាពក្លាហាន ចេះទំនាក់ទំនង និងចេះរួមចំណែកជួយដល់សង្គម។

ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណដល់លោកគ្រូអ្នកគ្រូ បងៗក្រុមការងារទាំងអស់ដែលខិតខំយកចិត្តទុកដាក់យ៉ាងខ្លាំងដល់អ្នកស្ម័គ្រចិត្ត និងអរគុណដល់យុវជនស្ម័គ្រចិត្តពីជំនាន់ទី១ ដល់ជំនាន់ទី៨ ដែលស្រឡាញ់រាប់អាន និងមានទំនាក់ទំនងល្អក្នុងដំណើរទស្សនកិច្ចនេះ។





អ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តកំពង់ចាមចូលរួមទស្សនកិច្ចសិក្សាស្តីអំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យដោយផ្តោតសំខាន់ទៅលើការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# អ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តត្បូងឃ្មុំ ចូលរួមទស្សនកិច្ចសិក្សាស្តីពី អំពើប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យ ដោយផ្តោតសំខាន់លើការជម្លៀសដោយបង្ខំក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩)

ឡុង ដានី



អ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តត្បូងឃ្មុំចូលរួមទស្សនកិច្ចសិក្សាស្តីពី អំពើប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យ ដោយផ្តោតសំខាន់លើការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





នៅព្រឹកថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម នៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានដឹកនាំអ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តត្បូងឃ្មុំចំនួន១០២នាក់ ចូលរួមដំណើរទស្សន-កិច្ចសិក្សាស្តីអំពី «ផ្លូវរថភ្លើងខ្មែរក្រហម៖ អំពើប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យ ការជម្លៀសដោយបង្ខំក្នុងរបបខ្មែរក្រហម (១៩៧៥ - ១៩៧៩)»។ គោលបំណងទស្សនកិច្ចសិក្សាស្តីពី ផ្លូវរថភ្លើងខ្មែរក្រហម អំពើប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យ ការជម្លៀសដោយបង្ខំក្នុងរបបខ្មែរក្រហម (១៩៧៥ - ១៩៧៩) មានចំនួន៣ ដូចខាងក្រោម៖

១) ឈ្វេងយល់ពីបទពិសោធន៍របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមអំពីការជម្លៀសដោយបង្ខំតាមរថភ្លើង។ ជាពិសេសខ្មែរក្រហមបានជម្លៀសប្រជាជនដោយបង្ខំក្នុងដំណាក់កាលទី២ តាមរថភ្លើងចាប់ពីខែកញ្ញា ឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៧ ដោយជម្លៀសចេញពីភូមិភាគនិរតី ភូមិភាគ

បស្ចិម ឆ្ពោះទៅកាន់ភូមិភាគពាយ័ព្យ (បច្ចុប្បន្នខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តប៉ៃលិន)។ យោងតាមឯកសារនៅមជ្ឈ-មណ្ឌលឯកសារកម្ពុជាដែលបន្សល់ទុកពីរបបខ្មែរក្រហមបានបង្ហាញឲ្យដឹងថា ប្រជាជនចន្លោះពី៤សែនទៅ៥សែននាក់ត្រូវបានខ្មែរក្រហមបញ្ជូនទៅកាន់ភូមិភាគពាយ័ព្យ ហើយប្រជាជនប្រមាណ៥ម៉ឺននាក់ទៀតត្រូវជម្លៀសចេញពីភូមិភាគបូព៌ា រួមមានខេត្តព្រៃវែង និងខេត្តស្វាយរៀង។ បុគ្គលិកធ្វើការនៅស្ថានីយរថភ្លើង ពិតជាបានឃើញប្រជាជនរាប់ម៉ឺននាក់ ត្រូវបានជម្លៀសតាមខ្សែរថភ្លើងចេញពីភ្នំពេញឆ្ពោះទៅកាន់ស្ថានីយរថភ្លើងផ្សេងៗដូចជាខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបងនៃភូមិភាគពាយ័ព្យ។

២) បង្កើនការយល់ដឹងអំពីរឿងរ៉ាវអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមតាមរយៈប្រវត្តិសាស្ត្រផ្ទាល់មាត់។ តាមរយៈដំណើរទស្សនកិច្ចសិក្សានេះ យុវជននឹងមានឱកាសជួបសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅតាមទីតាំងឧក្រិដ្ឋកម្មដែលប្រព្រឹត្តិដោយរបបខ្មែរក្រហមមួយចំនួននៅក្នុងស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ និងស្រុកកណ្ដៀង ខេត្តពោធិ៍សាត់។

៣) ផ្ដល់ឱកាសដល់យុវជនដើម្បីឈ្វេងយល់ពីផ្លូវរថភ្លើង និងការធ្វើដំណើរតាមរថភ្លើង ដើម្បីលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ។ រថភ្លើងគឺជាមធ្យោបាយដឹកជញ្ជូនដ៏មានប្រជាប្រិយមួយក្នុងមធ្យោបាយដឹកជញ្ជូនផ្សេងៗទៀត ពីព្រោះការធ្វើដំណើរ ឬដឹកជញ្ជូនតាមរថភ្លើងមានតម្លៃថោក និងផ្ទុកបានចំនួនច្រើន ហើយផ្ដល់ផលប៉ះពាល់ដល់បរិស្ថានតិចតួច។ រថភ្លើងក៏ជានិមិត្តរូបនៃចលនាតស៊ូដើម្បីសេរីភាពតាមគោលការណ៍អហឹង្សារបស់មេដឹកឥណ្ឌាឈ្មោះមហាត្មៈ គន្ធី ដែលបាននាំប្រទេសឥណ្ឌាទទួលបានឯករាជ្យពីចក្រភពអង់គ្លេស និងបានក្លាយទៅជាប្រទេសប្រជាធិបតេយ្យមួយនៅលើពិភពលោក។

លោក ឡុង ដានី ធ្វើការបែងចែកអ្នកស្ម័គ្រចិត្តចំនួន១០២នាក់ ជា១០ក្រុម ដើម្បីសម្ភាសន៍ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ ចំពោះការសម្ភាសន៍ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមានពីរដំណាក់កាល គឺសម្ភាសន៍ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅទួល



អ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តត្បូងឃ្មុំចូលរួមទស្សនកិច្ចសិក្សាស្ដីពី អំពើប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិប-តេយ្យ ដោយផ្ដោតសំខាន់លើការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ពោធិ៍ជ្រៃ ខេត្តពោធិ៍សាត់ និងឃុំព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ បន្ទាប់ពីកិច្ចប្រជុំបញ្ចប់អ្នកស្ម័គ្រចិត្តបន្តដំណើរទស្សនាបណ្ណាល័យហោអដ្ឋិធាតុនៅវត្តលង្កា រួមបន្តដំណើរចូលមកសណ្ឋាគាររៀងៗខ្លួន។

នៅព្រឹកថ្ងៃទី៩ ខែមេសា ឆ្នាំ២០២៤ វេលាម៉ោង៦ព្រឹកអ្នកស្ម័គ្រចិត្តទាំងចំនួន១០២នាក់បានធ្វើដំណើរពីសណ្ឋាគារទៅស្ថានីយរថភ្លើងជួបជុំគ្នានៅម៉ោង៦និង៣០នាទី។ លោក ឡុង ដានី បានធ្វើបទបង្ហាញអំពីការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម ជាពិសេសការជម្លៀសដោយបង្ខំក្នុងដំណាក់កាល ទី២ តាមរថភ្លើងចាប់ពីខែកញ្ញាឆ្នាំ១៩៧៥រហូតដល់ឆ្នាំ១៩៧៩ដោយជម្លៀសចេញពីភូមិភាគនិរតី ភូមិភាគបស្ចិម ឆ្ពោះទៅកាន់ភូមិភាគពាយ័ព្យ(បច្ចុប្បន្ន ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តប៉ៃលិន) ។

នៅម៉ោង១២និង៣០នាទីរសៀលអ្នកស្ម័គ្រចិត្តទាំងអស់បានធ្វើដំណើរមកដល់ស្ថានីយរថភ្លើងក្រុងពោធិ៍សាត់និងជិះឡានក្រុងបន្តទៅក្រុងសិរីសោភ័ណដើម្បីជួបសម្ភាសន៍ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន១នាក់។

នៅក្នុងដំណើរទស្សនកិច្ចនេះអ្នកស្ម័គ្រចិត្តកម្ពុជាបង្ហាញចំណាប់អារម្មណ៍ដូចខាងក្រោម៖

១) នាងខ្ញុំឈ្មោះ**លុន លក្ខិណា** ពិតជាមានសេចក្តីសប្បាយរីករាយណាស់នៅថ្ងៃនេះ។ ភាពសប្បាយរីករាយនេះ គឺកើតចេញពីការរៀបចំរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានរៀបចំឲ្យក្រុមអ្នកស្ម័គ្រចិត្តកម្ពុជា ទាំងអស់បានធ្វើដំណើរតាមរថភ្លើង ដើម្បីទទួលបាននូវបទពិសោធន៍ថ្មី ព្រមទាំងបានដឹងពីទុក្ខលំបាកនៃការធ្វើដំណើរតាមរថភ្លើងរបស់អ្នករស់រានមានជីវិតពីរបបប្រល័យពូជសាសន៍ ប៉ុល ពត។

២) ខ្ញុំបាទឈ្មោះ **គឿន ហ៊ាង**។ នៅថ្ងៃទីមួយនៃការធ្វើដំណើរទស្សនកិច្ចសិក្សានេះ ខ្ញុំពិតជាមានអារម្មណ៍សប្បាយរីករាយ និងប្លែក ពេលចេញពីភ្នំពេញឆ្ពោះមកទីរួមខេត្តបន្ទាយមានជ័យ ដើម្បីសិក្សាអំពីតំបន់ប្រវត្តិសាស្ត្រ និងទុក្ខលំបាករបស់ប្រជាជនកម្ពុជាដែលធ្លាប់ឆ្លងកាត់ក្នុងរបបខ្មែរក្រហម។ នៅលើរថភ្លើង ខ្ញុំជួបការលំបាកខ្លះៗដែរ ប៉ុន្តែបើស្រមៃពីភាពលំបាករបស់ប្រជាជនកម្ពុជាក្នុងពេលជម្លៀស ទាំងបង្ខំតាមរយៈរថភ្លើង ខ្ញុំគិតថាវាលំបាកជាងខ្ញុំទ្វេដងព្រោះកាលនោះខ្មែរក្រហមជម្លៀសប្រជាជនមានចំនួនច្រើនជាង។

៣) ខ្ញុំបាទឈ្មោះ **នី សុខនីម** មកពីវិទ្យាល័យហ៊ុន សែន ខ្នារ។ នៅពេលខ្ញុំបានចូលរួមក្នុងដំណើរទស្សនកិច្ចសិក្សាតាមរថភ្លើងរួចមក ខ្ញុំមានអារម្មណ៍ប្លែក ព្រោះការជិះរថភ្លើងគឺជាលើកទីមួយរបស់ខ្ញុំ។ ខ្ញុំរំភើបសប្បាយរីករាយ និងបានជជែកលេងជាមួយអ្នកស្ម័គ្រចិត្តដែលរួមដំណើរជាមួយគ្នា។ នៅក្នុងទូរថភ្លើងមិនសូវក្តៅទេ ព្រោះបំពាក់ទៅដោយម៉ាស៊ីនត្រជាក់។ ប៉ុន្តែនៅពេលស្រមៃទៅរបបខ្មែរក្រហមគឺមិនមានម៉ាស៊ីនត្រជាក់ គ្មានអាហារហូប កន្លែងអង្គុយប្រជ្រៀតគ្នាមិនស្រួលដូចរថភ្លើងដែលខ្ញុំកំពុងជិះទេ។ ប្រជាជនខ្លះ បានបាត់បង់ជីវិតក្នុងពេលនោះទៀតផង។ ទស្សនកិច្ចសិក្សាតាមរថភ្លើង បានឲ្យខ្ញុំបង្កើនទំនាក់ទំនងសមាជិកក្រុម ឲ្យមានភាពស្និទ្ធស្នាលគ្នា បង្កើតភាពសប្បាយរីករាយ និងបានហូបអាហាររួមគ្នា។

ជាចុងក្រោយ ខ្ញុំសូមអរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានរៀបចំកម្មវិធីទស្សនកិច្ចសិក្សាតាមរថភ្លើងនេះដោយមានការយកចិត្តទុកដាក់ មានកន្លែងស្នាក់នៅស្អាត ធ្វើឲ្យក្រុមអ្នកស្ម័គ្រចិត្តកម្ពុជាមានភាពកក់ក្តៅ។ ខ្ញុំសូមសំណូមពរដល់មជ្ឈមណ្ឌលឯកសារកម្ពុជាឲ្យមានការរៀបចំកម្មវិធីនេះជាបន្តបន្ទាប់ទៀត ដើម្បីឲ្យយុវជនស្ម័គ្រចិត្តជំនាន់ក្រោយបានសិក្សាឈ្វេងយល់ពីប្រវត្តិសាស្ត្រខ្មែរក្រហម។

៤) ជម្រាបសួរ នាងខ្ញុំឈ្មោះ **គួន ស្រីខ៊ួន** អាយុ២០ឆ្នាំ គឺជានិស្សិតគណនេយ្យ នៃសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច មកពីស្រុក

មេមត់ ខេត្តត្បូងឃ្មុំ។ នាងខ្ញុំគឺជាយុវជនស្ម័គ្រចិត្ត នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលចូលរួមដំណើរទស្សនកិច្ចសិក្សាអំពីការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ ខ្ញុំសូមអរគុណដល់លោកនាយកមជ្ឈ-មណ្ឌលឯកសារកម្ពុជា ដែលបានផ្តល់ឱកាសឲ្យខ្ញុំបានមកចូលរួមក្នុងដំណើរការទស្សនកិច្ចសិក្សានេះ។ នេះគឺជាលើកដំបូងសម្រាប់ខ្ញុំដែលបានជិះរថភ្លើង។ ទោះបី ការធ្វើដំណើរនេះជួបការលំបាកបន្តិចមែន ប៉ុន្តែខ្ញុំទទួលបានបទពិសោធន៍ និងចំណេះដឹង អំពីរបបកម្ពុជាប្រជាធិបតេយ្យ។ របបនេះធ្វើឲ្យប្រជាជនកម្ពុជារស់នៅដោយរងទុក្ខវេទនា និងគ្មានសិទ្ធិអ្វីទាំងអស់។ ប្រជាជនជាច្រើនត្រូវបានជម្លៀសខ្លួនចេញពីផ្ទះសម្បែង តាមរថភ្លើង ដែលពិតជាជួបការលំបាកខ្លាំងណាស់ និងគ្មានអាហារហូបចុកគ្រប់គ្រាន់ឡើយ។ លើសពីនេះ ប្រជាជនយ៉ាងច្រើនត្រូវបានសម្លាប់យ៉ាងសាហាវព្រៃផ្សៃបំផុតដោយខ្មែរក្រហមចោទថា ក្បត់អង្គការ។

ចុងក្រោយ ខ្ញុំសំណូមពរឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាជួយផ្សព្វផ្សាយ និងបង្រៀនអំពីរបបខ្មែរក្រហមដល់កូនខ្មែរជំនាន់ក្រោយៗឲ្យបានដឹង។





អ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តត្បូងឃ្មុំចូលរួមទស្សនកិច្ចសិក្សាស្តីពីអំពើប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិប-តេយ្យ ដោយផ្តោតសំខាន់លើការជម្លៀសដោយបង្ខំក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



អ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តត្បូងឃ្មុំទស្សនកិច្ចសិក្សាប្រាសាទបន្ទាយឆ្មារ ស្ថិតនៅក្នុងស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# អ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តព្រៃវែង ចូលរួមទស្សនកិច្ចសិក្សាស្តីពី អំពើប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យ ដោយផ្តោតសំខាន់លើការជម្លៀសដោយបង្ខំក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩)

ផេង ពង្សរ៉ាស៊ី







អ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តព្រៃវែងចូលរួមទស្សនកិច្ចសិក្សាស្តីពី អំពើប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យ ដោយផ្តោតសំខាន់លើការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩) ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ដំណើរទស្សនកិច្ចអប់រំ គឺជាឱកាសដ៏ល្អសម្រាប់យុវជនក្នុងការសិក្សាស្រាវជ្រាវឲ្យកាន់តែទូលំទូលាយថែមទៀតពីប្រធានបទសិក្សារបស់ខ្លួន និងការទទួលបានបទពិសោធន៍ថ្មីៗ ទាក់ទងនឹងចំណេះដឹងពីវប្បធម៌ ទីតាំងភូមិសាស្ត្រ និងទំនាក់ទំនងអន្តរជនាន់ជាមួយមនុស្សដែលខ្លួនពុំធ្លាប់ស្គាល់ពីមុនមក ហើយក៏ជាឱកាសដែលយុវជនអាចចាប់យកជំនាញអ្វីមួយដែលខ្លួនបានទទួលពីដំណើរទស្សនកិច្ចអប់រំនេះ។

ពីថ្ងៃទី៣ ដល់ថ្ងៃទី៧ ខែមេសា ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង បានរៀបចំដំណើរទស្សនកិច្ចសិក្សាសម្រាប់យុវជនចំនួន៦៨ នាក់ ក្រោមប្រធានបទ«ផ្លូវរថភ្លើងខ្មែរក្រហម៖ ទស្សនកិច្ចអប់រំសម្រាប់យុវជនស្តីពីអំពើប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យ»។ យុវជនទាំងអស់ ត្រូវបានលើកទឹកចិត្តឲ្យសិក្សាឈ្វេងយល់ពីព្រឹត្តិការណ៍ជម្លៀស ឬការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំក្នុងដំណាក់កាលទីពីរតាមរថភ្លើងក្នុងរបបខ្មែរក្រហម ដែលព្រឹត្តិការណ៍នេះ គឺជាបុសគល់នៃ

ការរំលោភសិទ្ធិរស់រានរបស់មនុស្ស រាប់បញ្ចូលទាំងការធ្វើទារុណកម្ម សម្លាប់ បង្អត់អាហារ បំបែកបំបាក់ក្រុមគ្រួសារ និងធ្វើការហួសកម្លាំង។

យុវជនដែលចូលរួមនៅក្នុងដំណើរទស្សនកិច្ចសិក្សានេះ គឺជាអ្នកស្ម័គ្រចិត្តកម្ពុជាដែលធ្លាប់បានធ្វើការជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនាពេលកន្លងមក ក្នុងគម្រោងស្តីពី«ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម»។ កិច្ចការដែលយុវជនបានធ្វើ គឺជាកិច្ចការងារបម្រើដល់គោលបំណងនៃការចងចាំជារួមអំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ដែលបានកើតឡើងក្នុងចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ និងការសន្ទនាអន្តរជំនាន់រវាងអ្នកដែលកើតមុន និងក្រោយរបបខ្មែរក្រហម។

គោលដៅនៃដំណើរទស្សនកិច្ចអប់រំនេះ គឺទីតាំងឧក្រិដ្ឋកម្ម និងការដ្ឋានការងាររបស់ខ្មែរក្រហមមួយចំនួនដែលស្ថិតនៅក្នុងស្រុកភ្នំស្រុក ស្រុកព្រះនេត្រព្រះ និងសិរីសោភ័ណ្ឌ នៃខេត្តបន្ទាយមានជ័យ។ យុវជនទាំងអស់បានធ្វើដំណើរតាមរថភ្លើងពីរាជធានីភ្នំពេញនៅវេលាព្រឹកថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៤ ឆ្ពោះទៅកាន់ស្ថានីយរថភ្លើងក្រុងសិរីសោភ័ណ្ឌ ទីរួមខេត្តបន្ទាយមានជ័យ ហើយបន្តដំណើរតាមរថយន្តក្រុងពីថ្ងៃទី៥ដល់ថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៤ ទៅកាន់គោលដៅឧក្រិដ្ឋកម្ម និងការដ្ឋានការងាររបស់ខ្មែរក្រហម ដើម្បីជួបជាមួយសាក្សី និងអ្នកធ្លាប់មានបទពិសោធន៍ជម្លៀសក្រោមការបង្ខិតបង្ខំរបស់ខ្មែរក្រហម និងឈ្វេងយល់ពីទីតាំងប្រល័យពូជសាសន៍ខ្មែរក្រហមនៅនឹងមូលដ្ឋានផ្ទាល់តែម្តង។ ចំណែកនៅថ្ងៃទី៧ ខែឆ្នាំដដែល គឺជាពេលវេលាដែលក្រុមយុវជនទាំងអស់ត្រូវជួបសម្តែងការគួរសមជាមួយលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា នៅក្នុងសណ្ឋាគារ ហាយយ៉ាត់ រាជធានីភ្នំពេញ។ ក្នុងជំនួបនេះដែរ យុវជនតាមក្រុមនីមួយៗមានឱកាសក្នុងការបញ្ចេញសមត្ថភាព និងធ្វើបទបង្ហាញពីលទ្ធផលនៃដំណើរទស្សនកិច្ច បញ្ហាប្រឈម និងមេរៀនថ្មីៗដែលខ្លួនបានរៀននៅក្នុងដំណើរទស្សនកិច្ច ប្រាប់ទៅកាន់ក្រុមទាំងមូល។ លើសពីនេះទៀត យុវជនទាំងអស់ទទួលបានអនុសាសន៍ល្អៗពីលោក ឆាំង យុ ទាក់ទងនឹងការសិក្សា ការប្រកបអាជីពការងារ ជំនាញ និងការរស់នៅប្រចាំថ្ងៃ។ ដំណើរទស្សនកិច្ចសិក្សានេះ ទទួលបានការគាំទ្រយ៉ាងពេញទំហឹងពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ ហៅកាត់ថា USAID។

ទស្សនកិច្ចនេះមានគោលបំណងដូចខាងក្រោម គឺ៖

- ឈ្វេងយល់ពីបទពិសោធន៍របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ទាក់ទងនឹងការជម្លៀសដោយបង្ខំតាមរថភ្លើង។
- បង្កើនការយល់ដឹងអំពីប្រវត្តិសាស្ត្រផ្ទាល់មាត់របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលមិនទាន់ត្រូវបានកត់ត្រា ប្រមូលចងក្រង និងបោះពុម្ព។
- ផ្តល់ឱកាសដល់យុវជនឲ្យមកកាន់និងធ្វើដំណើរតាមរថភ្លើងដោយផ្ទាល់ ដើម្បីឈ្វេងយល់ពីការជម្លៀសដោយបង្ខំតាមផ្លូវរថភ្លើង និងលើកកម្ពស់ការចូលរួមតាមបែបប្រជាធិបតេយ្យ។

នៅដើមទសវត្សរ៍ឆ្នាំ១៩៧០ ខ្មែរក្រហមបានបង្កើតប្រវត្តិសាស្ត្រដែលមិនធ្លាប់មាននៅកម្ពុជា គឺការបង្ខំជម្លៀសប្រជាជនដែលធ្លាប់រស់នៅសុខសាន្តក្នុងលំនៅឋាន ភូមិ ឃុំ ស្រុក និងខេត្តកំណើតឲ្យចាកចេញពីផ្ទះសម្បែងដើម្បីចូលរួមបម្រើបដិវត្តន៍មហាលោតផ្លោះមហាអស្ចារ្យ។ ការជម្លៀសឬការផ្លាស់ប្តូរទីលំនៅប្រជាជនដោយបង្ខំនេះ គឺជាផែនការដែលក្រុមមេដឹកនាំខ្មែរក្រហមបានគិតទុក និងរៀបចំតាំងពីមុនថ្ងៃចូលកាន់កាប់ទីក្រុងភ្នំពេញរបស់ខ្មែរក្រហមនៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ មកម្ល៉េះ។ មេដឹកនាំកំពូលៗខ្មែរក្រហមយល់ឃើញថា មានតែការចល័តប្រជាជនពីកន្លែងមួយទៅកន្លែងមួយទេ ទើបការដឹកនាំប្រទេសរបស់ខ្លួនអាចជៀសផុតពីការបះបោរ





អ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តព្រៃវែងចូលរួមទស្សនកិច្ចសិក្សា ស្តីពី អំពើប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យ ដោយផ្តោតសំខាន់លើការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩) ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ប្រឆាំងពីសំណាក់សត្រូវ និងអាចធ្វើឲ្យការកសាង និងការការពារប្រទេសបានឿនលឿនទៅមុខ។ ផ្តើមចេញពីការជម្លៀសប្រជាជនដោយបង្ខំនេះ ព្រឹត្តិការណ៍ឃោរឃៅជាច្រើនទៀតត្រូវបានបង្កើតឡើងដោយមេដឹកនាំខ្មែរក្រហម ហើយព្រឹត្តិការណ៍ទាំងនោះបានបណ្តាលឲ្យជីវិតមនុស្សប្រមាណជាង ២លាន ២សែននាក់ស្លាប់ និងប្រជាជនរាប់លាននាក់ផ្សេងទៀតត្រូវទទួលរងនូវការធ្វើទុក្ខបុកម្នេញទាំងផ្លូវកាយ និងផ្លូវចិត្ត។ ប្រជាជនទូទាំងប្រទេសសុទ្ធតែជាសាក្សី និងជាជនរងគ្រោះនៃការជម្លៀសដោយបង្ខំ ដែលធ្វើឡើងតាមថ្មើរជើង និងតាមយានជំនិះផ្សេងៗ រួមមានរថភ្លើងជាដើម។ ការជម្លៀសដោយបង្ខំ បានធ្វើឲ្យជនរងគ្រោះទទួលរងការឈឺចាប់ធ្ងន់ធ្ងរទាំងផ្នែករូបរាងកាយ ផ្លូវចិត្ត និងសេចក្តីថ្លៃថ្នូរបស់មនុស្សជាតិ។ ការជម្លៀសដោយបង្ខំនេះត្រូវអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា លើកយកមកកាត់សេចក្តីដើម្បីដាក់បន្ទុកលើមេដឹកនាំជាន់ខ្ពស់នៃសម័យខ្មែរក្រហមឲ្យទទួលខុសត្រូវចំពោះបទល្មើសប្រឆាំងនឹងមនុស្សជាតិនៅក្នុងសំណុំរឿង ០០២/០១ ដោយបានផ្តន្ទាទោស នួន ជា និង ខៀវ សំផន ឲ្យជាប់ឃុំឃាំងអស់មួយជីវិត។

ខ្មែរក្រហមបានជម្លៀសប្រជាជនដោយបង្ខំជាបីដំណាក់កាល។ ដំណាក់កាលទី១ គឺបន្ទាប់ពីការចូលកាន់កាប់នៃកងទ័ពខ្មែរក្រហមនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ខែសីហា ឆ្នាំ ១៩៧៥។ ដំណាក់កាលទី២ គឺចាប់ពីខែកញ្ញា ឆ្នាំ១៩៧៥ ដល់ ចុងឆ្នាំ១៩៧៧។ នៅដំណាក់កាលនេះ ខ្មែរក្រហមបានជម្លៀសប្រជាជនចេញពីភូមិភាគកណ្តាល ភូមិភាគនិរតី ភូមិភាគបស្ចិម និងភូមិភាគបូព៌ា ឆ្ពោះទៅកាន់ខេត្តសៀមរាប (តំបន់១០៦) ខេត្តព្រះវិហារ (តំបន់១០៣) និងភូមិភាគពាយ័ព្យ រួមមាន ខេត្តបាត់ដំបង ពោធិ៍សាត់ និងបន្ទាយមានជ័យ។ ដំណាក់កាលទី៣ គឺជាការផ្លាស់ទីលំនៅប្រជាជនពីភូមិភាគបូព៌ា ចាប់ពីចុងឆ្នាំ១៩៧៧ រហូតដល់ចុងឆ្នាំ១៩៧៨។ នៅដំណាក់កាលចុងក្រោយនៃរបបរបស់ខ្លួន ខ្មែរក្រហមខ្លួនឯង បានប្រើប្រាស់រថភ្លើងដើម្បីរត់ភៀសខ្លួនទៅភាគពាយ័ព្យនៃប្រទេសកម្ពុជា ដើម្បីបន្តការតស៊ូដើម្បីកាន់អំណាចឡើងវិញ។

នៅគ្រប់ដំណាក់កាលនៃការជម្លៀសប្រជាជនរបស់ខ្មែរក្រហម រថភ្លើង គឺជាមធ្យោបាយដឹកជញ្ជូនដ៏សំខាន់ក្នុងការដឹកជញ្ជូនមនុស្សទៅកាន់ខេត្តពោធិ៍សាត់ និងបាត់ដំបង ក្នុងភូមិភាគពាយ័ព្យ។ ប្រជាជនត្រូវបានបង្ខំឲ្យជិះនៅក្នុងទូររថភ្លើងដោយមានភាពចង្អៀត និងគ្មានកន្លែងអង្គុយ។ លើសពីនេះទៀត អ្នកជម្លៀសពុំទទួលបានការហូបចុក និងសេវាថែទាំសុខភាពនៅអំឡុងពេលជម្លៀសឡើយ។ អ្នក

ជម្លៀសមួយចំនួនបានស្លាប់ក្នុងពេលធ្វើដំណើរ ហើយសាកសពរបស់អ្នកទាំងនោះ ត្រូវកងកម្លាំងខ្មែរក្រហមបោះចោលតាមបង្អួច ទៅក្នុងព្រៃដែលដុះនៅសងខាងផ្លូវរថភ្លើង។

## អំពីរថភ្លើង

យោងតាមគេហទំព័រផ្លូវការរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន នៃព្រះរាជាណាចក្រកម្ពុជា ផ្លូវដែកកម្ពុជាបានចាប់ផ្តើមសាងសង់ដំបូងពីក្នុងទសវត្សរ៍ឆ្នាំ១៩៣០ រហូតដល់ទសវត្សរ៍ឆ្នាំ១៩៤០ ដោយសាងសង់ជាផ្លូវដែកចំនួន២ខ្សែ គឺខ្សែភាគខាងជើង និងខ្សែភាគខាងត្បូង ដែលមានប្រវែងសរុប៦៥០ គីឡូម៉ែត្រ។ ផ្លូវដែកភាគខាងជើងមានប្រវែង ៣៨៦ គីឡូម៉ែត្រ ពីភ្នំពេញ ទៅដល់ប៉ោយប៉ែត (ព្រំដែនកម្ពុជា-ថៃ) ត្រូវបានកសាងឡើងចាប់ពីឆ្នាំ១៩២៩ ដល់ឆ្នាំ១៩៤២ ក្នុងសម័យអាណានិគមបារាំង។ ចំណែកផ្លូវដែកភាគខាងត្បូងត្រូវបានកសាងឡើងក្នុងចន្លោះឆ្នាំ១៩៦០ ដល់ឆ្នាំ១៩៦៩ ក្នុងសម័យសង្គមរាស្ត្រនិយម ក្រោមព្រះរាជកិច្ចដឹកនាំរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ ក្រោមជំនួយរបស់ប្រទេសបារាំង អាល្លឺម៉ង់ខាងលិច និងចិន ដែលមានប្រវែងសរុប ២៦៤គីឡូម៉ែត្រ។ ផ្លូវដែកទាំងពីរខ្សែនេះ បានទទួលរងការខូចខាតយ៉ាងធ្ងន់ធ្ងរ ហើយផ្នែកខ្លះត្រូវបានបំផ្លាញទាំងស្រុងដោយរបបកម្ពុជាប្រជាធិបតេយ្យ។ បច្ចុប្បន្ន ផ្លូវដែកទាំងពីរខ្សែ ត្រូវបានសាងសង់ និងជួសជុលដាក់ឱ្យប្រើប្រាស់ឡើងវិញ តាមរយៈការសហការរវាងក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រុមហ៊ុន រ៉ូយ៉ាល់ រេលវេ កម្ពុជា (RRC) ដើម្បីផ្តល់ និងសម្រួលដល់សេវាដឹកជញ្ជូនក្នុងប្រទេសកម្ពុជា។

ទូររថភ្លើងដែលបន្សល់ទុកតាំងពីមុនរបបសង្គមរាស្ត្រនិយម បានផ្តល់ដល់មនុស្សនូវអារម្មណ៍ខុសៗគ្នាតាមសម័យកាល និងតាមការដឹកនាំរបស់មេដឹកនាំប្រទេស។ មានប្រជាជនមិនតិចនាក់ទេ ជាពិសេសអ្នកដែលមានបទពិសោធន៍ជិះរថភ្លើង បានបង្ហាញឱ្យដឹងពីអារម្មណ៍ពេញចិត្ត ស្ងប់ ខ្លាចរអា សប្បាយរីករាយ និងតក់ស្លុតចំពោះរថភ្លើងនៅកម្ពុជា។ ស្ថិតក្នុងសម័យសង្គមរាស្ត្រនិយម ខ្សែរថភ្លើងទាំងអស់ទទួលបានការពេញចិត្តពីសំណាក់ប្រជាជនគ្រប់ស្រទាប់វណ្ណៈ។ ការធ្វើដំណើរយ៉ាងពេញនិយមតាមរថភ្លើងនាពេលនោះបានផ្តល់នូវភាពងាយស្រួលមានសុវត្ថិភាព និងបន្ធូរបន្ថយការចំណាយរបស់ប្រជាជន។

ចំណែកនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យវិញ ខ្សែរថភ្លើងដដែលនេះ ដើរតួនាទីយ៉ាងសំខាន់ក្នុងការដឹកជញ្ជូនប្រជាជនកម្ពុជារាប់ម៉ឺននាក់ចេញពីទីក្រុង និងទីកន្លែងដទៃទៀតនៃប្រទេសកម្ពុជា ឆ្ពោះទៅកាន់គោលដៅដែលខ្មែរក្រហមបានកំណត់ ដោយគ្មាននរណាម្នាក់ដឹងខ្លួនជាមុនឡើយថា ជីវិតខ្លួននឹងមានភាពជុយស្រួយក្នុងការបាត់បង់ ដោយសារតែការសម្លាប់ និងធ្វើការហួសកម្លាំង។ ការផ្ទេរប្តូរលំនៅដោយបង្ខំនេះ គឺដើម្បីបម្រើដល់ផែនការកសាងប្រទេស មហាលោតផ្លោះ មហាអស្ចារ្យ តាមរបៀបនៃការចូលរួមអភិវឌ្ឍន៍លើវិស័យកសិកម្មដែលជាវិស័យអត្ថិភាពរបស់ខ្មែរក្រហម។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលធ្លាប់ត្រូវខ្មែរក្រហមជម្លៀសតាមរថភ្លើង នៅតែមានអារម្មណ៍តក់ស្លុតភ័យខ្លាច និងឈឺចាប់ ទោះបីជាបទពិសោធន៍នេះបានកន្លងផុតទៅជិត៥០ឆ្នាំហើយក៏ដោយ។

ស្ថិតក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ និង១៩៩០ ការធ្វើដំណើរតាមរថភ្លើង តែងទទួលរងនូវការគំរាមកំហែងជាដរាបពីសំណាក់ទ័ពព្រៃខ្មែរក្រហម។ នៅខែកក្កដា ឆ្នាំ១៩៩៤ កម្លាំងទ័ពព្រៃខ្មែរក្រហមបានពួនស្ទាក់វាយខ្សែរថភ្លើងនៅចំណុចប្រមាណ ១០គីឡូម៉ែត្រភាគខាងកើតទីក្រុងកំពត និងបានសម្លាប់អ្នកដំណើរជនជាតិខ្មែរចំនួន១៣នាក់ ព្រមទាំងបានចាប់ខ្លួនជនបរទេសចំនួន៣នាក់ ហើយបានសម្លាប់ជនបរទេសទាំងនោះចោលក្នុងរយៈពេល២ខែក្រោយមក។ មិនត្រឹមតែប៉ុណ្ណោះ ប្រជាជនរាប់រយពាន់នាក់ទៀត បានស្លាប់ដោយសារតែអំពើប្លន់

រថភ្លើង ជាពិសេសអ្នករកស៊ីជួញដូរពីខេត្តបាត់ដំបង បន្ទាយមានជ័យ មកកាន់រាជធានីភ្នំពេញ។ ព្រឹត្តិការណ៍ទាំងអម្បាលមាណនេះ បានធ្វើឲ្យប្រជាជនកម្ពុជាបាក់ស្បាត និងខ្លាចរអារចំពោះការធ្វើដំណើរតាមរថភ្លើង ហើយក៏មិនចង់រំឭកពីប្រវត្តិរឿងរ៉ាវទាំងអស់ប្រាប់កូនចៅជំនាន់ក្រោយឲ្យបានដឹងដែរ។

បន្ទាប់ពីរយៈពេលជាង៤០ឆ្នាំ ក្រោយការដួលរលំរបបខ្មែរក្រហម និងសង្គ្រាមរ៉ុាំរ៉ៃនៅកម្ពុជា រាជរដ្ឋាភិបាលកម្ពុជា បានដាក់ឲ្យប្រើប្រាស់ផ្លូវរថភ្លើងឡើងវិញ។ ទូររថភ្លើងទាំងប៉ុន្មាន ត្រូវបានជួសជុល និងរៀបចំដើម្បីដាក់បម្រើដល់សេចក្តីត្រូវការក្នុងការដឹកជញ្ជូនមនុស្ស និងសម្ភារបរិក្ខារផ្សេងៗទៅនិងមកទីក្រុងភ្នំពេញ។ ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចតេជោ ហ៊ុន សែន បានប្រកាសនៅថ្ងៃសម្ពោធដាក់ឲ្យប្រើប្រាស់ផ្លូវរថភ្លើង ថា «ដោយសារប្រទេសយើងមានសន្តិភាពពេញលេញ យើងមានឱកាសក្នុងការស្តាបនាហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនឡើងវិញ»។





អ្នកស្ម័គ្រចិត្តកម្ពុជាមកពីខេត្តព្រៃវែងទស្សនកិច្ចសិក្សាប្រាសាទបន្ទាយឆ្មារ ស្ថិតនៅក្នុងស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# មជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានរៀបចំដំណើរ ទស្សនកិច្ចសិក្សាតាមផ្លូវរថភ្លើងខ្មែរក្រហម ស្តីអំពី«ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និង លទ្ធិប្រជាធិបតេយ្យ» សម្រាប់យុវជនខេត្តពោធិ៍សាត់ចំនួន១០២នាក់

**ឡុង ដានី**



ចន្លោះពីថ្ងៃទី២ ដល់ថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៤ មជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានរៀបចំដំណើរទស្សនកិច្ចសិក្សាតាមផ្លូវរថភ្លើងខ្មែរក្រហម ស្តីអំពី «ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យ» សម្រាប់យុវជនខេត្តពោធិ៍សាត់ចំនួន១០២នាក់ ដោយផ្តោតលើប្រធានបទ ការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩)។ (ទាវ សម្ភស្ស/មជ្ឈមណ្ឌលឯកសារកម្ពុជា)





ចន្លោះពីថ្ងៃទី២ ដល់ថ្ងៃទី ០៦ ខែមេសា ឆ្នាំ ២០២៤ មជ្ឈមណ្ឌលផ្សះផ្សាវាលវែងបានរៀបចំដំណើរទស្សនកិច្ចសិក្សាតាមផ្លូវរថភ្លើងខ្មែរក្រហម ស្តីអំពី «ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យ» សម្រាប់យុវជនខេត្តពោធិ៍សាត់ចំនួន១០២នាក់ លើប្រធានបទ ការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩)។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ខ្មែរក្រហមបានជម្លៀសប្រជាជនដោយបង្ខំមានបីដំណាក់កាលធំៗគឺៈ ១) ការជម្លៀសប្រជាជនដោយបង្ខំចេញពីផ្ទះសម្បែងរបស់ខ្លួននៅទីក្រុងភ្នំពេញ និងទីប្រជុំជននានាទៅតាមទីជនបទដាច់ស្រយាលក្នុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ២) ការជម្លៀសប្រជាជនដោយបង្ខំតាមរថភ្លើងចាប់ពីខែកញ្ញា ឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៧ ពីភូមិភាគនិរតី ភូមិភាគបស្ចិម ឆ្ពោះទៅកាន់ភូមិភាគពាយ័ព្យ (បច្ចុប្បន្នខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តប៉ៃលិន)។ និងការផ្លាស់ទីប្រជាជនទៅតាម



ចន្លោះពីថ្ងៃទី២ ដល់ថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៤ មជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានរៀបចំដំណើរទស្សនកិច្ចសិក្សាតាមផ្លូវរថភ្លើងខ្មែរក្រហម ស្តីអំពី «ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យ» សម្រាប់យុវជនខេត្តពោធិ៍សាត់ចំនួន១០២នាក់ ដោយផ្តោតលើប្រធានបទ ការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩)។
(ទាវ សម្កស្ស/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ទីជនបទក្នុងភូមិភាគកណ្តាល ភូមិភាគនិរតី ភូមិភាគបស្ចិម ភូមិភាគបូព៌ា ចាប់ពីចុងឆ្នាំ១៩៧៥ ទៅកាន់ផ្នែកដទៃៗទៀតនៃប្រទេសកម្ពុជា។ ៣) ការជម្លៀសប្រជាជនភូមិភាគបូព៌ាដោយបង្ខំទៅកាន់ភូមិភាគពាយ័ព្យ និងភូមិភាគកណ្តាលក្នុងឆ្នាំ១៩៧៧ និង ១៩៧៨។

គោលបំណងនៃដំណើរទស្សនកិច្ចសិក្សាមានដូចខាងក្រោម៖ ១) ឈ្វេងយល់ពីបទពិសោធន៍របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមអំពីការជម្លៀសដោយបង្ខំតាមផ្លូវរថភ្លើង។ ជាពិសេសខ្មែរក្រហមបានជម្លៀសប្រជាជនដោយបង្ខំក្នុងដំណាក់កាលទី២ តាមផ្លូវរថភ្លើងចាប់ពីខែកញ្ញា ឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៧ ដោយជម្លៀសចេញពីភូមិភាគនិរតី ភូមិភាគបស្ចិម ឆ្ពោះទៅកាន់ភូមិភាគពាយ័ព្យ (បច្ចុប្បន្នខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តប៉ៃលិន)។ យោងតាមឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាដែលបន្សល់ទុកពីរបបខ្មែរក្រហមបានបង្ហាញឲ្យដឹងថា ប្រជាជនចន្លោះពី៤សែនទៅ៥សែននាក់ ត្រូវបានខ្មែរក្រហមបញ្ជូនទៅកាន់ភូមិភាគពាយ័ព្យ ហើយប្រជាជនប្រមាណ៥ម៉ឺននាក់ទៀត ត្រូវជម្លៀសចេញពីភូមិភាគបូព៌ា រួមមាន ខេត្តព្រៃវែង និងខេត្តស្វាយរៀង។ បុគ្គលិកធ្វើការនៅស្ថានីយរថភ្លើង ពិតជាបានឃើញប្រជាជនរាប់ម៉ឺននាក់ ត្រូវបានជម្លៀសតាមខ្សែរថភ្លើងចេញពីភ្នំពេញ ឆ្ពោះទៅកាន់ស្ថានីយរថភ្លើងផ្សេងៗ ដូចជាខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបងនៃភូមិភាគពាយ័ព្យ។ ២) បង្កើនការយល់ដឹងអំពីរឿងរ៉ាវអ្នករស់រានមានជីវិតរបបខ្មែរក្រហមតាមរយៈប្រវត្តិសាស្រ្តផ្ទាល់មាត់។ តាមរយៈដំណើរទស្សនកិច្ចសិក្សានេះ យុវជននឹងមានឱកាសជួបសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅតាមទីតាំងឧក្រិដ្ឋកម្មដែលប្រព្រឹត្តិដោយរបបខ្មែរក្រហមមួយចំនួននៅក្នុងស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ និងស្រុកកណ្តៀង ខេត្តពោធិ៍សាត់។ ៣) ផ្តល់ឱកាសដល់យុវជន



ចន្លោះពីថ្ងៃទី២ ដល់ថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៤ មជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានរៀបចំដំណើរទស្សនកិច្ចសិក្សាតាមផ្លូវរថភ្លើងខ្មែរក្រហម ស្ដីអំពី «ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យ» សម្រាប់យុវជនខេត្តពោធិ៍សាត់ចំនួន១០២នាក់ ដោយផ្ដោតលើប្រធានបទ ការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩)។
(ទាវ សម្ផស្ស/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ដើម្បីឈ្វេងយល់ពីផ្លូវរថភ្លើង និងការធ្វើដំណើរតាមរថភ្លើង ដើម្បីលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ។ រថភ្លើង គឺជាមធ្យោបាយដឹកជញ្ជូនដ៏មានប្រជាប្រិយមួយក្នុងមធ្យោបាយដឹកជញ្ជូនផ្សេងៗទៀត ពីព្រោះការធ្វើដំណើរ ឬដឹកជញ្ជូនតាមរថភ្លើងមានតម្លៃថោក និងផ្ទុកបានចំនួនច្រើន ហើយផ្ដល់ផលប៉ះពាល់ដល់បរិស្ថានតិចតួចៗ រថភ្លើងក៏ជានិមិត្តរូបនៃចលនាតស៊ូដើម្បីសេរីភាពតាមគោលការណ៍អហិង្សារបស់មេដឹកនាំឥណ្ឌាឈ្មោះ មហាត្មៈ គន្ធី ដែលបាននាំប្រទេសឥណ្ឌាទទួលបានឯករាជ្យពីចក្រភពអង់គ្លេស និងបានក្លាយទៅជាប្រទេសប្រជាធិបតេយ្យមួយនៅលើពិភពលោក។

ខាងក្រោមនេះគឺជាចំណាប់អារម្មណ៍របស់អ្នកស្ម័គ្រចិត្តកម្ពុជា ដែលបានចូលរួមក្នុងដំណើរទស្សនកិច្ចសិក្សាតាមផ្លូវរថភ្លើងខ្មែរក្រហម៖

នាងខ្ញុំឈ្មោះ **ឌួច ស្រីពេជ្រ** អាយុ១៨ឆ្នាំ រស់នៅភូមិ ប្រម៉ោយ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ ។ ខ្ញុំពិតជាមានអារម្មណ៍រីករាយជាខ្លាំង នៅពេលដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំនៅកម្មវិធីដំណើរទស្សនកិច្ចសិក្សាទាក់ទងនិងអំពើប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យ ដែលដំណើរទស្សនកិច្ចសិក្សាចេញពីទីក្រុងភ្នំពេញទៅខេត្តពោធិ៍សាត់ និង ខេត្តបន្ទាយមានជ័យ។ ដំណើរទស្សនកិច្ចមួយនេះ បានធ្វើឲ្យខ្ញុំយល់ដឹងយ៉ាងច្រើនអំពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម។ នៅក្នុងដំណើរទស្សនកិច្ចនេះ ខ្ញុំក៏បានជួបសម្ភាសន៍ជាមួយនឹងលោកអ៊ំប្រុសម្នាក់ឈ្មោះ ឈុន ឡុំា មានអាយុ៧០ឆ្នាំ រស់នៅក្នុងភូមិព្រីងខ្ពស់ ឃុំស្រែស្តុក ស្រុកកណ្ដៀង ខេត្តពោធិ៍សាត់ អ៊ំប្រុសបាននិយាយថា នៅពេលដែលខ្មែរក្រហមបានចូលមកដល់ អ៊ំមានអាយុ

ប្រហែល២០ឆ្នាំ ដំបូងៗខ្មែរក្រហមបានផ្តល់នូវស្បៀង និងម្ហូបអាហារឲ្យគ្រប់គ្រាន់តែមួយខែក្រោយមក ខ្មែរក្រហមបែរជាមិនមានការផ្គត់ផ្គង់ដូចមុនៗ ប្រជាជនគ្មានអាហារសម្រាប់បរិភោគ អង្គការផ្តល់ឲ្យត្រឹមតែបបរ និងគ្មានម្ហូបសម្រាប់បរិភោគថែមទៀតៗ លើសពីនេះទៅទៀត ខ្មែរក្រហមបានបំបែកបំបាក់គ្រួសារ ឪពុកម្តាយកូន ឲ្យព្រាត់ពីគ្នា ឲ្យក្មេងៗដើររើសអាចម៍គោ និងកាប់ទន្ទ្រានខែត្រសម្រាប់ធ្វើជីៗ កុមារក្នុងរបបខ្មែរក្រហមមិនមានសាលារៀនសូត្រៗ រីឯអ្នកមានវ័យពេញកម្លាំងឲ្យទៅកាប់ដី និង ធ្វើ ស្រែក្នុងពេលថ្ងៃ ចំណែកពេលយប់ត្រូវកាន់កាំភ្លើងយាមល្បាតៗ ចំណែកចាស់ៗគឺខ្មែរក្រហមឲ្យនៅដាំដំណាំដូចជា ពោត បន្លែ ជាដើម សម្រាប់ផ្គត់ផ្គង់នៅក្នុងការដ្ឋានៗ បន្ថែមទៀតនោះ ខ្មែរក្រហម បានណែនាំឲ្យប្រជាជនឲ្យជឿលើអង្គការតែម្នាក់គត់ ដោយឲ្យបងប្អូនសម្លាប់គ្នា កូនមិនស្គាល់ម្តាយៗ នៅពេលដែលខ្ញុំបានស្តាប់នូវរឿងរ៉ាវ ដែលអ៊ំប្រុសបានរៀបរាប់ ខ្ញុំពិតជាមានអារម្មណ៍សោកស្តាយជា ខ្លាំងដែលប្រទេសជាតិយើងទទួលរងនូវរបបដ៏ឃោរឃៅមួយនេះៗ ជាចុងក្រោយ នាងខ្ញុំសូមអរគុណ ដល់ មជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានផ្តល់ឱកាសដល់រូបនាងខ្ញុំបានចូលរួមដំណើរទស្សនកិច្ច និង បានសិក្សាឈ្វេងយល់នូវរបបខ្មែរក្រហម ហើយខ្ញុំ និង យកនូវរឿងរ៉ាវដែលខ្ញុំបានចេះដឹង ទាំងប៉ុន្មានចងក្រងជាឯកសារទុកសម្រាប់ ប្អូនៗជំនាន់ក្រោយបានដឹងពុ និងចេះ ឈឺចាប់នៅក្នុងរបបខ្មែរក្រហម ដើម្បីជាការការពារកុំឲ្យមានរបបខ្មែរក្រហមកើតឡើងមកម្តងទៀតៗ

នាងខ្ញុំឈ្មោះ **ប៉ុន បញ្ញា** ភេទស្រី អាយុ១៩ឆ្នាំ បន្ទាប់ពីបានធ្វើដំណើរទស្សនកិច្ចតាមរថភ្លើង ខ្ញុំមានអារម្មណ៍រំភើបនិងសប្បាយរីករាយ ប៉ុន្តែក៏មានអារម្មណ៍សោកស្តាយ នូវព្រឹត្តិការណ៍ដែលបានកើតឡើងលើប្រជាជនកម្ពុជា ក្នុងពេលដែលខ្មែរក្រហមបានជម្លៀសប្រជាជនដោយបង្ខំតាមរថភ្លើងៗ មួយវិញទៀតខ្ញុំទទួលបានចំណេះដឹងជាច្រើនបន្ថែមទៀតពីរឿងរ៉ាវដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានដឹងពីការ ឈឺចាប់ ទុក្ខលំបាក ការបង្អត់អាហារ ធ្វើការងារហួសកម្លាំងគ្មានពេលវេលាសម្រាក ការធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរដែលខ្មែរក្រហមបានធ្វើមកលើប្រជាជនកម្ពុជា ទាំងមូលៗ ជាពិសេសខ្មែរក្រហម បានបំបែកបំបាក់កុមារតូចៗចេញពីឪពុកម្តាយ ធ្វើឲ្យកុមារខ្វះភាពកក់ក្តៅ និងមិនទទួលបានការរៀនសូត្រៗ ខ្ញុំនៅតែចងចាំក្នុងចិត្ត ព្រោះវាគឺជាភាពឈឺចាប់ពេញមួយជីវិតរបស់ប្រជាជនខ្មែរគ្រប់រូបដែលធ្លាប់បានឆ្លងកាត់រឿងរ៉ាវដែលបានកើតឡើងក្នុងរបបខ្មែរក្រហមៗ ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានបង្កើតឲ្យមានកម្មវិធីទស្សនកិច្ចតាមរថភ្លើង ដើម្បីឲ្យរូបនាងខ្ញុំក៏ដូចជាយុវជនដទៃទៀតទទួលបានចំណេះដឹងនិងបានឈ្វេងយល់ពីប្រវត្តិសាស្ត្រកាន់តែច្បាស់ៗ

ខ្ញុំបាទឈ្មោះ **ស៊ន សុផល** អាយុ២៤ឆ្នាំ រស់នៅភូមិទំព័រ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ៗ ខ្ញុំរីករាយណាស់ដែលបានចូលរួមដំណើរទស្សនកិច្ចសិក្សាឈ្វេងយល់តាម ផ្លូវរថភ្លើងខ្មែរក្រហម ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា លើប្រធានបទ ការជម្លៀសប្រជាជនដោយបង្ខំដំណាក់កាល ទី២ (ពីឆ្នាំ១៩៧៥-១៩៧៩)ៗ នៅក្នុងដំណើរទស្សនកិច្ចនេះ បានធ្វើឲ្យខ្ញុំយល់កាន់តែច្បាស់ ព្រោះបានឃើញផ្ទាល់នៅទីតាំងភូមិសាស្ត្រដែលបានបន្សល់ទុកពីរបបខ្មែរក្រហម ព្រមទាំងសាក្សីរស់ គឺអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមៗ ចំពោះអារម្មណ៍ផ្ទាល់របស់ខ្ញុំបន្ទាប់ពីបានធ្វើដំណើរទស្សនកិច្ច និង បានសម្ភាសន៍ លោកយាយលោកតា ដែលបាន រស់រានមានជីវិតពីរបបខ្មែរក្រហមៗ ខ្ញុំពិតជាសោកស្តាយស្រណោះចំពោះអាយុជីវិតរបស់ប្រជាជនខ្មែរដែល ទទួលរងទារុណកម្មដ៏សាហាវព្រៃផ្សៃក្នុងរបបខ្មែរក្រហមៗ ក្នុងនាមខ្ញុំជាកូនខ្មែរមួយរូប ខ្ញុំមិនចង់ឲ្យប្រទេសកម្ពុជាមានរបបខ្មែរក្រហមកើតឡើងម្តងទៀតទេៗ

# មជ្ឈមណ្ឌលឯកសារកោះថ្មចុះពិនិត្យ និងវាយតម្លៃវេទិកាថ្នាក់រៀនស្ដីពី

## «ការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍» នៅវិទ្យាល័យ ហ៊ុន សែន ស្នួល

ឈុំ រ៉ា



មជ្ឈមណ្ឌលឯកសារកោះថ្មចុះពិនិត្យ និងវាយតម្លៃវេទិកាថ្នាក់រៀនស្ដីពី «ការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍» នៅវិទ្យាល័យ ហ៊ុន សែន ស្នួល។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





នៅព្រឹកថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៤ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មបានចុះជួបសិស្សនៅវិទ្យាល័យ ហ៊ុន សែន ស្នួល ចំនួន៥នាក់ ក្នុងនោះមានសិស្សស្រីចំនួន៣នាក់ ដែលធ្លាប់បានចូលរួមវេទិកាថ្នាក់រៀនស្ដីពី«ការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍» នៅមជ្ឈមណ្ឌលឯកសារកោះថ្មកន្លងមក ដោយមានការសម្របសម្រួល និងស្វាគមន៍យ៉ាងកក់ក្ដៅពី លោកនាយក និងលោកគ្រូ-អ្នកគ្រូ នៅវិទ្យាល័យ ហ៊ុន សែន ស្នួល។

គោលបំណងនៃការចុះមកជួបសិស្សពេលនេះ គឺដើម្បីត្រួតពិនិត្យ និងវាយតម្លៃពីការអនុវត្តសកម្មភាពវេទិកាថ្នាក់រៀនស្ដីពី «ការសិក្សាប្រវត្តិ-សាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍» កន្លងមក ជាពិសេសដើម្បីវាស់វែងពីប្រសិទ្ធភាពការងារ និងកំណើនចំណេះដឹងរបស់សិស្សទាក់ទង ១) ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និង ២) វិធីសាស្ត្រទប់ស្កាត់អំពើ

ហិង្សា ឬអំពើប្រល័យពូជសាសន៍។ ការចូលរួមរបស់សិស្សនៅក្នុងដំណើរការត្រួតពិនិត្យ និងវាយតម្លៃនាពេលនេះ គឺជាការបង្ហាញឲ្យឃើញពីប្រសិទ្ធភាពនៃការបង្រៀន និងចំណេះដឹងកើនឡើងដែលបានមកពីសកម្មភាពចូលរួមក្នុងវេទិកាថ្នាក់រៀន និងបញ្ចេញសមត្ថភាពផ្ទាល់ខ្លួនរបស់សិស្សក្នុងការបំពេញកម្រងសំណួរមួយចំនួន ដូចខាងក្រោម ៖

១) តើប្អូនបានចូលរួមវេទិកាថ្នាក់រៀនស្តីពី «ការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍» រៀបចំដោយមជ្ឈមណ្ឌលឯកសារកោះថ្មប៉ុន្មានដង?

២) តើប្អូនមានចំណេះអ្វីខ្លះពីប្រវត្តិសាស្ត្រខ្មែរក្រហម?

៣) តើប្អូននៅចងចាំអ្វីខ្លះពី «វិធីសាស្ត្រទប់ស្កាត់អំពើហិង្សា ឬអំពើប្រល័យពូជសាសន៍?

៤) បន្ទាប់ពីបានចូលរួមវេទិកាថ្នាក់រៀនរួច តើប្អូនធ្លាប់បានលើកយកមេរៀនប្រវត្តិសាស្ត្រខ្មែរក្រហម និងវិធីទប់ស្កាត់អំពើហិង្សាមកនិយាយ ឬពិភាក្សាដែរឬទេ?

៥) បន្ទាប់ពីបានចូលរួមវេទិកាថ្នាក់រៀនរួច តើប្អូនគិតថា ចំណេះដឹងដែលប្អូនទទួលបានពី «វេទិកាថ្នាក់រៀន» នេះ អាចជួយអ្វីខ្លះដល់ប្អូន?

៦) តើប្អូនមានសំណូមពរអ្វីខ្លះចំពោះការអនុវត្តកម្មវិធី «វេទិកាថ្នាក់រៀន» នេះនាពេលអនាគត?

នៅក្នុងឱកាសនោះ លោក ឡុង ដានី នាយកមជ្ឈមណ្ឌលឯកសារកោះថ្ម ក៏ធ្វើការណែនាំបន្ថែមដល់សិស្សឈ្មោះ ទិត តុលា, ខៀវ ម៉ាលី, នី ម៉ីលី, ឈួន ណារីតា និង ឈន ដានុត ដែលបានចូលរួមកម្មវិធីត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តសកម្មភាពគម្រោងវេទិកាថ្នាក់រៀនស្តីពី «ការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍» ឲ្យអានសំណួរស្ទាបស្ទង់មតិខាងលើឲ្យយល់ច្បាស់មុននឹងឆ្លើយសំណួរ។

បន្ទាប់ពីចប់កម្មវិធីត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តសកម្មភាពគម្រោងវេទិកាថ្នាក់រៀនស្តីពី «ការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍» យើងសង្កេតឃើញថា សិស្សទទួលបានចំណេះដឹងច្រើនពីវេទិកាថ្នាក់រៀនកន្លងមក។







មជ្ឈមណ្ឌលឯកសារកោះថ្មចុះពិនិត្យ និងវាយតម្លៃវេទិកាថ្នាក់រៀនស្តីពី «ការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិប-តេយ្យ និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍» នៅវិទ្យាល័យ ហ៊ុន សែន ស្នួល។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមកពីឃុំព្រះរំកិល ស្រុកបុរីអូរស្វាយសែន ជ័យ ទទួលបានការពិនិត្យសុខភាពបឋម

សាំង ចិន្តា



ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារកម្ពុជា សហការជាមួយរដ្ឋបាលស្រុកបុរីអូរស្វាយ សែនជ័យ ខេត្តស្ទឹងត្រែង និងមន្ទីរពេទ្យ ខេរី ត្បូងឃ្មុំ រៀបចំវេទិកាពិនិត្យសុខភាពបឋមជូនដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម សរុបចំនួន២០០នាក់ នៅមណ្ឌលសុខភាពព្រះរំកិល នៅឃុំព្រះរំកិល ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





ចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៥ ខែមេសា ឆ្នាំ ២០២៤ មជ្ឈមណ្ឌលឯកសារកម្ពុជា សហការជាមួយរដ្ឋបាលស្រុកបុរីអូរស្វាយ សែនជ័យ ខេត្តស្ទឹងត្រែង និងមន្ទីរពេទ្យ ខេរី ត្បូងឃ្មុំ រៀបចំវេទិកាពិនិត្យសុខភាពបឋមជូនដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម សរុបចំនួន២០០នាក់ នៅមណ្ឌលសុខភាពព្រះរំកិល នៅឃុំព្រះរំកិល ស្រុកបុរីអូរស្វាយសែនជ័យ។ វេទិកាពិនិត្យសុខភាពបឋម ដែលប្រព្រឹត្តទៅអស់រយៈពេល៣ថ្ងៃ គឺចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៥ ខែមេសា នេះ ធ្វើឡើងក្នុងគោលបំណងដើម្បីផ្តល់ការពិនិត្យសុខភាពបឋម ជូនដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលរស់នៅទីដាច់ស្រយាល និងកំពុងប្រឈមបញ្ហាសុខភាព និងផ្តល់ការណែនាំអំពីការថែទាំសុខភាព។

ជាកិច្ចចាប់ផ្តើម លោកស្រី សម្បត្តិ រចនា អភិបាលរងនៃគណៈអភិបាលស្រុកបុរីអូរស្វាយសែនជ័យ មានមតិបើកវេទិកាដោយបាននិយាយបញ្ជាក់អំពីសារសំខាន់នៃការដឹងអំពីស្ថានភាពសុខភាព និងរបៀបថែទាំសុខភាពរបស់ខ្លួន ដែលលោកតា លោកយាយ អ៊ំប្រុស អ៊ំស្រី សុទ្ធតែជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលរស់នៅ

ឆ្លងកាត់ទុក្ខលំបាកនៃសង្គ្រាម និងរបបប្រល័យពូជសាសន៍ខ្មែរក្រហម។ លោកស្រីអភិបាលរងនៃគណៈអភិបាលស្រុកបន្តថា ការមកពិនិត្យសុខភាពនាពេលនេះ គឺពិតជាមានសារសំខាន់សម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលកំពុងតែឈានចូលវ័យចាស់ជរា។ ជាចុងបញ្ចប់ លោកស្រីអភិបាលរងនៃគណៈអភិបាលស្រុក ថ្លែងអំណរគុណដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា និងវេជ្ជបណ្ឌិតមកពីមន្ទីរពេទ្យ ខេវី ត្បូងឃ្មុំ ដែលធ្វើដំណើរមកដល់ទីតាំងផ្ទាល់ដើម្បីផ្តល់ការពិនិត្យសុខភាពបឋម និងការណែនាំអំពីការថែទាំសុខភាពនៅមូលដ្ឋាន គឺនៅមណ្ឌលសុខភាពព្រះរំកិលនេះតែម្តង។

បន្ទាប់មក លោក ស៊ាង ចិន្តា ប្រធានក្រុមការងារមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា បានរំឭកអំពីការចូលរួមរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅឃុំព្រះរំកិល ដែលបាននិយាយចែករំលែកសាច់រឿងរបស់ខ្លួនក្នុងរបបខ្មែរក្រហមទៅកាន់អ្នកស្ម័គ្រចិត្តកម្ពុជា។ លោក ស៊ាង ចិន្តា បន្តថា ចាប់ពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៤ អ្នកស្ម័គ្រចិត្តកម្ពុជារបស់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅស្រុកបុរីអូរស្វាយសែនជ័យ បានចុះទៅសម្ភាសន៍ និងសរសេររឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីខ្មែរក្រហម ដែលការចុះទៅជួបផ្ទាល់ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅតាមផ្ទះ គឺមិនត្រឹមតែផ្តល់ពេលវេលាឲ្យអ្នកស្ម័គ្រចិត្តរបស់យើងអាចសួរសុខទុក្ខអំពីស្ថានភាពសុខភាពនាពេលបច្ចុប្បន្នក៏ប៉ុន្តែថែមទាំងអាចស្តាប់អំពីបទពិសោធន៍ដែលមិនអាចបំភ្លេចបានរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

ខាងក្រោមគឺជារឿងរ៉ាវសង្ខេបរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងឃុំព្រះរំកិល ស្រុកបុរីអូរស្វាយសែនជ័យ ដែលមកពិនិត្យសុខភាពបឋមជាមួយក្រុមគ្រូពេទ្យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ៖

ខ្ញុំបាទឈ្មោះ **សល់ ធីល** អាយុ៦២ឆ្នាំ គឺជាជនជាតិភាគតិចចារ៉ាយ រស់នៅក្នុងភូមិអន្លង់ស្វាយ ឃុំព្រះរំកិល ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។ ខ្ញុំមានអារម្មណ៍សប្បាយចិត្តយ៉ាងខ្លាំងដែលបានទទួលបានការពិនិត្យសុខភាពបឋមនៅថ្ងៃនេះ។ ពីមុនមក ខ្ញុំមិនដែលទទួលបានការពិនិត្យសុខភាពបែបនេះទេ ហើយនេះគឺជាលើកទី១សម្រាប់ខ្ញុំ។ គ្រូពេទ្យប្រាប់ខ្ញុំអំពីស្ថានភាពជំងឺរបស់ខ្ញុំ។ គ្រូពេទ្យក៏ណែនាំខ្ញុំអំពីការថែទាំសុខភាពផងដែរ។ នៅក្នុងរបប ប៉ុល ពត ខ្ញុំត្រូវបានដាក់ឲ្យធ្វើការនៅកងកុមារ។ កាលពីជំនាន់នោះ ខ្ញុំដើរប្រមូលអាចម៍គោ សម្រាប់ទុកធ្វើជី។ ខ្ញុំមានបងប្អូនប្រុសស្រីសរុបទាំងអស់ចំនួន៥នាក់។ ខ្ញុំមិនបានរស់នៅជួបជុំជាមួយឪពុកម្តាយ និងបងប្អូនទេ។ អ្វីដែលខ្ញុំចងចាំមិនភ្លេចនៅក្នុងរបបខ្មែរក្រហមនោះ គឺការបាត់បង់សមាជិកក្រុមគ្រួសារជាច្រើន។ នៅរបបខ្មែរក្រហម ខ្ញុំមិនអាចបដិបត្តិប្រពៃណីរបស់ខ្ញុំទេ ហើយសូម្បីតែភាសាចារ៉ាយ ក៏ខ្ញុំមិនអាចនិយាយបានដែរ។ ខ្ញុំត្រូវនិយាយតែភាសាខ្មែរតែប៉ុណ្ណោះ។ ខ្ញុំមិនចង់ឲ្យរបបខ្មែរក្រហមកើតឡើងជាថ្មីម្តងទៀតនោះទេ ដោយសារតែរបបនេះធ្វើបាបប្រជាជនយ៉ាងខ្លាំង។

ខ្ញុំបាទឈ្មោះ **ខង្យ លីម** អាយុ៧៨ឆ្នាំ កើតនៅឃុំតាវែងក្រោម ស្រុកតាវែង ខេត្តរតនគិរី។ ខ្ញុំគឺជាអតីតទាហានភូមិភាគ។ ខ្ញុំបានផ្លាស់មកនៅខាងប្រពន្ធនៅភូមិក្រឡាពាស ឃុំព្រះរំកិល នៅក្នុងឆ្នាំ១៩៨៦។ ខ្ញុំគឺជាជនជាតិដើមភាគតិចព្រៅ។ សព្វថ្ងៃនេះ ខ្ញុំរស់នៅភូមិក្រឡាពាស ឃុំព្រះរំកិល ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។ នៅក្នុងថ្ងៃនេះ ខ្ញុំពិតជាពេញចិត្តយ៉ាងខ្លាំងចំពោះបងប្អូនកូនក្មួយដែលជាក្រុមគ្រូពេទ្យបានចុះមកពិនិត្យសុខភាពខ្ញុំ ពីព្រោះរាល់ថ្ងៃនេះ ខ្ញុំក៏មានបញ្ហាជំងឺលើសឈាមដែរ។ ខ្ញុំមិនទាន់បានពិនិត្យសុខភាពទេ រហូតមកទល់ពេលនេះទើបខ្ញុំបានពិនិត្យ។ ខ្ញុំ និងជនជាតិភាគតិចព្រៅផ្សេងទៀត ត្រូវបានសម្តេចព្រះនរោត្តម សីហនុ ជ្រើសរើសឲ្យទៅរៀនបន្តនៅលំផាត់ បានត្រឹមថ្នាក់ទី៩។ នៅអំឡុងឆ្នាំ១៩៧០ ខ្ញុំធ្វើជាគ្រូ

បង្រៀននៅក្នុងស្រុកតាវែង ស្រាប់តែមានការទម្លាក់គ្រាប់បែកធ្វើឲ្យខូចខាតទ្រព្យសម្បត្តិ រងរបួស និងបាត់បង់ជីវិតប្រជាជនជាច្រើន។ នៅក្នុងរបបប៉ុល ពត ខ្ញុំត្រូវបានចាត់តាំងឲ្យធ្វើស្រែនិងចម្ការ។ ខ្ញុំរៀបការប្រពន្ធរួចហើយ។ នៅអំឡុងឆ្នាំ១៩៧៧ ខ្ញុំ និងយុវជនជនជាតិភាគតិចផ្សេងទៀតនៅក្នុងភូមិ ត្រូវបានបញ្ជូនទៅលើកទំនប់នៅអូរពួក។ នៅការដ្ឋានទំនប់អូរពួកនេះ មានជនជាតិដើមភាគតិចជាច្រើនត្រូវបានបង្ខំឲ្យធ្វើការ និងលើកទំនប់។ ពេលនោះ ខ្ញុំនិងយុវជនជនជាតិដើមផ្សេងទៀត ត្រូវបានបង្ខំឲ្យធ្វើការចាប់តាំងពីម៉ោង៦ព្រឹកដល់ម៉ោង១១ រួចសម្រាកថ្ងៃត្រង់បានបន្តិច ក៏ចូលទៅធ្វើការបន្ត ហើយពេលខ្លះរហូតដល់ម៉ោង៧យប់។ រឿងរ៉ាវដែលខ្ញុំចងចាំមិនភ្លេចនៅក្នុងរបបខ្មែរក្រហម គឺនៅពេលខ្មែរក្រហមស្រែកបង្ខំឲ្យធ្វើការដោយពាក្យគំរាមថា «បើមិនធ្វើការ ប្រយ័ត្នត្រូវមួយត្បូងចប»។ ជាចុងក្រោយ ខ្ញុំចង់ឲ្យយុវជនជំនាន់ក្រោយត្រូវចូលរួមការពារកុំឲ្យរបបខ្មែរក្រហមកើតមានឡើងម្តងទៀត។



ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារកម្ពុជា សហការជាមួយរដ្ឋបាលស្រុកបុរីអូរស្វាយ សែនជ័យ ខេត្តស្ទឹងត្រែង និងមន្ទីរពេទ្យ ខេរី ត្បូងឃ្មុំ រៀបចំវេទិកាពិនិត្យសុខភាពបឋមជូនដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម សរុបចំនួន២០០នាក់ នៅមណ្ឌលសុខភាពព្រះរំកិល នៅឃុំព្រះរំកិល ស្រុកបុរីអូរស្វាយសែនជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





# ចំណាប់អារម្មណ៍របស់អ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តកំពង់ចាម ចូលរួមដំណើរទស្សនកិច្ចសិក្សាអំពី «ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងប្រជាធិបតេយ្យ» ដោយផ្ដោតសំខាន់ទៅលើ «ការជម្លៀសប្រជាជនដោយបង្ខំនៅក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩) ពីថ្ងៃទី៣ ដល់ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៤

***សាំង ចាន់ធូ***

### ១) ងួន ឆេងងីម



**អ្នកស្ម័គ្រចិត្តកម្ពុជា មកពីស្រុកចំការលើ ខេត្តកំពង់ចាម**

ខ្ញុំឈ្មោះ ងួន ឆេងងីម គឺជាអ្នកស្ម័គ្រចិត្តកម្ពុជា មកពីស្រុកចំការលើ ខេត្តកំពង់ចាម។ ការធ្វើដំណើរតាមរថភ្លើងគឺជាលើកទី១របស់ខ្ញុំ ខ្ញុំពិតជាមានអារម្មណ៍ថាប្លែកព្រោះពេលជិះរថភ្លើងខ្ញុំមើលឃើញទេសភាពច្បាស់ ទោះបីជិះរថភ្លើងក្ដៅបន្តិចមែន ប៉ុន្តែមានអារម្មណ៍សប្បាយរីករាយ ព្រមទាំងធ្វើឲ្យខ្ញុំដឹងអំពីប្រវត្តិសាស្ត្រ ទៀតផង។ ក្នុងការធ្វើដំណើរតាមរថភ្លើងចេញពីភ្នំពេញ ទៅកាន់ខេត្តបន្ទាយមានជ័យ ខ្ញុំទទួលបានបទពិសោធន៍ជាច្រើន ដូចជា មានការប្រាស្រ័យ និងទំនាក់ទំនងល្អជាមួយអ្នករួមដំណើរ ដឹងអំពីជីវភាពរស់នៅរបស់ប្រជាជននៅខេត្តបន្ទាយមានជ័យ ហូបបាយជុំគ្នា និងបានស្គាល់មិត្តភក្តិច្រើនអំឡុងពេលធ្វើដំណើរ។ រថភ្លើងដើរតួនាទីយ៉ាងសំខាន់ចំពោះការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម ដូចជា បញ្ជូនប្រជាជន និងផ្លាស់ប្ដូរទីលំនៅរបស់ប្រជាជននៅក្នុងទ្រង់ទ្រាយធំ បន្ទាប់ពីការជម្លៀសប្រជាជនដោយថ្មើរជើង និងតាមរថយន្តពីកន្លែងមួយទៅកន្លែងមួយ។ ប្រជាជនដែលខ្មែរក្រហមជម្លៀសដោយបង្ខំតាមរថភ្លើងបានជួបប្រទះទុក្ខលំបាក ពិបាកក្នុងការធ្វើដំណើរដោយសារមនុស្សច្រើន ក្ដៅ ខ្វះទឹក និងអាហារ។

### ២) លន់ សៀកឈីង



**អ្នកស្ម័គ្រចិត្តកម្ពុជា មកពីស្រុកស្រីសន្ធរ ខេត្តកំពង់ចាម**

ខ្ញុំឈ្មោះ លន់សៀកឈីង គឺជាអ្នកស្ម័គ្រចិត្តកម្ពុជា មកពីស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ ការធ្វើដំណើរតាមរថភ្លើងគឺជាលើកទី១របស់ខ្ញុំ។ ការធ្វើដំណើរតាមរថភ្លើងធ្វើឲ្យខ្ញុំបានយល់ដឹងពីការជម្លៀសប្រជាជនដោយបង្ខំ នាសម័យខ្មែរក្រហម។ ក្នុងការធ្វើដំណើរតាមរថភ្លើងចេញពីទីក្រុងភ្នំពេញឆ្ពោះទៅកាន់ខេត្តបន្ទាយមានជ័យ ខ្ញុំទទួលបានបទពិសោធន៍ ដូចជា ការជិះរថភ្លើងជាលើកដំបូង ដោយប្រើរយៈពេលយូរ និងអាកាសធាតុក្ដៅខ្លាំង ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ការជិះរថភ្លើងជាបទពិសោធន៍គួរឲ្យកត់សម្គាល់ក្នុងចំណោមការដំណើរលើផ្លូវគោក។ រថភ្លើងដើរតួនាទីយ៉ាងសំខាន់ចំពោះការ

ជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម ព្រោះរថភ្លើងជាមធ្យោបាយធ្វើដំណើរមួយដែលអាចដឹកជញ្ជូនមនុស្សបានច្រើនមិនមានគ្រោះថ្នាក់។ ប្រជាជនដែលត្រូវបានជម្លៀសដោយបង្ខំតាមរយៈរថភ្លើងបានជួបទុក្ខលំបាក ដូចជា ការធ្វើដំណើរផ្លូវឆ្ងាយ ខ្វះខាតទឹក និងអាហារ ដែលអាចធ្វើឲ្យប្រជាជនស្លាប់។

## ៣) អេង សូរីកា



**អ្នកស្ម័គ្រចិត្តកម្ពុជា មកពីស្រុកចំការលើ ខេត្តកំពង់ចាម**

ខ្ញុំឈ្មោះ អេង សូរីកា គឺជាអ្នកស្ម័គ្រចិត្តកម្ពុជា មកពីស្រុកចំការលើ ខេត្តកំពង់ចាម។ ការធ្វើដំណើរតាមរថភ្លើងគឺជាលើកទី១សម្រាប់ខ្ញុំ។ ខ្ញុំមានអារម្មណ៍ថារំភើប ព្រោះវាជាបទពិសោធន៍ថ្មីមួយសម្រាប់ជីវិតខ្ញុំ ថែមទាំងទទួលបាននូវរឿងរ៉ាវថ្មីទាក់ទងទៅនឹងប្រវត្តិសាស្ត្រក៏ដូចជាជីវភាពរស់នៅរបស់ប្រជាជនខ្មែរ។ ក្នុងការធ្វើដំណើរពីទីក្រុងភ្នំពេញទៅកាន់ខេត្តបន្ទាយមានជ័យ ខ្ញុំទទួលបានបទពិសោធន៍ច្រើន និងមានអារម្មណ៍សប្បាយរីករាយពេលមើលឃើញទេសភាពពីលើរថភ្លើង ព្រមទាំងទីលំនៅរបស់អ្នកភូមិតាមផ្លូវរថភ្លើង។ ខ្ញុំក៏ទទួលបានចំណេះដឹងទាក់ទងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យកាន់តែច្រើនជាងមុន។ រថភ្លើងដើរតួនាទីយ៉ាងសំខាន់ចំពោះការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម ព្រោះវាជាមធ្យោបាយមួយដែលអាចជម្លៀសប្រជាជនមានចំនួនច្រើនក្នុងពេលតែមួយ។ តាមការស្រមៃរបស់ខ្ញុំ ការជម្លៀសប្រជាជនដោយបង្ខំតាមរថភ្លើងបានជួបប្រទះទុក្ខលំបាកជាច្រើន ដូចជា ធ្វើឲ្យប្រជាជនរងទុក្ខវេទនាខ្លោចផ្សា ព្រោះការពីសម័យនោះអាកាសធាតុក្តៅខ្លាំង ប្រជាជនមានចំនួនច្រើន ឈរប្រជ្រៀតគ្នា ព្រមទាំងគ្មានអាហារបរិភោគគ្រប់គ្រាន់។

## ៤) សឿន ស្រីណុច



**អ្នកស្ម័គ្រចិត្តកម្ពុជា មកពីស្រុកជើងព្រៃ ខេត្តកំពង់ចាម**

នាងខ្ញុំឈ្មោះ សឿន ស្រីណុច រៀនថ្នាក់ទី១២ និងជាអ្នកស្ម័គ្រចិត្តកម្ពុជា មកពីស្រុកជើងព្រៃ ខេត្តកំពង់ចាម។ ជាដំបូង នាងខ្ញុំសូមគោរពលោកពូ ឆាំង យុ គឺជានាយកនៃមជ្ឈមណ្ឌលឯកសារកម្ពុជា និងសូមគោរពទៅដល់ក្រុមការងាររួមទាំងលោកគ្រូអ្នកគ្រូដែលបានចូលរួមនៅក្នុងដំណើទស្សនកិច្ចសិក្សា និងសួស្តីយុវជនស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានចូលរួមក្នុងកម្មវិធីនេះ។

តំណាងឲ្យយុវជនស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលឯកសារកម្ពុជាទាំងអស់ ខ្ញុំសូមបង្ហាញនូវអារម្មណ៍របស់ខ្ញុំក្នុងដំណើរទស្សនកិច្ចសិក្សាថា ពិតជាមានលក្ខណៈប្លែកខុសពីសព្វមួយដង ព្រោះបានផ្តល់ឱកាសឲ្យខ្ញុំចុះមកស្រាវជ្រាវអំពីប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជាក្នុងរបបខ្មែរក្រហមនៅទីតាំងដោយផ្ទាល់។ ខ្ញុំបានយល់កាន់តែច្បាស់អំពីរឿងរ៉ាវនៅក្នុងសម័យនោះ ពីព្រោះទីតាំងមួយចំនួនខ្ញុំបានត្រឹមតែឮតាមរយៈការរៀនសូត្រ ប៉ុន្តែខ្ញុំមិនដែលបានឃើញទីតាំងទាំងនោះផ្ទាល់នោះទេ។ កម្មវិធីនេះក៏បានផ្តល់នូវបទពិសោធន៍ថ្មីៗដល់ខ្ញុំ ក៏ដូចជាអ្នកដែលបានចូលរួមទាំងអស់ដែរ។ បទពិសោធន៍ដែលនាងខ្ញុំទទួលបានក្នុងអំឡុងពេលចុះមកទស្សនកិច្ចសិក្សានេះគឺ ខ្ញុំបានយល់ច្បាស់ពីអារម្មណ៍របស់ប្រជាជនដែលរស់រានមានជីវិតពីរបបខ្មែរក្រហម ក៏ដូចជាបានឆ្លុះបង្ហាញពីទិដ្ឋភាពពិតជាក់ស្តែងក្នុងតំបន់ប្រវត្តិសាស្ត្រនៅក្នុងសម័យកាលនោះ ដូចជា ការផ្គត់ផ្គង់អាហារមិនគ្រប់គ្រាន់ ការបង្ខំឲ្យប្រជាជនធ្វើការហួសកម្លាំង និងការបិទសិទ្ធិសេរីភាពប្រជាជន។ ទស្សនកិច្ចសិក្សានេះក៏បានបង្កើនចំណេះដឹងថ្មីមួយសម្រាប់ខ្ញុំទុកជាទុនយកទៅសិក្សានៅថ្ងៃខាងមុខ និងជួយបង្ហាញប្រាប់ដល់ប្អូនៗជំនាន់ក្រោយឲ្យបាន

យល់កាន់តែស៊ីជម្រៅអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។

ក្នុងនាមខ្ញុំគឺជាយុវជនជំនាន់ក្រោយ ខ្ញុំពិតជាមានមោទនភាពចំពោះមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានរៀបចំកម្មវិធីនេះឡើង និងផ្តល់ឱកាសឲ្យនាងខ្ញុំបានសិក្សាស្រាវជ្រាវពីប្រវត្តិសាស្ត្រខ្មែរ។ នាងខ្ញុំសូមលើកទឹកចិត្តឲ្យមានដំណើរទស្សនកិច្ចនេះបន្ថែមទៀតព្រោះការសិក្សាក្រៅសាលាក៏ជាផ្នែកមួយក្នុងការអភិវឌ្ឍន៍ប្រទេសជាតិយើងដែរ។

## ៥) ហុង ចាន់រ៉ា



**អ្នកស្ម័គ្រចិត្តកម្ពុជា មកពីស្រុកជើងព្រៃ ខេត្តកំពង់ចាម**

ជាដំបូង នាងខ្ញុំសូមគោរពលោកពូ ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្សទាំងអស់។ នាងខ្ញុំឈ្មោះ ហុង ចាន់រ៉ា គឺជាសិស្សថ្នាក់ទី១២ នៃវិទ្យាល័យ ហ៊ុន សែន សួគ៌ និងជាអ្នកស្ម័គ្រចិត្តនៃអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា។ នាងខ្ញុំពិតជាមានអារម្មណ៍ថាអស្ចារ្យខ្លាំងណាស់ដែលបានចូលរួមដំណើរទស្សនកិច្ចសិក្សាស្រាវជ្រាវអំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហម និងទៅសម្ភាសន៍តាយាយអ៊ុំពូមីងដោយផ្ទាល់នៅខេត្តបន្ទាយមានជ័យ។

ដំបូងខ្ញុំឃើញទំនប់អាងត្រពាំងថ្មហាក់ដូចជាទន្លេដែលមានទំហំធំធេង និងមានទឹកជ្រៅនៅពេលទៅដល់ភ្លាម ប៉ុន្តែនៅពេលដែលស្តាប់ការលើកឡើងរបស់លោកគ្រូ ស៊ាង ចិន្តា ធ្វើឲ្យនាងខ្ញុំ និងសិស្សានុសិស្សជាច្រើននាក់ទៀតមានការភ្ញាក់ផ្អើលជាខ្លាំងព្រោះ ទំនប់ត្រពាំងថ្មនេះកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ខ្មែរក្រហមបានប្រើ តាយាយ អ៊ុំពូមីង ធ្វើការដោយកម្លាំងផ្ទាល់ដោយគ្មានពេលសម្រាក។ នាងខ្ញុំពិតជាមានសេចក្តីសង្វេគចំពោះយាយតាជាពន់ពេកនៅដែលបានដឹងរឿងរ៉ាវពិតដែលបង្កប់នៅខាងក្រោយភាពស្រស់ស្អាតរបស់ទំនប់ត្រពាំងថ្មនេះ។ បន្ថែមលើនេះ ខ្ញុំបានធ្វើដំណើរដោយជិះរថភ្លើង។ ការធ្វើដំណើរតាមផ្លូវមានការលំបាក និងក្តៅបន្តិចមែន ប៉ុន្តែសម្រាប់នាងខ្ញុំគឺជាអ្នកស្ម័គ្រចិត្តអាចពុះពារបាន។

នៅពេលខ្មែរក្រហមឡើងគ្រប់គ្រងអំណាច ខ្មែរក្រហមបានជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញដែលបង្កឲ្យមានការលំបាកជាខ្លាំង ហើយនេះគឺជាលើកទីមួយហើយដែលនាងខ្ញុំបានធ្វើដំណើរដោយជិះរថភ្លើង។ នាងខ្ញុំបានដឹងអំពីប្រវត្តិ-សាស្ត្រដែលខ្មែរក្រហមបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍លើជាតិនិងប្រជាជនរបស់ខ្លួន និងបានយល់ដឹងអំពីទុក្ខលំបាករបស់ យាយតា នាសម័យនោះ។ ទស្សនកិច្ចសិក្សានេះធ្វើឲ្យនាងខ្ញុំទទួលបាននូវបទពិសោធន៍ថ្មី និងជំរុញនាងខ្ញុំឲ្យមានភាពក្លាហានជាងមុន។

ជាកិច្ចបញ្ចប់ នាងខ្ញុំសូមអរគុណដល់អង្គការមជ្ឈមណ្ឌលឯកសារកម្ពុជាដែលផ្តល់ឱកាសដល់នាងខ្ញុំ ក៏ដូចជាសិស្សានុសិស្សជាច្រើនទៀតបានចូលរួមទស្សនកិច្ចសិក្សានេះ។ ខ្ញុំក៏សូមគោរពជូនពរដល់អង្គការមជ្ឈមណ្ឌលឯកសារកម្ពុជាឲ្យកាន់តែមានភាពរីកចម្រើនតទៅមុខជានិរន្តរ៍ ដើម្បីជាទីស្នាក់ការតម្កល់ឯកសារសម័យខ្មែរក្រហមសម្រាប់កូនចៅ និងអ្នកស្រាវជ្រាវជំនាន់ក្រោយ។

## ៦) ម៉ន រដ្ឋា



**អ្នកស្ម័គ្រចិត្តកម្ពុជា មកពីស្រុកជើងព្រៃ ខេត្តកំពង់ចាម**

ជាដំបូង ខ្ញុំសូមគោរពលោកពូ ឆាំង យុ គឺជានាយកមជ្ឈមណ្ឌលឯក-សារកម្ពុជា និងសូមគោរពដល់ក្រុមការងារ រួមទាំងលោកគ្រូអ្នកគ្រូ និងសួស្តីយុវជនស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានចូលរួមក្នុងដំណើរទស្សនកិច្ចសិក្សានេះ។

ខ្ញុំបាទឈ្មោះ វិន រដ្ឋា គឺជាសិស្សវិទ្យាល័យ ហ៊ុន សែន ស្គន់។ ដំណើរទស្សនកិច្ចសិក្សានេះ គឺបានផ្តល់ឱកាសឲ្យខ្ញុំបានចុះមកស្រាវជ្រាវពីប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា ក្នុងសម័យខ្មែរក្រហម (ប៉ុល ពត) ដោយផ្ទាល់ ហើយធ្វើឲ្យខ្ញុំយល់កាន់តែច្បាស់ពីប្រវត្តិសាស្ត្រនៅក្នុងសម័យនោះ ព្រោះទីតាំងមួយចំនួនខ្ញុំបានត្រឹមតែឮប៉ុណ្ណោះ ប៉ុន្តែខ្ញុំមិនដែលបានឃើញផ្ទាល់ទេ។ ទស្សនកិច្ចសិក្សានេះក៏បានផ្តល់នូវបទពិសោធន៍ថ្មីៗមកដល់ខ្ញុំផ្ទាល់ ក៏ដូចជាអ្នកដែលបានចូលរួមទាំងអស់គ្នា គឺខ្ញុំបានយល់ច្បាស់ពីអារម្មណ៍របស់ប្រជាជនដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម និងបានឃើញទិដ្ឋភាពពិតជាក់ស្តែងទាក់ទងនឹងទីតាំងប្រវត្តិសាស្ត្រនៅក្នុងរបបខ្មែរក្រហម។ ខ្មែរក្រហមមិនផ្តល់អាហារឲ្យប្រជាជនហូបគ្រប់គ្រាន់ បង្ខំប្រជាជនឲ្យធ្វើការងារហួសកម្លាំង បិទសិទ្ធិសេរីភាពប្រជាជន។ ទស្សនកិច្ចសិក្សានេះបានបង្កើនចំណេះដឹងថ្មីមួយសម្រាប់ខ្ញុំទុកជាទុនយកទៅសិក្សានៅថ្ងៃខាងមុខ ហើយខ្ញុំនឹងបង្ហាញប្រាប់ដល់ប្អូនៗជំនាន់ក្រោយឲ្យបានយល់ដឹងអំពីប្រវត្តិសាស្ត្រក្នុងរបបខ្មែរក្រហមដែរ។

## ៧) ភួន ផល្លីន



**អ្នកស្ម័គ្រចិត្តកម្ពុជា មកពីស្រុកស្រីសន្ធរ ខេត្តកំពង់ចាម**

ខ្ញុំឈ្មោះ ភួន ផល្លីន សូមគោរពអរគុណលោកពូ ឆាំង យុ គឺជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ក្រុមការងាររបស់លោកនាយក លោកគ្រូអ្នកគ្រូ ព្រមទាំងអ្នកស្ម័គ្រចិត្តកម្ពុជា ទាំងអស់។ ខ្ញុំគឺជាសិស្សរៀននៅថ្នាក់ទី១១ មកពីវិទ្យាល័យព្រែកដំបូក និងជាយុវជនស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ ខ្ញុំពិតជាមានអារម្មណ៍ថាប្លែក និងអស្ចារ្យដែលបានចូលរួមដំណើរទស្សនកិច្ចសិក្សានេះ ព្រោះខ្ញុំបានក្លាយជាអ្នកសិក្សាស្រាវជ្រាវវ័យក្មេងអំពីរបបកម្ពុជាប្រជាធិបតេយ្យ ឬរបបប្រល័យពូជសាសន៍ខ្មែរក្រហម។ ខ្ញុំបានយល់ដឹងអំពីរបបនេះកាន់តែច្បាស់ យល់អំពីការរស់នៅរបស់ប្រជាជនក្នុងរបបខ្មែរក្រហម ព្រមទាំងការឈឺចាប់ ការលំបាកវេទនា និងការហ៊ានលះបង់ចំពោះមនុស្សជាទីស្រលាញ់ ដូចជាកូនៗ។ ប្រជាជនក្នុងរបបខ្មែរក្រហមធ្វើការគ្មានពេលសម្រាក ហូបចុកមិនគ្រប់គ្រាន់ និងត្រូវបានជម្លៀសដោយបង្ខំតាមរថភ្លើងដែលធ្វើឲ្យប្រជាជនខ្លះបាត់បង់សមាជិកគ្រួសារ ដែលពិបាកនឹងបំភ្លេចបាន។

លើសពីនេះ ខ្ញុំក៏ទទួលបានបទពិសោធន៍យល់ដឹងនូវអ្វីដែលថ្មីយល់ដឹងអំពីសង្គម និងមានភាពក្លាហានជាងមុន។ ខ្ញុំបានស្គាល់អំពីប្រវត្តិទំនប់ត្រពាំងថ្ម តាមរយៈនាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម គឺលោក ស៊ាង ចិន្តា បានរៀបរាប់ប្រាប់ថា ទំនប់នេះធ្វើដោយកម្លាំងប្រជាជន ដែលស្ថិតក្រោមការគ្រប់គ្រងយ៉ាងតឹងរ៉ឹងរបស់មេដឹកនាំខ្មែរក្រហម និងបណ្តាលឲ្យប្រជាជនជាច្រើននាក់ស្លាប់ដោយសារធ្វើការហួសកម្លាំង។

ជាចុងក្រោយ ខ្ញុំសូមអរគុណចំពោះមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលផ្តល់ឱកាសដល់នាងខ្ញុំ និងយុវជនស្ម័គ្រចិត្តទាំងអស់បានចូលរួមដំណើរទស្សនកិច្ចតាមរថភ្លើង និងបានសិក្សាស្រាវជ្រាវអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។ ខ្ញុំក៏សូមអរគុណដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានរៀបចំអាហារហូបចុក ការស្នាក់នៅ ការមើលថែយ៉ាងយកចិត្តទុកដាក់ដល់ខ្ញុំ និងអ្នកស្ម័គ្រចិត្តទាំងអស់។ ខ្ញុំសូមឲ្យអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជាផ្តល់ឱកាសដល់យុវជនផ្សេងទៀតដើម្បីចូលរួមដំណើរទស្សនកិច្ចនេះ ដើម្បីសិក្សាស្រាវជ្រាវអំពីប្រវត្តិសាស្ត្រដ៏ឈឺចាប់ក្នុងរបបខ្មែរក្រហម និងសូមជូនពរឲ្យអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជាមានភាពរីកចម្រើនតទៅមុខទៀតជានិរន្តរ៍ សម្រាប់បង្ហាញដល់កូនចៅជំនាន់ក្រោយ។

## ៨) ហេង រួចលាង



**អ្នកស្ម័គ្រចិត្តកម្ពុជា មកពីស្រុកកំពង់សៀម ខេត្តកំពង់ចាម**

ខ្ញុំឈ្មោះ ហេង រួចលាង គឺជាអ្នកស្ម័គ្រចិត្តកម្ពុជា មកពីស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ខ្ញុំចូលរួមដំណើរទស្សនកិច្ចសិក្សាតាមរថភ្លើងពេលនេះ គឺជាលើកទី១ហើយសម្រាប់ខ្ញុំ ហើយខ្ញុំយល់ឃើញថា ការធ្វើដំណើរតាមរថភ្លើងគឺជាមធ្យោបាយល្អ។ អំឡុងពេលខ្ញុំជិះលើរថភ្លើង ខ្ញុំមានអារម្មណ៍រំភើប និងប្លែក ពីព្រោះខ្ញុំអាចមើលឃើញពីទេសភាពនារដូវក្តៅ។ ខ្ញុំទទួលបានបទពិសោធន៍ជាច្រើន នៅក្នុងការធ្វើដំណើរតាមរថភ្លើងចេញពីភ្នំពេញទៅខេត្តបន្ទាយមានជ័យ។ ខ្ញុំបានឈ្វេងយល់អំពីផលលំបាករបស់ប្រជាជនដែលរស់រានមានជីវិតពីរបបខ្មែរក្រហម។ របបខ្មែរក្រហមបានបន្សល់ទុកទំនប់ទឹកមួយដ៏ធំក្នុងខេត្តបន្ទាយមានជ័យ ដែលជីកដោយប្រជាជន ជាមួយការបង្ខិតបង្ខំឲ្យធ្វើការងារយ៉ាងធ្ងន់ធ្ងរ។ ដោយឡែក រថភ្លើងបានដើរតួនាទីជាមធ្យោបាយសម្រាប់ជម្លៀសប្រជាជនដោយបង្ខំនៅក្នុងរបបខ្មែរក្រហម។ ប្រជាជនដែលត្រូវបានជម្លៀសដោយបង្ខំតាមរថភ្លើងបានជួបប្រទះទុក្ខលំបាកជាច្រើន ដូចជា ខ្វះខាតទឹក, ស្បៀងអាហារ, រងនូវជំងឺ, កម្តៅថ្ងៃ និងជិះប្រជ្រៀតគ្នាអំឡុងពេលធ្វើដំណើរ។

## ៩) ភី សៀកមួយ



**អ្នកស្ម័គ្រចិត្តកម្ពុជា មកពីស្រុកស្រីសន្ធរ ខេត្តកំពង់ចាម**

ខ្ញុំឈ្មោះ ភី សៀកមួយ គឺជាអ្នកស្ម័គ្រចិត្តកម្ពុជា មកពីស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ ខ្ញុំមិនធ្លាប់បានធ្វើដំណើរតាមរថភ្លើងទេ។ ខ្ញុំយល់ថា ការធ្វើដំណើរតាមរថភ្លើងនេះបានផ្តល់បទពិសោធន៍ជាច្រើន។ ម្យ៉ាងទៀត កាលពីរបបខ្មែរក្រហម ការធ្វើដំណើរតាមរថភ្លើងមានស្ថានភាពលំបាកខ្លាំង ហើយអាកាសធាតុក្តៅ ព្រោះតែស្ថិតនៅក្នុងខែមេសា ដែលជារដូវប្រាំង។ ខ្ញុំទទួលបានបទពិសោធន៍ច្រើន អំឡុងពេលចូលរួមដំណើរទស្សនកិច្ចនេះ ដូចជាបានស្គាល់ផ្លូវរថភ្លើង ទីតាំងប្រវត្តិសាស្ត្រជាច្រើន នៅពេលរថភ្លើងបើកឆ្លងកាត់ពីសំណាក់បងៗដែលធ្លាប់ស្គាល់រៀបរាប់ប្រាប់ខ្ញុំ និងការស្វែងរកទីតាំងតាមដែនទី។ រថភ្លើងដើរតួនាទីយ៉ាងសំខាន់ក្នុងការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម ព្រោះការជម្លៀសតាមរថភ្លើងលឿនជាងការធ្វើដំណើរដោយថ្មើរជើង។ ម្យ៉ាងទៀត ខ្មែរក្រហមប្រញាប់ឲ្យប្រជាជនចាកចេញពីទីក្រុងភ្នំពេញឲ្យបានឆាប់រហ័សបំផុត។ ប្រជាជនដែលត្រូវបានជម្លៀសដោយបង្ខំតាមរថភ្លើងបានជួបប្រទះទុក្ខលំបាក ការធ្វើដំណើរច្រើនម៉ោង ស្ថានភាពផ្លូវលំបាកខ្លាំងដែលអាចធ្វើឲ្យអ្នកខ្លះពុល និងទទួលរងអាកាសធាតុក្តៅខ្លាំង។ ការធ្វើដំណើរតាមរថភ្លើងក្នុងរបបខ្មែរក្រហមគឺមានមនុស្សច្រើន ចង្អៀត ណែនណាន់ តានតាប់ និងរកកន្លែងអង្គុយមិនបានឡើយ។ ចំណែកដំណើរទស្សនកិច្ចសិក្សាដោយជិះរថភ្លើងពេលនេះ គឺទូរថភ្លើងទូលាយ និងងាយស្រួលជិះ ដោយអ្នកដំណើរខ្លះឈរ ខ្លះអង្គុយគយគន់មើលទេសភាពនៅអមសងខាងផ្លូវ។

## ១០) រឿន ស្រីរ័ត្ន



**អ្នកស្ម័គ្រចិត្តកម្ពុជា មកពីស្រុកស្រីសន្ធរ ខេត្តកំពង់ចាម**

ខ្ញុំឈ្មោះ រឿន ស្រីរ័ត្ន គឺជាអ្នកស្ម័គ្រចិត្តកម្ពុជា មកពីស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ ការធ្វើដំណើរតាមរថភ្លើងនៅពេលនេះគឺជាលើកទី១សម្រាប់ខ្ញុំ។ ខ្ញុំយល់ថា ការធ្វើដំណើរ

តាមរថភ្លើងនេះបានផ្ដល់បទពិសោធន៍ជាច្រើន និងមានស្ថានភាពរលាក់ជាខ្លាំង និងអាកាសធាតុក្ដៅ ព្រោះតែស្ថិតនៅខែមេសាដែលជារដូវប្រាំង។ ខ្ញុំបានស្គាល់អំពីផ្លូវរថភ្លើង និងទីតាំងប្រវត្តិសាស្ត្រជាច្រើន នៅពេលដែលរថភ្លើងបើកឆ្លងកាត់ ព្រោះបងៗក្រុមការដែលធ្លាប់ស្គាល់ទីតាំងទាំងនោះរៀបរាប់ប្រាប់។ រថភ្លើងដើរតួនាទីយ៉ាងសំខាន់ក្នុងការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម ដោយសារការជម្លៀសតាមរថភ្លើងមានរយៈពេលលឿនជាងធ្វើដំណើរដោយថ្មើរជើង។ ម្យ៉ាងទៀត ខ្មែរក្រហមប្រញាប់ឲ្យប្រជាជនចេញពីទីក្រុងភ្នំពេញឲ្យកាន់តែឆាប់។ ការធ្វើដំណើរតាមរថភ្លើងមានរយៈពេលច្រើនម៉ោង បណ្ដាលឲ្យអ្នកធ្វើដំណើរខ្លះពុលពិបាកក្នុងខ្លួន ក្អួត កន្ទួងអន្ទុយ ចង្អៀតព្រោះមានអ្នកដំណើរណែនណាន់តាន់តាប់។

## ១១) អុល ម៉េងសា៊



**អ្នកស្ម័គ្រចិត្តកម្ពុជា មកពីស្រុកស្រីសន្ធរ ខេត្តកំពង់ចាម**

ខ្ញុំបាទឈ្មោះអុលម៉េងស៊ា គឺជាអ្នកស្ម័គ្រចិត្តកម្ពុជា មកពីស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ ការចូលរួមដំណើរទស្សនកិច្ចសិក្សាតាមផ្លូវរថភ្លើងពេលនេះគឺជាលើកទី១ហើយសម្រាប់ខ្ញុំ។ ការធ្វើដំណើរតាមរថភ្លើងធ្វើឲ្យខ្ញុំបានយល់ដឹងពីការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម។ ការធ្វើដំណើរតាមរថភ្លើងចេញពីទីក្រុងភ្នំពេញ ឆ្ពោះទៅកាន់ខេត្តបន្ទាយមានជ័យ គឺប្រើរយៈពេលយូរ ក្រោមអាកាសធាតុក្ដៅខ្លាំង ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏ការជិះរថភ្លើងពេលនេះ គឺជាបទពិសោធន៍ថ្មី ក្នុងចំណោមការដំណើរតាមផ្លូវគោករបស់ខ្ញុំ។ រថភ្លើងបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម ព្រោះរថភ្លើងដឹកជញ្ជូនមនុស្សបានច្រើន និងមិនមានគ្រោះថ្នាក់។ ប្រជាជនដែលត្រូវបានខ្មែរក្រហមជម្លៀសដោយបង្ខំតាមរយៈរថភ្លើងបានជួបទុក្ខលំបាក ដូចជា ខ្វះខាតទឹក និងអាហារ ដែលអាចធ្វើឲ្យប្រជាជនស្លាប់។

## ១២) ចក់ គីមហុង



**អ្នកស្ម័គ្រចិត្តកម្ពុជា មកពីស្រុកស្រីសន្ធរ ខេត្តកំពង់ចាម**

ខ្ញុំឈ្មោះ ចក់ គីមហុង គឺជាអ្នកស្ម័គ្រចិត្តកម្ពុជា មកពីស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ នេះគឺជាលើកទី១សម្រាប់ខ្ញុំដែលបានជិះរថភ្លើងពីរាជធានីភ្នំពេញ ទៅកាន់ខេត្តបន្ទាយមានជ័យ។ ក្នុងការធ្វើដំណើរតាមរថភ្លើងនេះ ខ្ញុំទទួលបទពិសោធន៍ដូចជា ផ្ដល់នូវចំណេះដឹងថ្មីៗ និងកាន់តែធ្វើឲ្យខ្ញុំយល់ច្បាស់ពីរបបខ្មែរក្រហម។ រថភ្លើងដើរតួនាទីយ៉ាងសំខាន់ក្នុងការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម ដោយសារជម្លៀសប្រជាជនតាមរថភ្លើងមានរយៈពេលខ្លី ហើយលឿនជាងការធ្វើដំណើរដោយថ្មើរជើង។ ម្យ៉ាងទៀត ខ្មែរក្រហមចង់ឲ្យប្រជាជនចាកចេញពីទីក្រុងភ្នំពេញឲ្យបានឆាប់បំផុត។ ប្រជាជនដែលត្រូវបានជម្លៀសដោយបង្ខំតាមរថភ្លើងបានជួបប្រទះនូវទុក្ខលំបាកជាខ្លាំង ដោយសារមិនបានត្រៀមទុកជាមុន។ ពេលធ្វើដំណើរប្រជាជនខ្លះហត់ហេវអស់កម្លាំង គ្មានអាហារហូបតាមផ្លូវ បណ្ដាលឲ្យអ្នកទាំងនោះធ្លាក់ខ្លួនឈឺ និងស្លាប់។

## ១៣) ឡេង លីនដា



**អ្នកស្ម័គ្រចិត្តកម្ពុជា មកពីស្រុកស្រីសន្ធរ ខេត្តកំពង់ចាម**

ខ្ញុំឈ្មោះ ឡេង លីនដា គឺជាអ្នកស្ម័គ្រចិត្តកម្ពុជា មកពីស្រុកស្រីសន្ធរ

ខេត្តកំពង់ចាម។ នេះគឺជាលើកទី១សម្រាប់ខ្ញុំដែលបានធ្វើដំណើរតាមរថភ្លើង។ ខ្ញុំយល់ឃើញថា ការធ្វើដំណើរតាមរថភ្លើងផ្តល់បទពិសោធន៍ថ្មីៗដែលខ្ញុំមិនដែលបានជួបពីមុនមក ពិសេសធ្វើឲ្យខ្ញុំស្រមៃនិងនឹកគិតដល់ការជម្លៀសប្រជាជនដោយបង្ខំនៅក្នុងរបបខ្មែរក្រហម។ ខ្ញុំបានធ្វើដំណើរពីភ្នំពេញទៅខេត្តបន្ទាយមានជ័យ។ នៅលើរថភ្លើងមានមនុស្សជាច្រើន គឺមានទាំងមិត្តភក្តិដែលខ្ញុំធ្លាប់ស្គាល់ពីមុនមក និងមិត្តភក្តិមកពីសាលាផ្សេងៗដែលស្គាល់គ្នាពេលរួមដំណើរ។ អំឡុងពេលធ្វើដំណើរ ខ្ញុំជួបការលំបាកបន្តិចបន្តួច ដែលធ្វើឲ្យខ្ញុំគិតប្រៀបធៀបជាមួយរបបប្រល័យពូជសាសន៍ ប៉ុល ពត ដែលបានជម្លៀសប្រជាជនរាប់ពាន់នាក់តាមរយៈរថភ្លើងដែលរឹតតែលំបាកជាងខ្ញុំជិះរថភ្លើងពេលបច្ចុប្បន្ន។ រថភ្លើងដើរតួនាទីយ៉ាងសំខាន់ក្នុងការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម ព្រោះធ្វើឲ្យងាយផ្លាស់ទីប្រជាជនពីតំបន់មួយទៅតំបន់មួយទៀត និងងាយស្រួល គ្រប់គ្រងប្រជាជន។ បើតាមការស្រមៃ និងបទពិសោធន៍ដែលខ្ញុំបានធ្វើដំណើរតាមរថភ្លើង ខ្ញុំយល់ថាការធ្វើដំណើរតាមរថភ្លើងមានផលលំបាកច្រើននៅសម័យនោះ ដោយសារអាកាសធាតុក្តៅខ្លាំង ពិសេស នៅពេលដែលរថភ្លើងដឹកមនុស្សដ៏ច្រើនលើសលប់ មិនមានកន្លែងអង្គុយ និងចង្អៀតពិបាកដកដង្ហើម ម្យ៉ាងទៀតរទេះភ្លើងរលាក់ខ្លាំង។

## ១៤) លាង លីនដា



**អ្នកស្ម័គ្រចិត្តកម្ពុជា មកពីស្រុកស្រីសន្ធរ ខេត្តកំពង់ចាម**

ខ្ញុំឈ្មោះ លាង លីនដា គឺជាអ្នកស្ម័គ្រចិត្តកម្ពុជា មកពីស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ នេះគឺជាលើកទី១សម្រាប់ខ្ញុំដែលបានធ្វើដំណើរតាមរថភ្លើង។ ការជិះរថភ្លើងគឺលំបាកដោយសាររលាក់ មិនដូចជិះរថយន្តឡើយ ដែលធ្វើឲ្យអ្នកជិះខ្វះវិលមុខ និងពិបាកក្នុងខ្លួន។ ខ្ញុំបានជិះរថភ្លើងពីភ្នំពេញ ឆ្ពោះទៅខេត្តបន្ទាយមានជ័យ។ នៅលើរថភ្លើងមានមនុស្សច្រើន រួមទាំងមិត្តភក្តិដែលធ្លាប់ស្គាល់គ្នាពីមុនមក និងមិត្តភក្តិដែលទើបស្គាល់គ្នានៅពេលធ្វើដំណើរ។ ខ្ញុំស្រមៃដល់របបប្រល័យពូជសាសន៍ ប៉ុល ពត ដែលជម្លៀសប្រជាជនយ៉ាងច្រើនតាមរថភ្លើង ដែលលំបាកជាងខ្ញុំទៅទៀត។ រថភ្លើងដើរតួនាទីយ៉ាងសំខាន់ក្នុងការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម ព្រោះអាចដឹកជញ្ជូនប្រជាជនបានច្រើន។ ខ្ញុំគិតថាការធ្វើដំណើរតាមរថភ្លើងមានផលលំបាកច្រើននៅសម័យនោះដោយសារអាកាសធាតុក្តៅខ្លាំង ផ្ទុកមនុស្សច្រើន និងរលាក់ខ្លាំង។

## ១៥) មុត សុខបុប្ផា



**អ្នកស្ម័គ្រចិត្តកម្ពុជា មកពីស្រុកស្រីសន្ធរ ខេត្តកំពង់ចាម**

ខ្ញុំឈ្មោះ មុត សុខបុប្ផា គឺជាអ្នកស្ម័គ្រចិត្តកម្ពុជា មកពីស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ ខ្ញុំបានធ្វើដំណើរតាមរថភ្លើង ហើយជាលើកទី១សម្រាប់ខ្ញុំ។ ខ្ញុំយល់ឃើញថាការជិះរថភ្លើងគឺលំបាកដោយសាររថភ្លើងញ័រខ្លាំងមិនដូចរថយន្តឡើយ ដែលធ្វើឲ្យអ្នកជិះខ្វះវិលមុខ និងលំបាកក្នុងខ្លួន។ ខ្ញុំបានធ្វើដំណើរពីក្រុងភ្នំពេញ ឆ្ពោះទៅខេត្តបន្ទាយមានជ័យ។ នៅលើរថភ្លើងមានមនុស្ស ច្រើន ហើយខ្ញុំក៏បានស្គាល់ និងរាប់អានមិត្តភក្តិមកពីសាលាផ្សេងៗបានច្រើន។ រថភ្លើងដើរតួនាទីយ៉ាងសំខាន់ចំពោះការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម ព្រោះអាចធ្វើឲ្យងាយស្រួលក្នុងដឹកជញ្ជូនប្រជាជន។ ខ្ញុំគិតថាការធ្វើដំណើរតាមរថភ្លើងមានការលំបាកច្រើននៅសម័យនោះ ដោយសារអាកាសធាតុក្តៅខ្លាំង ហើយផ្ទុកមនុស្សច្រើន ។

# ការិយាល័យព័ត៌មានសាធារណៈ







«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន សិស្ស និស្សិត អ្នកសិក្សាស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍អំពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្ភាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។







តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមានៈ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្សទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លងនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។







ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ ១១ ផ្លូវលេខ ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង រស់ សំពៅ អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៨៨២ ៥០៥ ឬ

អ៊ីម៉ែល ៖ truthsampeou.r@dccam.org










សូមអរគុណ!

# ជីវិតកូនប្រុសពុកក្នុងគុកខ្មែរក្រហម (ត)

ហង្ស ឆាំឆាន

## ២.២០. ដំណឹងថ្ងៃអាពាហ៍ពិពាហ៍

ចាប់ពីថ្ងៃបានស្គាល់គ្នាច្បាស់ប្រមាណ១អាទិត្យ លោកពូ បានសរសេរសំបុត្រឲ្យនីរសារគាត់ទៅអញ្ជើញឪពុកម្ដាយ ខ្ញុំឲ្យមកការកូននៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៧ និងដាក់កំហិតថា បើមិនមកក៏គាត់ការឲ្យដែរ។ ការប្រកាសរបស់អង្គការសង្កាត់ឲ្យយុវជនយុវនារីរកមើលគូស្រករខ្លួនឯងដោយមានការយល់ព្រមពីឪពុកម្ដាយ ទាំងសងខាង អង្គការនឹងរៀបចំអាពាហ៍ពិពាហ៍ជាក្រុមនៅថ្ងៃទី២២ខែមីនាឆ្នាំ១៩៧៧ខាងមុខនេះ។ ព័ត៌មានដ៏ពិសេសនេះកាលណា លោកឪពុកអ្នកម្ដាយ និងសាម៉ីខ្លួនទាំងខាងប្រុស និងខាងស្រីប្រញាប់ប្រញាល់ស្វែងរកគូឲ្យកូននិងខ្លួនឯង បានចំនួន៤២គូ ចូលរួមពិធីអាពាហ៍ពិពាហ៍នេះ។ ស្អែកជាថ្ងៃការ ខ្ញុំខំរង់ចាំមើលផ្លូវលោកអ្នកមានគុណ និងសាច់ញាតិ រួចសុំច្បាប់មេកងចល័តមកកាត់សក់តាំងពីម៉ោង៣ល្ងាច រហូតដល់ម៉ោង៥ល្ងាចទើបអ្នកមានគុណនិងសាច់ញាតិ៥នាក់មកដល់។ ល្ងាចថ្ងៃទី២២ ម៉ោង៧ចង្កៀងមាំងសុង៣គ្រឿងមកបំភ្លឺឲ្យសាម៉ីខ្លួនបង្ហាញមុខ និងមានហៅឈ្មោះគូនីមួយៗជាបន្តបន្ទាប់។

## ២.២១. ការរៀបអាពាហ៍ពិពាហ៍៤២គូ

កម្មវិធីអាពាហ៍ពិពាហ៍ត្រូវបានចាប់ផ្ដើមពីម៉ោង៧ព្រឹកគឺ ទី១) សាម៉ីខ្លួនត្រូវមានមុខនៅមុខអង្គការ នៅសាលារៀនភូមិខុដុង្គ(ក្នុងបរិវេណអុងកូ) នៅម៉ោង៧÷០០ ទី២) អង្គការចាប់ផ្ដើមហៅឈ្មោះតាមបញ្ជីឈ្មោះដែលបានប្រកាសពីល្ងាចរួចហើយ ហាមប្ដូរគូប្ដូរប្រឡំគូ បើមានការប្ដូរគូដោយចេតនា ឬបន្ធំ ត្រូវទទួលខុសត្រូវចំពោះមុខអង្គការ ទី៣)មតិណែនាំរបស់អង្គការផ្ដាំផ្ញើទៅសាម៉ីខ្លួន និងឪពុកម្ដាយ ទាំងសងខាង ទី៤) ការចាប់អារម្មណ៍របស់តំណាងសាម៉ីខ្លួនទាំង៤២គូ ទី៥)ប្រកាសរំសាយទៅហូបបាយសាមគ្គីនៅស្នាក់ការភូមិទាំងបីរៀងៗខ្លួន។ ក្រោយសាម៉ីខ្លួនជួបជុំគ្នាហើយ សមមិត្ត សារុំ អ្នកកាន់កម្មវិធីបានហៅឈ្មោះឲ្យឡើងឈរបង្ហាញខ្លួនមួយគូម្ដងៗរហូតដល់ចប់។ ជាបន្តសមមិត្ត ឡេ បានធ្វើការផ្ដាំផ្ញើសាម៉ីខ្លួន និងឪពុកម្ដាយ ទាំងសងខាងថាតើត្រូវធ្វើដូចម្ដេចក្រោយពីរៀបការរួច។ សមមិត្ត សារិន បានឡើងចាប់អារម្មណ៍ ប្ដេជ្ញាចិត្តគោរពតាមការណែនាំរបស់អង្គការ។ កម្មវិធីចប់នៅម៉ោង៩ គត់គូស្វាម៉ីខ្លួននីមួយៗគេបណ្ដើរគ្នាត្រសងទៅតាមកន្លែងរៀងៗខ្លួន។ ដោយឡែកតែគូខ្ញុំ ប្រពន្ធទៅបោលបាត់ រកគូមិនឃើញ ក៏ដើរតាមឪពុកក្មេកដែលកំពុងបណ្ដើរនិយាយគ្នាជាមួយដន្លង់ទើបនឹងស្គាល់គ្នាថ្មីៗងាកមកមើលខ្ញុំហើយនិយាយថា កូនឯងម៉េចមិនទៅតាមប្រពន្ធ? ខ្ញុំឆ្លើយថា ខ្ញុំមើលមិនស្គាល់ទេស្លៀកពាក់ខ្មៅដូចគ្នាច្រើនណាស់ លោកឪពុកទាំងពីរក៏ទះទ្រូង ហាក់ដូចជាហួសចិត្តអាណិតខ្ញុំ។ គូគេស្គាល់គ្នាយូរហើយទើបរៀបការ ឯគូខ្ញុំឃើញគ្នាមិនទាន់បាន១អាទិត្យផង ហើយបានឃើញគ្នា៤ដងគត់ និងជួបគ្នាតែពេលយប់ផងចាប់រៀបការ លោកឪពុក និងអ្នកម្ដាយបាននាំគ្នាទៅដល់កន្លែងហូបបាយរួចទៅផ្ទះដដែកគ្នារហូតដល់យប់។



ហង្ស ឆាំឆាន ពេលបួសជាព្រះសង្ឃ។

ល្ងាចថ្ងៃការខ្ញុំ និងប្រពន្ធខ្ញុំត្រូវទៅនៅផ្ទះម្ដាយមីង់ដោយមានលោកឪពុក អ្នកម្ដាយទៅតាមក្រោយ។ ការហើយអង្គការឲ្យចុះធ្វើការជាធម្មតានៅការដ្ឋានភ្នួរចម្ការ ប្រពន្ធខ្ញុំត្រូវទៅធ្វើការជាមួយបងស្រី។ បានបីថ្ងៃដោយឃើញលោកឪពុកក្មេកចាស់ ពុំមានអ្នកថែទាំជិតដល់ អ្នកមីង និងលោកពូ បានឲ្យយើងខ្ញុំទៅនៅជាមួយឪពុកម្ដាយ ខាងស្រីវិញ។

## ២.២២. ព័ត៌មានដ៏រន្ធត់នៅការដ្ឋាន

## បឹងបាត់ឪ

ទៅនៅផ្ទះបានមួយថ្ងៃ ដែនការអង្គការកំណត់ឲ្យអ្នកទើបរៀបការថ្មីទៅបោះជំរំនៅការដ្ឋានស្រែប្រាំបឹងបាត់ឪ ដែលនៅចម្ងាយប្រមាណជាង១០គីឡូម៉ែត្រខាងត្បូងសង្កាត់ព្រែកក្របៅ។ យើងចេញដំណើរពីព្រឹកបណ្តើរគ្នាទាំងគូៗទៅដល់ការដ្ឋានម៉ោង៧។ ស្រាប់តែឃើញលោកពូជិះកង់មកហៅឲ្យខ្ញុំ២នាក់ប្តីប្រពន្ធទៅផ្ទះវិញ មកដល់ផ្ទះប្រហែលម៉ោង៩លោកពូ ក៏ប្រាប់ឲ្យឪពុកក្មេកនិងខ្ញុំថា គេនិយាយគ្នាថា ក្មួយឯងជាសាស្ត្រាចារ្យ លោកសង្ស័ ត្រូវយកទៅរៀនសូត្រសិន ក្មួយឯងជាសាស្ត្រាចារ្យមែនឬ? ខ្ញុំប្រាប់ពូថា ខ្ញុំមិនមែនជាសាស្ត្រាចារ្យទេ ប្រាំឆ្នាំក្នុងសង្គ្រាមមិនមានរើសសាស្ត្រា-ចារ្យទេពូ។ លោកពូបានសួរទៅលោកឪពុកក្មេកខ្ញុំថា តើយើងគិតដោះស្រាយដូចម្តេចលោកបង? លោកឪពុកក៏និយាយថា ប្អូនម៉េងគណៈស្រុកជាប្អូនធម៌ខ្ញុំ ចាំព្រឹកស្អែកឲ្យកូនឌុបខ្ញុំទៅ សុំប្អូនមើលគេថាយ៉ាងម៉េចដែរ?។ លោកថា អញ្ចឹងក៏ល្អដែល តែកុំឲ្យកូនចូលទៅក្នុងមន្ទីរប្រយ័ត្នលោកបង លោកបងទៅដល់ក្បែរហើយឲ្យកូនត្រឡប់មកផ្ទះវិញ បងនៅនិយាយជាមួយគេទៅ មិត្តម៉េង ប្រាកដជាឲ្យគេជូនលោកបងមកផ្ទះវិញហើយ។ ពេលល្ងាចម៉ោង៥ លោកឪពុកមកដល់ផ្ទះគ្រវីក្បាលទាំងទឹកមុខស្ងួត និយាយថាគេមិនហ៊ានធានាថាម៉េចទេគេឲ្យកូនឯងបែកគ្នាទៅផ្ទះវិញកុំឲ្យគេរករឿងទាន់អាចគ្រោះថ្នាក់ទាំងអស់គ្នា។ បន្ទាប់មកលោកពូ ក៏មកដល់ ក៏សួរដឹងរឿងហើយក៏នៅស្ងៀមមិននិយាយអ្វីទាំងអស់ ហើយត្រឡប់ទៅកន្លែងគាត់វិញបាត់។

## ៣. សប្បាយក្លាយជាទុក្ខ

ម៉ោង៤ទៀបភ្លឺថ្ងៃបន្ទាប់ លោកពូបានមកដល់ផ្ទះដាស់លោកឪពុកអ្នកម្តាយនិងខ្ញុំឲ្យក្រោករួចហុចសំបុត្រធ្វើដំណើរមកខ្ញុំប្រាប់ថា កូនត្រូវរៀបចំខ្លួនចេញទៅផ្ទះឯបឹងដោលឥឡូវនេះកុំបង្អង់ចាំភ្លឺ គេនឹងមកចាប់ខ្លួននៅព្រឹកនេះ បើកូនទៅស្រុកជាប់គុកជិតម៉ែឪអាចរស់ខ្លះបើជាប់នៅពាមជរ ទោះមានទោសមិនដល់ស្លាប់ក៏ស្លាប់ដោយអត់អាហារដែរ ទៅឲ្យសុខសប្បាយណាកូនៗ។ ខ្ញុំក៏ក្រាបថ្វាយបង្គំលាលោកឪពុក អ្នកម្តាយក្មេក និង លាប្រពន្ធទាំងទឹកភ្នែករៀងៗខ្លួន ចេញទៅភ្លឺនៅកន្លែងឆ្លងកាណូតដីក្រហម។

## ៣.១. ការបន្ទែងជានខ្ញុំមុនចាប់ដាក់គុក

ទៅដល់ផ្ទះម៉ោងប្រមាណជា៨ព្រឹក សាច់ញាតិបងប្អូនក្មួយមកជុំគ្នាចោមរោមខ្ញុំ ព្រោះចង់ឃើញប្រពន្ធខ្ញុំ ជាពិសេសក្មួយៗធ្វើឈ្លបសង្កាត់បានសួរខ្ញុំថា លោកពូឯណាមីង? ខ្ញុំបានរៀបរាប់ប្រាប់តាមដំណើររឿង? ម្នាក់ៗប្រែជាស្រងូតស្រងាត់ដួយឈើឆ្កាល និងក្តៅក្រហាយដួសខ្ញុំរួចសួររកមុខអាណាមួលបង្កាច់ដូច្នេះ។ ខ្ញុំវិលវល់អស់ហើយរកនឹកយូរៗទៅនឹងឃើញថាថ្ងៃទី១ មករា ១៩៧៧ នៅដីក្រហម អាប៉ាល់ និយាយអួតប្រាប់គេប្រាប់ឯងលេងផងនៅលើទូកចម្លងដ នឹងឃើញពាក្យនេះទើបគាត់សាញលួងខ្លួនឯង និងប្រាប់លោកអ្នកមានគុណ នឹងបងប្អូនក្មួយថា មិនអីទេកុំខ្វល់ទឹកដោះម្តាយថ្ងៃ ខ្ញុំត្រូវតែរស់តទៅទៀត។ ថ្ងៃទី៣០ មីនា មិត្តគីអនុប្រធានក្រុមបានហៅខ្ញុំទៅធ្វើឡរំលាយដែករថក្រោះដើម្បីចាក់ចេញជារបស់ប្រើប្រាស់ដូចជា ចានឆ្នាំង ស្លាបព្រាៗល។ ធ្វើការងារនេះបាន២ថ្ងៃ ក៏ចាត់ឲ្យទៅជាន់រហាត់ទឹកស្រូវប្រាំងនៅអូរតាសៅ។ ជាធម្មតាការជាន់រហាត់ពីព្រឹកដល់ម៉ោង១១ យើងនាំគ្នាឈប់ហូបបាយហើយចុះរុតត្រីដល់ម៉ោង៣ទើបឡើងមកជាន់បន្ត។

## ៣.២. ការចាប់ខ្លួនមកដល់

រុតត្រីមិនទាន់ដល់ម៉ោងផង ខ្ញុំឃើញមិត្តឡឿក ប្រធានភូមិមកបក់ដៃហៅខ្ញុំហើយ ប្រាប់ថា«អង្គការឲ្យយកសំបុត្រទៅជួបប្រពន្ធវិញ» នៅផ្ទះមិត្តចក ឥឡូវនេះ។ ពាក្យនេះភ្ញាក់ខ្ញុំយល់ពីល្បិចពួកនេះរួចជាស្រេច គឺខ្ញុំដល់ពេលចាប់ខ្លួនហើយ តើត្រូវដោះស្រាយយ៉ាងម៉េចខ្ញុំ? នៅលើខ្លួនខ្ញុំមានតែខោខ្លី និងអាវយឺតទាហានជ្រលក់មាក់ក្លឿទទឹកដោតនិងក្រមាជូតក្បាល។ ខ្ញុំក៏ប្រាប់ទៅអ្នករុតត្រីជាមួយគ្នាឲ្យទៅយកខោអាវនិងប្រាប់អ្នកមានគុណខ្ញុំផង។ ដើរទៅដល់ផ្ទះអង្គការ មិត្តចក អនុប្រធានសង្កាត់ស្រែកពីលើផ្ទះមកប្រាប់ មិត្តយោន ជាសន្តិសុខស្រុក កំពុងឈរកាន់កាំភ្លើងអាកា៤៧ នៅចាំក្រោមផ្ទះថា ហ្នឹងហើយយកវាទៅ។ មិត្តយោនក៏តម្រង់កាំភ្លើងភ្ជង់មកខ្ញុំហើយស្រែកថា«លើកដៃឡើងនៅឲ្យស្ងៀម» រួចគេហៅមិត្តចកឲ្យចុះពីលើផ្ទះយកខ្សែអង្រឹងដែលគេត្រៀមជាស្រេចមកចងស្លាបសេកខ្ញុំ និងយកក្រមាគ្របពីលើរួចបណ្តើរខ្ញុំចេញសំដៅទៅទិសខាងលិច។ ឃើញសកម្មភាពនេះខ្ញុំគិតថា ទី១) ខ្ញុំអាចត្រូវគេនាំយកទៅសម្លាប់នៅទួលអង្គជាកន្លែងដែលគេយកលោកគ្រូ សេក នាង ជាគ្រូសូត្ររបស់ខ្ញុំ និងលោកតាញ៉ែម ទៅសម្លាប់កាលពីជាងមួយឆ្នាំមុន។ ទី២) អាចយកខ្ញុំទៅដាក់គុកនៅផ្ទះមេស្រុកស្ងួង។ មិត្តយោនជិះកង់ភ្ជង់ពីក្រោយខ្ញុំបានបង្ខំឲ្យខ្ញុំដើរឲ្យលឿន ខ្ញុំក៏លែងគិតអ្វីទាំងអស់ប្រឹងតែដើរ

ឲ្យលឿនតាមបញ្ជាគេ ព្រោះខ្លាចគេវាយ ហ្នឹងស៊ុយកាំភ្លើង។ ម៉ោងប្រហែលជា៥ល្ងាចយើងបានទៅដល់គុកផ្ទះមេស្រុកសួង ជាមន្ទីររួមសន្តិសុខស្រុកកោះដ៏យ មិត្តយោនបានស្រែកទៅប្រាប់មនុស្សម្នាក់ដែលធ្លាប់រៀនជាមួយខ្ញុំកាលពីឆ្នាំ១៩៥៧ និងត្រូវជាឪពុកមាជីទូតមួយខាងម្ដាយខ្ញុំគឺមិត្ត មឿង ថា «អីលោកមេឃុំផ្ញើមនុស្សមួយផងមើលទុកដាក់ឲ្យស្រួលខ្ញុំចប់បេសកកម្មខ្ញុំហើយ»។ មិត្ត មឿង ឃើញខ្ញុំភ្លាម ក៏សម្ដែងអាការស្រងូតស្រងាត់ទឹកភ្នែកដាក់ខ្ញុំ ដោយមិននិយាយអ៊ីមួយម៉ាត់សោះ រួចក៏ស្រែកហៅកូនចៅគាត់២នាក់ឲ្យយកខ្ញុំទៅឡើងលើផ្ទះ ដាក់ខ្នោះ៤ និងស្រាយចំណងដៃចេញ។ ដាក់ខ្នោះរួចខ្ញុំក្រឡេកមើលជុំវិញខ្ញុំ មានបុរសម្នាក់ឈ្មោះសុនអត់ពាក់អាវរបួសពេញខ្លួនក្រវេមក្រវាមគួរឲ្យព្រឺព្រួចជាស្នាមវាយនឹងក្ដោគ្រាម រួមនឹងអ្នកទោសឈ្លើយសឹកវៀតណាមចំនួន៤នាក់ទៀតនៅជាប់ខ្នោះ៤ដូចគ្នា។

## ៣.៣. ទិដ្ឋភាពក្នុងគុកផ្ទះមេស្រុកសួង

កន្លះម៉ោងក្រោយមក មានអ្នកទោសចូលមកដល់ម្នាក់ទៀតឈ្មោះ ឆែ វង្ស ជាអតីតមន្ត្រីគយសម័យសង្គមរាស្ត្រនិយម និងសាធារណរដ្ឋខ្មែរគេទើបនឹងរកនឹកឃើញចាប់មក ត្រូវបានគេដាក់ខ្នោះ៤ដូចពួកខ្ញុំដែរ។ លោកគយ បានរំកិលខ្លួនទាំងជើងជាប់ខ្នោះមកជិតពួកខ្ញុំ ហើយសួរថា ប្អូនទាំងពីរមកជាប់គុកនេះប៉ុន្មានខែហើយ ជាអ្នកចាស់ឬអ្នកថ្មី មានរឿងអ៊ីដែរ? លោកសុន ឆ្លើយថា ខ្ញុំមកជាប់ទើបតែ២ខែខ្ញុំអ្នក១៧មេសា គេចោទខ្ញុំថា ខ្ញុំជាប៉ូលិស លន់ នល់ ខ្ញុំប្រកែកយកឈ្នះអ្នកសួរចម្លើយ គេវាយខ្ញុំជាង៥០ក្ដោសន្លប់៣ដង គេជះទឹកដាក់មុខខ្ញុំខ្ញុំដឹងខ្លួនលើកទី៣ ទើបគេលែងសួរតទៅទៀត រួចយកមកដាក់ខ្នោះបន្ត ខ្ញុំសូមផ្ដាំប្អូនទាំង២ថា យើងសុខចិត្តឲ្យវាវាយ ទាល់តែស្លាប់ជាជាងឆ្លើយសារភាពតាមពួកវាចោទ ព្រោះវាមិនទុកឲ្យយើងនៅរស់ទេ បើយើងសារភាព។ ខ្ញុំក៏បាននិយាយទៅរកលោកគយថា ខ្ញុំទើបមកមុនបងបន្តិចនេះខ្ញុំអ្នកថ្មី ខ្ញុំមិនដឹងថាខ្ញុំខុសអីទេមកដល់ពេលនេះ។ លោកគយសួរបន្តធ្លាប់ធ្វើការទេ ខ្ញុំឆ្លើយថាអត់ដែលទេ។

ចុះរៀនសូត្របានដល់ណាដែរ? ខ្ញុំមិនបានរៀនសូត្រទេ ខ្ញុំបួសរៀនខាងលោកសង្ឃដល់ឆ្នាំ១៩៧០ គ្មានអ្នកផ្គត់ផ្គង់ក៏ឈប់រៀនទៅ។ ខ្ញុំនិយាយចប់ លោកគយ បាននិយាយអួតពីការងាររបស់គាត់ រួចបង្ហាញកាំភ្លើងរ៉ឺវ៉ុលវ៉ែរមួយដើមដែលគាត់បានលាក់យកមកតាមខ្លួនរួចបន្តថាខ្ញុំមានកូនខ្មោចនៅតាមខ្លួនមិនឲ្យពួកអាអស់នេះធ្វើអីខ្ញុំតាមអំពើចិត្តទេ។ និយាយចប់ឆ្មាំគុកបានស្រែកប្រាប់អ្នកទោសឲ្យចូលដាក់ខ្នោះតាមកន្លែងរៀងៗខ្លួន។ អ្នកទោសប្រមាណជា៩០នាក់ ត្រូវដេកផ្ទុយគ្នា៣ជួរខ្នោះក្នុងផ្ទះបណ្ដោយប្រហែល៣០ម៉ែត្រទទឹង១៥ម៉ែត្រ បើត្រូវបានបត់ជើងធំគេឲ្យជុះដាក់កេះគ្រាប់ដែលនៅតាមបណ្ដោយខ្នោះនីមួយៗ បើចង់បត់ជើងតូច ត្រូវស្រែកប្រាប់អ្នកដែលនៅក្បែរកានដាក់ប្រេងឲ្យជួយ ហុចបន្តគ្នាមកឲ្យ។ គ្រាន់ចូលមកដល់ភ្លាមសង្កើចរាប់លាន និងចៃរាប់សែនស្វាគមន៍យើងមុន។ នៅខាងក្រោមផ្ទះ មានមនុស្សជាប់ខ្នោះប្រហែល១០នាក់ស្រែកយំ និងជេរប្រទេចជាច្រើន តែខ្ញុំនៅចាំពាក្យមួយឃ្លាថា «បរាជ័យពួកអាកុម្មុយនិស្ត ជយោ! សាធារណរដ្ឋខ្មែរ» អ្នកស្រែកឈ្មោះយ៉ុល អតីតទាហាន លន់ នល់។ អ្នកទោសជាប់នៅខាងក្រោមជាអ្នកទោសប្រហារជីវិត អ្នកណាជាប់ខ្នោះនៅខាងក្រោម គេមិនឲ្យបាយ ឬទឹកផឹករយៈពេល៤៩ថ្ងៃ បើអ្នកណាមិនស្លាប់គេយកមកដាក់ខ្នោះខាងលើឲ្យបាយ ទឹកស៊ីវិញ។ នៅខាងលិចគុកនេះមានរោងគុកមួយទៀតប្រវែងបណ្ដោយប្រហែល២៥ម៉ែត្រសម្រាប់ដាក់មនុស្សស្រី និងកុមារ រាប់សិបនាក់ៗ នៅខាងកើតជាមន្ទីររបស់អង្គការចំនួន២ខ្នង មានកម្មាភិបាលនិងសន្តិសុខប្រហែលជា៤០នាក់នៅប្រចាំការ២៤ម៉ោង។ ពួកអ្នកទោសដាក់ខ្នោះ និងរាប់ចំនួន ហើយដោយមានប្រធានអ្នកជាប់គុកម្នាក់គេមិនដាក់ខ្នោះទេ ជាអ្នកដើរមើល និងណែនាំអ្នកទោសទាំងឡាយប្រតិបត្តិតាមគឺ១) ហៅឈ្មោះខ្លួនឯង លេខរៀង ឲ្យគេដឹងពីដើមខ្នោះ ដល់ចុងខ្នោះ ឧទាហរណ៍: លេខ១ ឈ្មោះ សែនខ្មៅ លេខ២ រស់រំដួល។ ទី២) ប្រធានអ្នកជាប់គុកពិនិត្យឃើញថាត្រឹមត្រូវហើយស្រែករាយការណ៍ប្រាប់សន្តិសុខថា អ្នកទោសបានមកគ្រប់ចំនួនហើយបង។ ក្រោយរៀបចំអ្នកទោសចូលខ្នោះអស់ ចុងភៅយកបាយមកឲ្យពួកខ្ញុំដែលកំពុងជាប់ខ្នោះទាំង៧នាក់ហូប ខ្ញុំនិងលោកគយទើបនឹងមកដល់ថ្មី ពុំមានចានឲ្យគេដាក់បបរទេ។ គេយកក្បាលមួកស្លឹកត្នោតសុទ្ធតែក្អែលខ្មៅក្រឹកដាក់សន្លឹកដំឡូងកាត់ជាផង់ៗស្ងោរលាយនឹងបបររាវឲ្យពួកយើងហូប ខ្ញុំនិងលោកគយសាកបាន២ទៅ៣ម៉ាត់ក៏ទុកលើក្បាលដំណេកសិន អ្នកទោសដូចគ្នាសម្លឹងពួកយើងទាំងពីរនាក់រួចអ្នកខ្លះនិយាយថានៅរើសស្មៅនៅឡើយទេឥឡូវនេះចាំមើលបន្តិចទៀតគាត់លែងរើសស្មៅហើយពេលឃើញបបរខ្ញុំទុកលើក្បាលដំណេក អ្នកទោសដូចគ្នាសុំថាបើមិនហូប កុំទុកអញ្ចឹងអង្គការដឹងមានរឿងដល់បងឯងទៀត ខ្ញុំសូមហូបមក ខ្ញុំទាំងពីរក៏ផ្ដល់ក្បាល ពួកគេពីរ

នាក់បានលើកបបរហូតអស់ទៅ ចុងភៅយកបាន ក៏មកដល់ល្មមប្រមូលយកទៅវិញអស់។ រាត្រីកាលចូលមកដល់ ព្រឹត្តិការណ៍ដ៏គួរឲ្យរន្ធត់មួយមកដល់គឺ គេហៅឈ្មោះលោកគយ ឲ្យដោះខ្នោះ រួចចេញពីគុកទៅក្រៅ បានន័យថាលោកគយ គេយកទៅសម្លាប់ហើយ។ អ្នកទោសទាំងឡាយសម្ងំស្ងៀម ម្នាក់ៗមិនមាត់ ហើយក៏មិនហ៊ានកម្រើកដែរ គ្រាន់តែពួសន្តិសុខហៅឈ្មោះទោះបីមិនចំឈ្មោះខ្លួនឯងក៏ញ័រមាត់ដែរ។ ពេលវេលាដែលខ្ញុំសម្គាល់ឃើញជារៀងរាល់យប់ ចាប់ពីម៉ោង៦ដល់ម៉ោង១០យប់ បើមិនមានសំឡេងហៅឈ្មោះទេចាត់ទុកថាយើងបានរស់១ល្ងាច ទៀបភ្លឺចាប់ពីម៉ោង៣ដល់ម៉ោង៦ បើមិនមានឈ្មោះចាត់ទុកថា បានរស់មួយយប់ ពេលព្រឹកក៏ដូចគ្នាដែរចាប់ពីម៉ោង៨ដល់ម៉ោង១០រស់បាន១ព្រឹក និងម៉ោង៣ដល់ម៉ោង៥ល្ងាចរស់បាន១ថ្ងៃ។

## ៣.៤.ការងារជីកស្រះជម្រៅ៧ម៉ែត្រ ដោយប្រើអ្នកទោស

ព្រឹកឡើងម៉ោង៦អង្គការសន្តិសុខបានដោះខ្នោះឲ្យមិត្តសុន និងខ្ញុំទៅតម្រង់ជួរចេញទៅធ្វើការនឹងគេ មិត្តមឿង គឺជាអ្នកចាត់ចែងការងារ។ ខ្ញុំមិត្ត សុន និងអ្នកទោសប្រហែល២០នាក់ទៀតត្រូវទៅជីកស្រះនៅជិតមន្ទីរសន្តិសុខ ឯអ្នកផ្សេងត្រូវចែកតាមការដ្ឋានជាច្រើនក្រុម។ ចេញពីមន្ទីរសន្តិសុខទៅទិសខាងកើតប្រមាណជា៥០ម៉ែត្រ មានស្រះមួយទំហំប្រហែលជា៥០ម៉ែត្រគុណ៤០ម៉ែត្រ មានជម្រៅដ៏ជ្រៅតាមស្នាមប្រហែលជា៦ទៅ៧ម៉ែត្រ មិនដឹងគេជីកតាំងពីពេលណាមកទេ។

ពេលចាប់ផ្ដើមធ្វើការគេឲ្យរើសគូសម្រាប់សែងដី ឡើងពីបាតស្រះមកចាក់នៅមាត់ស្រះខាងលើពីរនាក់ប្រើប្រង៍កាមួយ។ យើងទាំងពីរនាក់សែងដីបានប្រមាណជា១០ប្រង៍កា ស្រាប់តែមិត្តមឿង បក់ដៃហៅខ្ញុំទៅជួបគាត់នៅក្នុងស្នាក់ការសន្តិសុខ ខ្ញុំក៏ដើរចូលទៅម្នាក់ឯងដោយប្រុងប្រយ័ត្នបំផុត ព្រោះមិនដឹងមានរឿងអីកើតឡើងទៀតទេ។

## ៣.៥. លោកឪពុកធម៌ស៊ូយកខោអាវមកឱ្យដល់ក្នុងគុក

ខ្ញុំបានដើរតាមក្រោយពូ មឿង ចូលទៅក្នុងមន្ទីរ ឃើញឪពុកធម៌ឈ្មោះ ស៊ូ ដែលជាក្មេងលោកឪពុកខ្ញុំ ញញឹមដាក់ខ្ញុំ រួចប្រាប់ខ្ញុំថា អត់អីទេកូនទ្រាំសិនទៅ ចាំឪឲ្យដំណឹងទៅពូពៅ វាមកធានាកូនចេញវិញ។ ល្ងាចមិញក្មេង បានមកផ្ទះឪផ្ញើខោអាវ និងអីវ៉ាន់មកឲ្យដោយយប់ណាស់ហើយ ឪមិនហ៊ានមក។ លោកពូ មឿង ក៏មកអង្គុយជិតខ្ញុំរួចនិយាយថា ទ្រាំសិនទៅក្មួយកុំខឹងនឹង ពូថា មិនជួយក្មួយ ល្ងាចមិញគ្រាន់តែឃើញក្មួយភ្លាមពូស្លុតចិត្តណាស់ តែមិនដឹងធ្វើម៉េចបើពីមុនបងមិ នៅប្រហែលជាអាចជួយក្មួយបាន ពេលនោះពូក៏អាចការពារក្មួយបានដែរ តែឥឡូវបង មិ ត្រូវគេហៅដាក់ឡានទៅបាត់ ពូក៏ត្រូវគេដកសិទ្ធិជាប្រធានមន្ទីរសន្តិសុខមកជាបុគ្គលិកសន្តិសុខធម្មតា ហើយវាសនាពូក៏មិនដឹងជាទៅយ៉ាងណាទេ និយាយបានប៉ុណ្ណឹង ពូមឿង ស្រក់ទឹកភ្នែកក៏ចេញទៅក្រៅទៅ។ ឪធម៌ក៏ចាប់ផ្ដើមប្រាប់ថា ឪម៉ែកូនឯង ម្សិលមិញបានតាមមើលកូនរហូត ឃើញគេចងកូនបណ្ដើរម្ដាយកូនយំដល់សន្លប់លែងដឹងខ្លួន តែឥឡូវបានស្រួលវិញហើយអត់អីទេ។ ពេលនោះ ពូមឿង ក៏មកតឿនឪធម៌ថា ប៉ុណ្ណឹងបានហើយបងកុំនិយាយយូរពេកនាំគេសង្ស័យ។ យើងក៏បែកគ្នា ខ្ញុំក៏យួរកន្ត្រកខោអាវទៅការដ្ឋានវិញ បន្តសែងដីតទៅទៀតរហូតដល់ម៉ោងបាយទើបឈប់។ ពេលហូបបាយរួចខ្ញុំត្រូវឡើងទៅដោះខ្នោះទៀតជាមួយមិត្ត សុន រហូតដល់ម៉ោង២ ទើបគេដោះឲ្យទៅធ្វើការវិញ។ ម្ដងនេះឈ្លើយសឹកវៀតណាមចំនួន៤នាក់ដែលជាប់ខ្នោះ៤ដូចខ្ញុំពីម្សិលមិញមិនដឹងជាទៅណាបាត់អស់។ យើងទាំងពីរនាក់ឃើញដូច្នេះមិនហ៊ាននិយាយអ្វីទាំងអស់ ខ្ញុំបើកកន្ត្រកមើលខោអាវចានស្លាបព្រា និងនំអន្សម២។ល។ យកអន្សមចែកគ្នាហូបពីរនាក់មិត្តសុន ហើយក៏សម្រាកទៅ។ ពេលល្ងាចយើងទាំងពីរនាក់បានអត់ធ្មត់ហ្នឹងការសែងដីឡើងទីទួលខ្ពស់ ព្រោះការងារនេះធ្វេសប្រហែសអាចធ្លាក់ដីមកក្រោមវិញ មិត្តភីប្រធានមន្ទីរឃើញប្រាកដជាមិនរួចជីវិតទេ។ កន្លងមកមានមនុស្សជាច្រើនស្លាប់នៅកន្លែងនេះដោយសារការធ្វេសប្រហែសដូចខ្ញុំនិយាយខាងលើ ដោយមិត្តភីវាយឲ្យផាប់នៅហ្នឹងកន្លែង ឬឲ្យកូនចៅយកទៅសម្លាប់ភ្លាមៗ។ យើងសែងដីបណ្ដើរ មិត្ត សុន និយាយបណ្ដើររឿងពីនេះពីនោះមកឲ្យខ្ញុំស្ដាប់ ពិសេសគាត់និយាយថា ឆាន ឯងគេមិនទាន់សួរចម្លើយទេ នៅពេលគេសួរ បើគេសួរអ្វីដែលជាការចោទប្រកាន់មិនត្រឹមត្រូវកុំសារភាពឲ្យសោះ សុខចិត្តស្លាប់ដោយសារពួកវាវាយ បើយើងមិនសារភាពតាមពួកវាចោទអាចរស់ភាគច្រើន។

## ៣.៦. ការចងស្លាបសេក និងចងបិតមុខសួរចម្លើយ

ការងារដដែលៗនេះបានប្រព្រឹត្តទៅអស់រយៈពេល៧ថ្ងៃ ស្រាប់តែម៉ោងប្រហែល៧ មិត្តឡឿន និងមិត្តសារ៉ន កាន់កាំភ្លើងអាកាម្នាក់១ដើម មកឈរស្រែកបក់ដៃហៅខ្ញុំឲ្យឡើងពីក្នុងស្រះមកលើ។ ពេលខ្ញុំឡើងមកដល់ភ្លឺស្រះ មិត្តសារ៉នភ្ជង់កាំភ្លើងដាក់

ខ្ញុំ ប្រាប់ឲ្យដាក់ដៃទៅក្រោយរួចយកខ្សែអង្រឹងមកចងស្ទាបសេកខ្ញុំ ដូចកាលមិត្តយោនចងខ្ញុំពីថ្ងៃមុន និងស្រាយក្រមាពីក្បាលខ្ញុំមកចងមុខកុំឲ្យខ្ញុំមើលអ្វីឃើញ រួចមិត្តឿន កាន់ខ្សែអង្រឹងដែលចងដៃខ្ញុំរុញ និងប្រាប់ខ្ញុំឲ្យដើរទៅមុខៗ ខ្ញុំមើលអ្វីមិនឃើញទេបេះតែដើរទៅមុខតាមគេញាក់ម្តងបត់ឆ្វេង ម្តងបត់ស្តាំ តាមភ្លឺស្រែៗ ខ្ញុំហាក់ដូចជារន្ធត់រកនឹកអីមិនឃើញរួចចាប់តាំងស្មារតីឡើងគិតថា តើពួកវាយកខ្ញុំទៅសម្លាប់ឬយកទៅណា? បើយកទៅសម្លាប់ម៉េចចាំឲ្យខ្ញុំមកធ្វើការហើយបានហៅចាប់ខ្ញុំនៅមុខមនុស្សជាច្រើននាក់ឈរមើល? កំពុងតែឆ្ងល់ប្រហែលជា១០នាទី មិត្តឿន ប្រាប់ថាអង្គុយចុះៗ ខ្ញុំក៏អង្គុយចុះមិនដឹងថាអង្គុយនៅលើគោអីឬដើងម៉ា ឬលើអ្វីទេ ព្រោះដៃជាប់ចំណង ភ្នែកមើលមិនឃើញ។ បន្តិចក្រោយមកខ្ញុំបានឮសំឡេងសម្រិបជើងមនុស្ស២ទៅ៣នាក់ដើរមកដោយនិយាយគ្នាតិចៗ ខ្ញុំស្តាប់មិនបានថាគេនិយាយពីអ្វីទេ។

## ៣.៧. ការចោទប្រកាន់ថាជាសាស្ត្រាចារ្យនិងវាយខ្ញុំ

បន្ទាប់មកមិត្ត ភី និយាយមកខ្ញុំថា អ្នកឯងត្រូវនិយាយពីប្រវត្តិរបស់ខ្លួនចាប់ពីថ្ងៃទៅនៅភ្នំពេញរហូតមកដល់ពេលនេះឲ្យអង្គការស្តាប់ដើម្បីឲ្យអង្គការជួយរកយុត្តិធម៌ឲ្យ។ ខ្ញុំក៏ឆ្លើយទៅវិញថា តើខ្ញុំអាចនិយាយប្រវត្តិតាំងពីខ្ញុំកើត មកដល់ឥឡូវបានដែរឬអត់? មិត្ត ភី ឆ្លើយថាបានៗ ខ្ញុំក៏ចាប់ផ្តើមនិយាយរៀបរាប់ពីថ្ងៃ ខែ ឆ្នាំ ទីកន្លែងកំណើតរហូតដល់ឆ្នាំ១៩៦២ បួសជាលោកសង្ឃឆ្នាំ១៩៦៤ទៅនៅភ្នំពេញរហូតដល់ឆ្នាំ១៩៥៧ ទើបត្រឡប់មករស់នៅវត្តកំណើត និងសិក្ខមករស់នៅជាមួយអង្គការរហូតដល់បច្ចុប្បន្ន។ ខ្ញុំរៀបរាប់ប្រហែលជា១ម៉ោងទើបចប់។ ក្រោយពេលចប់នៅចងចាំបណ្តាំមនុស្ស២នាក់ប្រាប់ខ្ញុំ នៅពេលមិត្តភី សួរចម្លើយគាត់គឺប្អូនថ្លៃខ្ញុំឈ្មោះខឹម គុល ប្រាប់ថានិយាយពីការរៀនសូត្រខាងលោកសង្ឃពួកនេះមិនដឹងទេ និងបង ហ៊ុន សុន ប្រាប់ថ្មីៗ។ បន្ទាប់មកមិត្តភី ក៏សួរបន្តថាតើការរៀនសូត្របានដល់ណា? ធ្លាប់ធ្វើជាសាស្ត្រាចារ្យបានប៉ុន្មានឆ្នាំ? ខ្ញុំឆ្លើយទៅវិញថា ខ្ញុំជាអ្នកបួសនៅវត្តសូត្រធម៌ដូចលោកនៅតាមវត្តដទៃទៀតដែរ រៀនសូត្រតែធម៌ មិនមានទទួលសញ្ញាបត្រអ្វី ហ្នឹងគេទេសាស្ត្រាចារ្យក៏ខ្ញុំមិនដែលដឹង ហើយក៏មិនដែលធ្វើដែរ។ មិត្ត ភី គំហកមកខ្ញុំដោយនិយាយខ្លាំងៗថា និយាយឲ្យពិតណាអង្គការនៅតែតាមដានតទៅទៀតអង្គការមានភ្នែកម្នាស់ អ្នកណាធ្វើអីក៏អង្គការដឹងដែរ បើនិយាយមិនពិតអាចអង្គការកម្ទេចណា បើនិយាយត្រង់ជាមួយអង្គការអាចរស់។ ខ្ញុំបន្តថាបាទខ្ញុំនិយាយតែការពិតទេ មិនហ៊ានលាក់បាំងជាមួយអង្គការទេ បើមានការខុសឆ្គងអី សុំអង្គការមេត្តាអភ័យទោសផងៗ មិត្តភីបន្តថា ចុះមុនចេញពីភ្នំពេញថ្ងៃទី១៧ មេសា ១៩៧៥ អ្នកឯងបានសឹកម្តងហើយតើមែនឬអត់? ឮពាក្យនេះភ្លាមខ្ញុំក៏ឆ្លើយភ្លាមថា ខ្ញុំមិនដែលសិក្ខទេចាប់តាំងពីខ្ញុំបួសរហូតដល់ខែ៧ ឆ្នាំ១៩៧៥ ទើបខ្ញុំសិក្ខនៅវត្តបឹងដោល។ មិត្តភីបន្តថា តាមពិតអ្នកឯងទើបនឹងមកស្លៀកស្បង់ចីវរតាមផ្លូវបន្លំគេនៅពេលដឹងថាខ្លួនត្រូវត្រឡប់មកស្រុកកំណើតវិញមែន? មិត្ត ភី គំហកហើយនិយាយបន្តថា កុំភូតណា ខ្ញុំឆ្លើយការពារថាខ្ញុំមិនកុហកទេ នេះជាការពិតស្រាប់តែឮស្នូរក្រាកក្បែរខ្លួនខ្ញុំ(គេទាញក្តគោក្រោម) ហើយគេវ៉ាយមកលើខ្នងខ្ញុំបីដងដូងៗក៏ឈប់ ខ្ញុំឈឺណាស់តែខ្ញុំអត់ធ្មត់ នៅតែតមាត់ទៅទៀតថា និយាយនេះមិនពិតទេ ខ្ញុំស្មោះត្រង់ជាមួយអង្គការសុំមេត្តារកយុត្តិធម៌ឲ្យខ្ញុំផងៗ មិត្ត ភី សួរបន្តទៀតថា អ្នកឯងស្គាល់ឈ្មោះ ជាម យៀប ទេត្រូវជាយ៉ាងម៉េចជាមួយអ្នកឯង? ហើយថ្ងៃមុននេះឮថាប្រុងរត់ទៅស្រុកយួនផងមែនឬអត់? ខ្ញុំឆ្លើយថាមិនដែលស្គាល់ឈ្មោះ ជាម យៀប ទេហើយក៏មិនដឹងថាឈ្មោះនេះត្រូវជាអ្វីនឹងខ្ញុំផង ខ្ញុំឮតែបងប្អូនខ្ញុំប្រាប់ថាមានឈ្មោះ អៀប ត្រូវជាបងប្អូនខាងឪពុកខ្ញុំគាត់ជាគ្រូបង្រៀននៅពាមរក៍ស្រុកកំណើតជីតាខ្ញុំ ពីមុនមកពួកយើងពុំដែលបានស្គាល់គ្នាទេក្រោយមកក៏ពុំដែលដែលបានជួបគ្នាដែរ។ មិត្ត ភី បន្តថាចុះកាលនៅប្រព័ន្ធភ្លឺស្រែ ក្រែងដេកនៅរោងជាមួយគ្នាហ្អេះ? ស្រាប់តែគេវាយខ្នងខ្ញុំទៀតខ្ញុំក៏ផ្តេកខ្នងខ្ញុំកុំឲ្យគេវាយត្រូវក្បាលខ្ញុំ ២ក្តគោក្រោម រួចខ្ញុំឆ្លើយថាគាត់នៅក្រុមភូមិឬស្សីស្រុក ខ្ញុំនៅរោងភូមិបឹងដោល មិនបានដេកជាមួយគ្នាទេ។ បានតែប៉ុណ្ណោះមិត្ត ភី សួរទៅគ្នាគេថា មានអ្នកណាដឹងព័ត៌មានចង់សួរបន្ថែមទេ? បានន័យថាពេលខ្ញុំកំពុងនិយាយមានមនុស្សច្រើនរង់ចាំថ្ងៃក្រោយចាំសួរទៀតពេលនោះមានគេមកចាប់ចំណងស្ទាបសេកខ្ញុំឲ្យខ្ញុំក្រោកឈរឡើង និងបង្កិលឲ្យខ្ញុំដើរទៅមុខរួចស្រាយមុខនិងដៃនៅក្បែរមន្ទីរសន្តិសុខវិញ។ ក្រោយពីស្រាយក្រមាយកមកបង់ក ខ្ញុំឃើញក្រមាខ្ញុំឈាមប្រលាក់ទទឹកយ៉ាងច្រើន។ ពេលឃើញឈាមខ្ញុំស្ទាបក្បាលត្រង់កន្លែងដែលគេវាយត្រូវឈឺផ្សាៗ នៅលើក្បាលមានដាច់សាច់២កន្លែងនៅខ្នងរយះសាច់មួយកន្លែងនិងជើងរយះមួយកន្លែងៗ ខ្ញុំបានដើរចូលទៅយកចានបបរមកហូប មិត្ត សុន ក៏ចេញពីផ្លូវរត់មករកខ្ញុំ ដៃកាន់ត្រួយ

(តនៅលេខក្រោយ)

រូបក្របមុខ និង ក្របក្រោយ ៖
នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងកម្លាំងកុម្មុយនីស្តខ្មែរក្រហម បានគ្រប់គ្រងប្រទេសកម្ពុជាទាំងស្រុង និងបានជម្លៀសប្រជាជនចេញពីផ្ទះសម្បែងឲ្យទៅរស់នៅតាមសហករណ៍ស្ថិតនៅទីជនបទដាច់ស្រយាល។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ ៖ (៨៥៥) ៧៨ ៦៩៨ ៣៣៣

DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chatomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 1110

Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 292, April 2024 ◆ Funded by USAID

Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.